ISSN 1560-7615 / ISBN 978-99950-52-06-5

ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៥ លេខ ២ | មេសា - មិថុនា ឆ្នាំ២០១១ | តម្លៃ ១.៥០០រ

# ជម្រុញកំណើនសេដ្ឋកិច្ចខ្ពស់ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា៖ ទស្សនៈ និងអាទិភាពគោលនយោបាយ ទទួលបានពីសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១១[១]

សន្និសីទចក្ខុវិស័យកម្ពុជាប្រចាំឆ្នាំលើកទី៥ បានប្រារព្ធឡើងកាលពីថ្ងៃទី១៦ មីនា ២០១១ នៅសណ្ឋាគារភ្នំពេញ។ សន្និសីទនេះ បានអញ្ជើញតំណាងជាន់ខ្ពស់មកពីខាងរដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ សហគមន៍ស្រាវជ្រាវ និងសង្គមស៊ីវិល មកជួបជុំគ្នាដើម្បីធ្វើការពិភាក្សាអំពីប្រធានបទ "ជម្រុញកំណើនសេដ្ឋកិច្ចខ្ពស់ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា៖ កាលានុវត្តភាព និងបញ្ហាប្រឈម"។ នៅក្នុងសុន្ទរកថាគន្លឹះបើកសន្និសីទ សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសម្ដែងការអបអរសាទរចំពោះ វិទ្យាស្ថាន CDRI និងធនាគារ ANZ Royal ដែលបានសហការគ្នាផ្ដួចផ្ដើមគំនិតបង្កើតសន្និសីទប្រចាំឆ្នាំដ៏មានសារៈសំខាន់នេះ ហើយសម្ដេច បានថ្លែងថា សន្និសីទនេះប្រារព្ធឡើងចំពេលវេលាល្អ និងមានភាពពាក់ព័ន្ធនឹងកាលៈទេសៈបច្ចុប្បន្ន។

អត្ថបទនេះ បូកសរុបពីចំណុចសំខាន់ៗនៃសន្និសីទចក្ខុវិស័យ មានជាអាទិ៍ ក្របខ័ណ្ឌច្បាប់និងស្ថាប័ននៅកម្ពុជា ទម្រង់ទូទៅនៃកម្លាំងពលកម្ម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដោយផ្ដោតលើទស្សនៈ និងអាទិភាពគោលនយោបាយនានា ដែលវាគ្មិន និងអ្នកចូលរួមទាំងឡាយបានលើកឡើង។ បទបង្ហាញនានា ក្នុងសន្និសីទចក្ខុវិស័យ អាចរកបាននៅក្នុងគេហទំព័ររបស់វិទ្យាស្ថាន CDRI៖ www.cdri.org.kh។




*សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងសុន្ទរកថាគន្លឹះបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាប្រចាំឆ្នាំលើកទី៥ កាលពីថ្ងៃទី១៦ មីនា ២០១១*

កម្ពុជា កំពុងបន្តដំណើររើបឡើងវិញយ៉ាងខ្លាំងក្លាពីវិបត្តិសេដ្ឋកិច្ចពិភពលោក ដោយមានអត្រាកំណើនសេដ្ឋកិច្ចដែលរំពឹងថានឹងកើនឡើងពី ៥,៩% នៅឆ្នាំ២០១០ ដល់ ៦-៧% នៅឆ្នាំនេះ។ វិស័យជម្រុញកំណើនតាំងពីដើមរៀងមករបស់កម្ពុជា និងវិស័យនានាដែលរងការប៉ះទង្គិចធ្ងន់ធ្ងរ ក្នុងអំឡុងពេលមានវិបត្តិនោះ កំពុងរើបឡើងវិញគួរឲ្យកត់សម្គាល់ ហើយថែមទាំងបានជួយជម្រុញកំណើនសេដ្ឋកិច្ចនាពេលបច្ចុប្បន្នទៀតផង។ វិស័យឧស្សាហកម្មមានដំណើរការខ្លាំងជាងគេ ដោយសម្រេចបានកំណើន ១៣,៥% នៅឆ្នាំ២០១០ ធៀបនឹង -៩,៥% នៅឆ្នាំ២០០៩។ ដោយឡែក វិស័យកាត់ដេរក្នុងពេលដ៏ខ្លីខាងមុខរំពឹងថាអាចកើនលឿនដល់កម្រិតដូចនៅមុនពេលមានវិបត្តិ ដោយបង្កើតការងារបានដល់ ៥៥.០០០ គឺស្ទើរតែស្មើនឹងចំនួនការងារដែលបានបាត់បង់ក្នុងអំឡុងពេលមានវិបត្តិ។ ស្ថិតិកំណើន មានលក្ខណៈល្អ ប៉ុន្តែរចនាសម្ព័ន្ធសេដ្ឋកិច្ចនៅបង្កក្ដីបារម្ភដែល

## មាតិកា

ជម្រុញកំណើនសេដ្ឋកិច្ចខ្ពស់ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា៖ ទស្សនៈ និងអាទិភាពគោលនយោបាយ ទទួលបានពីសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១១ .......... ១
ការវិវត្តថ្មីៗក្នុងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រុង ស្រុក ខណ្ឌ នៅកម្ពុជា .......... ៦
អង្កេតស្ដីពីសមត្ថភាព និងការត្រៀមខ្លួនរបស់ឃុំក្នុងការគ្រប់គ្រងគម្រោងអភិវឌ្ឍន៍មូលដ្ឋាន៖ លទ្ធផលបឋម .. ១២
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស .......... ១៨
— ស្ថានភាពក្នុងប្រទេស .......... ២០
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI .......... ២៨

១ អត្ថបទនេះ រៀបរៀងដោយ Benjamin C. R. FLOWER កម្មសិក្សាការីផ្នែកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI ដោយផ្អែកលើបទបង្ហាញនានាក្នុងសន្និសីទចក្ខុវិស័យ ។

ពីព្រោះត្រូវពឹងផ្អែកលើវិស័យកាត់ដេរ និងទេសចរណ៍ ដែលងាយរងគ្រោះដោយសារហានិភ័យពីខាងក្រៅ។ ការពឹងផ្អែកខ្លាំងពេកលើតម្រូវការពីខាងក្រៅនូវមុខផលិតផលមួយចំនួនតូច អាចគ្រោះថ្នាក់ខ្លាំងណាស់ ប្រសិនបើតម្រូវការធ្លាក់ចុះ ឬលក្ខខណ្ឌពាណិជ្ជកម្មប្រែប្រួលផ្សេង។ ដើម្បីកាត់បន្ថយហានិភ័យនេះ និងកសាងមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ពេលអនាគត ប្រទេសកម្ពុជាត្រូវឆក់ឱកាសនេះ ដើម្បីធ្វើពិពិធកម្មសេដ្ឋកិច្ច ដោយពង្រីកសកម្មភាពទាក់ទងច្រើនវិស័យ បង្កើតសកម្មភាពថ្មីៗក្នុងវិស័យនីមួយៗ បង្កើនខ្សែសង្វាក់តម្លៃបន្ថែម និងចូលទៅក្នុងទីផ្សារថ្មីៗផ្សេងទៀត។

ឈរលើជោគជ័យសម្រេចបានក្នុងពេលកន្លងមក និងក្នុងការស្វែងរកដំណោះស្រាយគោលនយោបាយសមស្រប សម្រាប់អនាគត សន្និសីទចក្ខុវិស័យឆ្នាំ២០១១ បានផ្តោតលើចំណុចសំខាន់ៗ ៣ ដែលទាមទារឱ្យមានការចូលរួមរបស់រដ្ឋាភិបាលដើម្បីធានាឲ្យមានកំណើនខ្ពស់ ប្រកបដោយសមធម៌ និងនិរន្តរភាព គឺមាន៖ (១) គោលនយោបាយពង្រឹងបរិយាកាសច្បាប់ និងស្ថាប័នសម្រាប់ពាណិជ្ជកម្មនិងវិនិយោគ ការលើកទឹកចិត្តដល់វិស័យនាំចេញថ្មីៗឲ្យមានលក្ខណៈចម្រុះច្រើនមុខ និងមានកំណើនប្រកបដោយសមធម៌ (២) គោលនយោបាយលើកកម្ពស់ធនធានមនុស្សកម្ពុជាឲ្យក្លាយជាកត្តាជម្រុញផង និងជាអ្នកទទួលផលប្រយោជន៍ផងពីពិពិធកម្មសេដ្ឋកិច្ច និង (៣) គោលនយោបាយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដ៏ចាំបាច់ សម្រាប់ជួយទ្រទ្រង់មាគ៌ាអភិវឌ្ឍន៍របស់កម្ពុជា។

## ការកសាងបរិយាកាសច្បាប់ និងស្ថាប័ន ឲ្យមានលក្ខណៈអំណោយផល

ក្នុងរយៈពេលមធ្យម ពាណិជ្ជកម្ម និងវិនិយោគ រំពឹងថានឹងកើនឡើង (ក្រាហ្វិក ១)។ គោលនយោបាយសមស្របអនុវត្តដោយស្ថាប័នមានតម្លាភាពល្អ នឹងពង្រឹងកំណើននេះ ហើយញ៉ាំងឲ្យវាមានចីរភាព និងសមធម៌ថែមទៀត។ ភាពអំណោយផលនៃបរិយាកាសស្ថាប័ន គោលនយោបាយ និងច្បាប់ សំខាន់ខ្លាំងណាស់ក្នុងការជម្រុញកម្ពុជាឲ្យមានផលិតផល និងសេវាកម្មនាំចេញថ្មីៗ មានទីផ្សារក្នុងតំបន់ភូមិសាស្ត្រថ្មីៗ និងឲ្យបង្កើនតម្លៃខ្សែសង្វាក់ផលិតកម្ម។ ការជួយឲ្យវិស័យទើបស្ទុះឡើង (ឧ. កសិកម្ម) ដើម្បីទទួលបានផលចំណេញពីកំណើនពាណិជ្ជកម្ម និងវិនិយោគ អាចជម្រុញយ៉ាងច្រើនដល់ការកាត់បន្ថយភាពក្រីក្រ ហើយគោលនយោបាយផ្តោតចំវិស័យទាំងនេះ អាចញ៉ាំងឲ្យលទ្ធផលសម្រេចបានប្រសើរបំផុត។

គោលនយោបាយពាណិជ្ជកម្ម ជាសមាសភាគស្នូលមួយនៃយុទ្ធសាស្ត្រពិពិធកម្មរបស់រដ្ឋាភិបាល។ ក្នុងក្របខ័ណ្ឌនៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (SWAp) គេព្យាយាមបញ្ជ្រាបគោលនយោបាយពាណិជ្ជកម្ម ដោយធ្វើការសម្របសម្រួលរវាងធនធានរដ្ឋាភិបាល និងធនធានរបស់ដៃគូអភិវឌ្ឍន៍ ដើម្បីឲ្យគោលនយោបាយមានឥទ្ធិពលខ្លាំងបំផុត។ ក្របខ័ណ្ឌនេះសំដៅដោះស្រាយទាំងឧបសគ្គជាក់លាក់ និងឧបសគ្គមានលក្ខណៈជាប្រព័ន្ធដែលរារាំងពិពិធកម្មសេដ្ឋកិច្ច។ ទាក់ទងនឹងឧបសគ្គមានលក្ខណៈជាប្រព័ន្ធ គេឃើញមានការរួមកម្លាំងគ្នាកសាងសមត្ថភាពស្ថាប័ននានា ដើម្បីជម្រុញការអនុវត្តគោលនយោបាយពាណិជ្ជកម្មឲ្យ

ក្រាហ្វិក ១. ទម្រង់ពាណិជ្ជកម្មកម្ពុជា និងវិនិយោគផ្ទាល់ពីបរទេស (FDI)




ប្រភព៖ បទបង្ហាញក្នុងសន្និសីទចក្ខុវិស័យឆ្នាំ២០១១

បានសមស្រប។ តួយ៉ាង គម្រោងពាណិជ្ជកម្ម UNDP មួយ បានផ្តោតលើការកសាងសមត្ថភាព និងការសម្របសម្រួលរវាងនាយកដ្ឋានមួយចំនួនរបស់ក្រសួងពាណិជ្ជកម្ម។ ក្របខ័ណ្ឌគោលនយោបាយតាមវិស័យជាក់លាក់មួយចំនួន ក៏បានដាក់អនុវត្តដែរ ជាអាទិ៍ គោលនយោបាយជម្រុញផលិតកម្មស្រូវ និងការនាំចេញស្រូវ ដែលបានដាក់ចេញដោយសម្តេចនាយករដ្ឋមន្ត្រី ក្នុងខែកក្កដា ២០១០ គឺជាកិច្ចប្រឹងប្រែងដំបូងបង្អស់ ដើម្បីឆ្លើយតបចំពោះតម្រូវការផ្ទាល់របស់វិស័យនាំចេញជាក់លាក់នីមួយៗ នៅក្រោមក្របខ័ណ្ឌនៃ SWAp។

គោលនយោបាយអាចមានប្រសិទ្ធភាព លុះណាតែបានកំណត់ត្រឹមត្រូវពីឧបសគ្គនានា ហើយបានផ្តោតលើទម្រង់សេដ្ឋកិច្ច-សង្គមកិច្ច និងប្រជាសាស្ត្រខុសៗគ្នានៅកម្ពុជា។ វេទិការដ្ឋាភិបាល-វិស័យឯកជន បានជួយសម្រួលដល់កិច្ចសន្ទនានៅកម្រិតជាតិរវាងរដ្ឋាភិបាល និងវិស័យឯកជន ដើម្បីធានាថាគោលនយោបាយពាណិជ្ជកម្ម មានបង្ហាញពីធាតុពិតនៃការផ្លាស់ប្តូរសេដ្ឋកិច្ចនៅកម្ពុជា។ ប៉ុន្តែ ការទាក់ទាញអ្នកពាក់ព័ន្ធក្នុងវិស័យឯកជនឲ្យមកចូលរួម ត្រូវជួបបញ្ហាចោទ ដោយសារសហគ្រិន តែងធ្វើការគិតគូរសម្រាប់រយៈពេលខ្លី ចំណែកឯពិពិធកម្មគឺជាយុទ្ធសាស្ត្ររយៈពេលវែង។

ដើម្បីតម្រឹមចំណុចទាំងពីរនេះ រដ្ឋាភិបាលគួរផ្តល់គ្រឿងលើកទឹកចិត្តដល់វិស័យឯកជនឲ្យខំគិតគូរ សម្រាប់រយៈពេលវែង និងជួយដល់ការធ្វើពិពិធកម្ម។ ម៉្យាងទៀតត្រូវមានការវិភាគ និងស្រាវជ្រាវស៊ីជម្រៅផ្នែកគោលនយោបាយ ដើម្បីជួយឲ្យគោលនយោបាយពាណិជ្ជកម្មមានបង្ហាញពី តម្រូវការរបស់ជនងាយរងគ្រោះបំផុតក្នុងសង្គម។ ក្នុងគោលដៅនេះ យុទ្ធសាស្ត្រធ្វើពោតវិនិច្ឆ័យលើសមាហរណកម្មពាណិជ្ជកម្មឆ្នាំ២០០៧ បានជួយកំណត់វិស័យនាំចេញចំនួន ១៩ ដែលមានសក្តានុពលកាត់បន្ថយភាពក្រីក្របានច្រើន។ រដ្ឋាភិបាលត្រូវបង្កើនសមត្ថភាពស្រាវជ្រាវគោលនយោបាយ នៅក្នុងបណ្តាញស្ថាប័នស្រាវជ្រាវនៅកម្ពុជា ដើម្បីពង្រឹងការយល់ដឹងពីទំនាក់ទំនងរវាងការអភិវឌ្ឍវិស័យនាំចេញ និងការអភិវឌ្ឍធនធានមនុស្សប្រកបដោយនិរន្តរភាព។ ធនធានសម្រាប់ការស្រាវជ្រាវ ក៏ត្រូវយកមកប្រើប្រាស់ ដើម្បីត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃគោលនយោបាយ សំដៅចូលរួមចំណែកជម្រុញកំណើនប្រកបដោយសមធម៌ ដោយជួយឲ្យគោលនយោបាយអាចដាក់អនុវត្តបានសមស្រប និងសម្រេចបានពេញលេញតាមគោលបំណង។

សមត្ថភាពស្ថាប័ន ជាកត្តាដ៏សំខាន់សម្រាប់លើកកម្ពស់បរិយាកាសវិនិយោគនៅកម្ពុជា។ តំបន់សេដ្ឋកិច្ចពិសេស (SEZ) ជាឧទាហរណ៍ជាក់ស្តែងមួយ ដែលបញ្ជាក់ពីជោគជ័យនៃគោលនយោបាយបច្ចុប្បន្នរបស់កម្ពុជា ក្នុងការទាក់ទាញវិនិយោគឯកជនច្រើនៗ ប្រសិនបើឧបសគ្គខាងស្ថាប័នត្រូវបានដោះស្រាយ។ ប្រទេសកម្ពុជា និង SEZ មានក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិស្រដៀងគ្នា ប៉ុន្តែ នីតិវិធីអនុវត្តច្បាប់នៅក្នុង SEZ មានភាពលឿនជាង និងងាយស្មានដឹងមុនជាង។ កំណើនចំនួនវិនិយោគ នៅ SEZ បញ្ជាក់ច្បាស់ថា វិនិយោគិនឲ្យតម្លៃខ្ពស់ទៅលើដំណើរការអនុវត្តច្បាប់ប្រកបដោយតម្លាភាព។ ដូច្នេះ កិច្ចការសំខាន់គឺត្រូវសិក្សាពីក្របខ័ណ្ឌច្បាប់ដែលមានដំណើរការល្អក្នុង SEZ និងទាញយកបទពិសោធន៍នេះ ធ្វើជាការសន្និដ្ឋានទូទៅសម្រាប់សេដ្ឋកិច្ចកម្ពុជា។

ប្រព័ន្ធតុលាការទន់ខ្សោយ ជាឧបសគ្គខាងស្ថាប័នចំបងមួយចំពោះវិនិយោគ ជាពិសេសក្នុងវិស័យដែលត្រូវការរយៈពេលវែងដើម្បីផ្តល់ផលចំណេញ (ឧទាហរណ៍វិស័យកសិកម្ម)។ នៅពេលសេដ្ឋកិច្ចរីកលូតលាស់ និងមានសកម្មភាពកាន់តែច្រើនមុខ ភាពទន់ខ្សោយនៃប្រព័ន្ធតុលាការ ក៏មានផលប៉ះពាល់កាន់តែធ្ងន់ធ្ងរឡើង។ ដំណោះស្រាយជាក់ស្តែងមួយ គឺត្រូវកសាងសមត្ថភាពយន្តការដោះស្រាយទំនាស់ ដែលមិនមែនជាប្រព័ន្ធតុលាការ ជាអាទិ៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រាប់ដោះស្រាយវិវាទឧស្សាហកម្ម ឬគណៈកម្មការសុរិយោដីសម្រាប់ដោះស្រាយជម្លោះដីធ្លី ជាដើម។ ការបង្កើតស្ថាប័នឯករាជ្យដាច់ពីតុលាការមានន័យថា វិនិយោគនឹងមិនជួបឧបសគ្គដោយសារកង្វះសមត្ថភាពនៃប្រព័ន្ធតុលាការ ហើយតុលាការក៏នឹងមិនរងបន្ទុកធ្ងន់ដោយសារចំនួន និងភាពស្មុគស្មាញនៃករណីបណ្តឹងដែរ។ លើសពីនេះទៀត ស្ថាប័នឯកទេសដែលមានតម្លាភាព អាចជួយកាត់បន្ថយការចែកចាយព័ត៌មានទីផ្សារមិនស្មើភាព ជួយបង្កើនប្រសិទ្ធភាព និងកាត់បន្ថយហានិភ័យ ព្រមទាំងភាពមិនច្បាស់លាស់សម្រាប់វិនិយោគិន។

ស្ថិរភាព ជាកត្តាសំខាន់បំផុតក្នុងការកំណត់ស្ថានភាពសេដ្ឋកិច្ចរយៈពេលវែងរបស់ប្រទេសមួយ និងជាបុរេលក្ខខណ្ឌដ៏ចាំបាច់សម្រាប់វិនិយោគ។ កន្លងមក កម្ពុជាបានអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចយ៉ាងវៃឆ្លាត៖ បរិយាកាសទូទៅមានស្ថិរភាពល្អនិងអំណោយផលដល់វិនិយោគ អតិផរណាមានកម្រិតទាប ធនបម្រុងជារូបិយវត្ថុបរទេសកើនឡើងដល់ ២,៧ពាន់លានដុល្លារអាមេរិក នៅចុងឆ្នាំ២០១០ ហើយបំណុលសាធារណៈមានកម្រិតអាចគ្រប់គ្រងបាន។ ដោយសារស្ថិរភាពល្អ វិនិយោគផ្ទាល់ពីបរទេស (FDI) កើនបាន ៤២លានដុល្លារពីឆ្នាំ២០១០-២០១១ ថ្វីបើនៅទាបជាងល្បឿនកំណើនមុនពេលមានវិបត្តិសេដ្ឋកិច្ចក្តី។ មកទល់ពេលនេះ វិធានការឆ្លើយតបល្អរបស់ធនាគារជាតិនៃកម្ពុជា (ការតម្លើងថ្លៃប្រាក់រៀល និងការបង្កើនធនបម្រុងជារូបិយវត្ថុបរទេស) អាចគ្រប់គ្រងអតិផរណាបាន។ ប៉ុន្តែដោយសារកំណើនអត្រាអតិផរណាក្នុងតំបន់ និងសម្ពាធផុសចេញពីកំណើនសេដ្ឋកិច្ច លំហូរចូលមូលធន និងកំណើនចំណាយសាធារណៈ ដូច្នេះរដ្ឋាភិបាលត្រូវតែគ្រប់គ្រងអតិផរណាឲ្យបានតាមរយៈគោលនយោបាយដ៏សមស្រប។ កត្តាអាចបង្កអស្ថិរភាពសេដ្ឋកិច្ចមួយទៀត គឺការផ្តត់ផ្គង់ឥណទានដល់វិស័យឯកជនដែលបានកើនឡើង ៣០% ពីឆ្នាំ ២០០៩-២០១០ (ក្រាហ្វិក ២) ដែលត្រូវមានបទបញ្ញត្តិសម្រាប់កាត់បន្ថយហានិភ័យ និងគ្រប់គ្រងនិន្នាការឡើងថ្លៃទំនិញ។ ប្រភពនៃអស្ថិរភាពនយោបាយដូចជា ការទន្ទ្រានយកដី ការអភិវឌ្ឍទីក្រុងឡើងវិញ និងការឡើងថ្លៃអាហារ ក៏គួរតែដោះស្រាយដែរ។

ក្រាហ្វិក ២. កំណើនឥណទានសម្រាប់វិស័យឯកជន




ប្រភព៖ បទបង្ហាញក្នុងសន្និសីទចក្ខុវិស័យឆ្នាំ២០១១

## ការអភិវឌ្ឍកម្លាំងពលកម្ម

កម្ពុជា មានប្រជាជនវ័យក្មេងយ៉ាងច្រើន ដែលសកម្ម និងធ្វើការផ្លាស់ទីចុះឡើង។ បើសិនមានគោលនយោបាយសមស្រប ទ្រព្យសំណាងជាប្រជាជននេះ អាចក្លាយជាសម្បត្តិដ៏ស្តុកស្តម្ភ សម្រាប់ជម្រុញ និងធ្វើពិពិធកម្មកំណើនសេដ្ឋកិច្ច។ តាំងពីដើមរៀងមក ថ្លៃពលកម្មទាបជាកត្តាសំខាន់មួយសម្រាប់ទាក់ទាញវិនិយោគទុនបរទេស ជាពិសេស ក្នុងវិស័យកម្មន្តសាល។ វិនិយោគនេះ បានផ្តល់ការងាររាប់ពាន់ ព្រមទាំងជាឈ្នាន់មួយសម្រាប់ការឈានឡើងផ្នែកឧស្សាហកម្ម។ ការពង្រឹងផលចំណេញទាំងនេះ និងការធ្វើពិពិធកម្មសេដ្ឋកិច្ច ត្រូវមានការជម្រុញជាគោលនយោបាយរួមមួយពីសំណាក់រដ្ឋាភិបាល។ គន្លឹះសំខាន់ គឺសមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការផ្តល់កម្លាំងពលកម្មមានជំនាញដ៏ចាំបាច់សម្រាប់ជម្រុញពិពិធកម្ម ព្រមទាំងពង្រឹងវិស័យជាប្រពៃណី ដូចជា ទេសចរណ៍ និងផ្នែកកាត់ដេរជាដើម។

លក្ខខណ្ឌចាំបាច់សម្រាប់កំណើនសេដ្ឋកិច្ចចម្រុះបែប គឺការបង្កើនផលិតភាពពលកម្មក្នុងវិស័យកសិកម្ម។ នាបច្ចុប្បន្ន ការរួមចំណែករបស់មនុស្សម្នាក់គិតក្នុងមួយឯកតាកំណើន ផសស មានលក្ខណៈមិនស្មើគ្នាទេរវាងវិស័យនានា ដោយឡែក ពលករក្នុងកសិកម្ម មានផលិតភាពតិចជាង ពលករក្នុងឧស្សាហកម្ម (មានផលិតភាពខ្ពស់ជាងគេ) ឬពលករក្នុងសេវាកម្ម។ រាជរដ្ឋាភិបាលបានផ្តោតកម្លាំងលើការបង្កើនផលិតភាពពលកម្ម ក្នុងកសិកម្ម ដោយធ្វើការផ្សព្វផ្សាយពីជំនាញថ្មីៗ បច្ចេកទេស និងផ្តល់ការបណ្តុះបណ្តាលដល់កម្លាំងពលកម្មនៅជនបទ។ ថវិកាជាតិបានជួយទ្រទ្រង់យ៉ាងច្រើនដល់ មជ្ឈមណ្ឌលបណ្តុះបណ្តាលកសិកម្មខេត្ត ដើម្បីផ្តល់កម្មវិធីបណ្តុះបណ្តាល អំពីវិធីសាស្រ្តដាំដុះ ផលិតកម្មជី ការរក្សាទុកកសិផលក្រោយពេលប្រមូលផល ការដាំដំណាំចម្រុះ និងជំនាញមូលដ្ឋាននៃសហគ្រិន។ ការបង្កើនផលិតភាពពលកម្មក្នុងវិស័យនេះ នឹងជះឥទ្ធិពលជម្រុញផលិតកម្មកសិកម្ម ព្រមទាំងជួយរំដោះកម្លាំងពលកម្មលើសតម្រូវការចេញពីវិស័យកសិកម្ម ឲ្យចូលបម្រើក្នុងឧស្សាហកម្ម និងសេវាកម្មដែលមានផលិតភាពខ្ពស់ជាង។

នាបច្ចុប្បន្ន កម្លាំងពលកម្មរបស់កម្ពុជានៅខ្វះខាតជំនាញដ៏ចាំបាច់សម្រាប់ពិពិធកម្មក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម ក្នុងនេះ គេចាំបាច់ត្រូវកែលម្អស្តង់ដារ និងបង្កើនលទ្ធភាពទទួលបានការអប់រំថ្នាក់ខ្ពស់ ដើម្បីដោះស្រាយ "ចន្លោះខ្វះខាតជំនាញនេះ"។ ស្ថាប័នអប់រំថ្នាក់ខ្ពស់ (HEIs) ជាច្រើននៅកម្ពុជា នៅទាបជាងស្តង់ដារអន្តរជាតិក្នុងវិស័យស្នូល ដូចជា ការស្រាវជ្រាវ អភិបាលកិច្ច និងការបង្រៀន។ បន្ថែមលើកង្វះសមត្ថភាពស្ថាប័ននេះ នៅមានកង្វះសម្ភារៈសម្រាប់ការស្រាវជ្រាវ និងការបង្រៀន ដូចជា សៀវភៅ បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ទំនើប បន្ទប់ពិសោធន៍។ល។ អត្រាចុះឈ្មោះចូលរៀននៅជនបទ នៅទាបជាខ្លាំងជាងតំបន់ទីក្រុង ហើយជនវណ្ណៈខ្ពស់មានប្រៀបលើសលុបជាងគេ។ ជាដំណោះស្រាយ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣ បានផ្តោតលើសមត្ថភាព និងដែនឈោងដល់នៃការអប់រំថ្នាក់ខ្ពស់ ដោយពង្រីកលទ្ធភាពទទួលបានការអប់រំ តាមរយៈកម្មវិធីអាហារូបករណ៍ និងការកែលម្អស្តង់ដារបង្រៀន និងការស្រាវជ្រាវតាមកម្មវិធីកសាងសមត្ថភាពផ្សេងៗ។ បទបញ្ញត្តិសមស្រប ក៏មានតួនាទីសំខាន់ដែរ មានជាអាទិ៍ ក្រមសីលធម៌ ស្តង់ដារនិងប្រព័ន្ធទទួលស្គាល់គុណភាពសម្រាប់លើកទឹកចិត្ត HEIs ឲ្យកែលម្អគុណភាព និងផ្តល់ព័ត៌មានកាន់តែច្រើនដល់និយោជក និងនិស្សិត អំពីមុខវិជ្ជា និងគុណភាពនៃសញ្ញាប័ត្ររបស់ខ្លួន។

បញ្ហាស្នូលមួយទៀត ទាក់ទិននឹងប្រសិទ្ធភាពទីផ្សារពលកម្ម គឺភាពមិនស៊ីគ្នារវាងជំនាញដែលវិស័យឯកជនស្វែងរកក្នុងទីផ្សារពលកម្ម និងជំនាញដែល HEIs ផ្គត់ផ្គង់។ បញ្ហានេះចោទជាពិសេស ក្នុងមុខជំនាញវិជ្ជាជីវៈមួយចំនួនដែលឧស្សាហកម្មប្រភេទខ្លះត្រូវការជាចាំបាច់។ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ជាក្របខ័ណ្ឌគោលនយោបាយពលកម្មរួមរបស់រដ្ឋាភិបាល សម្រាប់ផ្តល់ឲ្យទីផ្សារពលកម្មកម្ពុជានូវមុខជំនាញដែលនិយោជកចង់បាន។ គំនិតផ្តួចផ្តើមផ្សេងៗ រួមមានរបៀបវារៈកំណែទម្រង់នៃ គណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB) ការបង្កើត ទីភ្នាក់ងារជាតិមុខរបរ (NEA) និងគម្រោងពង្រឹង ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (STVET) ដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី។ មានបញ្ហាប្រឈមជាច្រើនសម្រាប់ TVET ជាពិសេសទស្សនៈក្នុងសង្គមដែលថា TVET ជាវគ្គបណ្តុះបណ្តាលសម្រាប់ពលករសាមញ្ញ មិនមែនអ្នកមានជំនាញវិជ្ជាជីវៈទេ។ គោលនយោបាយរបស់រដ្ឋាភិបាល ត្រូវផ្តោតលើការកែប្រែទស្សនៈទាំងនេះ តាមរយៈបទបញ្ញត្តិសមស្រប និងប្រព័ន្ធទទួលស្គាល់គុណភាពអប់រំ។

## ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

ក្នុងមួយទសវត្សរ៍កន្លងទៅនេះ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងអគ្គិសនីនៅកម្ពុជា មានការអភិវឌ្ឍយ៉ាងច្រើន។ លទ្ធផលទាំងនេះ ភាគច្រើនបានមកពីកិច្ចសហប្រតិបត្តិការក្នុងតំបន់ តាមរយៈគំនិតផ្ដួចផ្ដើមមហាអនុតំបន់មេគង្គដែលគាំទ្រដោយ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB-GMS)។ ត្រឹមចុងឆ្នាំ២០០៨ ADB បានផ្ដល់មូលនិធិ ៤១៨លានដុល្លារ សម្រាប់ទ្រទ្រង់ដល់គម្រោងទាំងអស់ ៩។ គំនិតផ្ដួចផ្ដើម ADB-GMS កន្លងមក សំខាន់ជាខ្លាំងសម្រាប់ការអភិវឌ្ឍច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង (SEC) ដោយបានកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត តភ្ជាប់ប្រទេសកម្ពុជាទៅថៃ វៀតណាម និង ឡាវ។ បច្ចុប្បន្ន កម្ពុជាកំពុងស្ដារជួសជុសបណ្ដាញផ្លូវដែកដែលចាស់ទ្រុឌទ្រោម ដោយមានការគាំទ្រពី ADB និងវិនិយោគពីវិស័យឯកជន។ គម្រោងមានតម្លៃ ១៤៨លានដុល្លារនេះ នឹងតភ្ជាប់ប្រទេសកម្ពុជា ទៅថៃ និងវៀតណាម ហើយក្លាយជាចំណែកដ៏សំខាន់មួយនៃផ្លូវដែក តភ្ជាប់ពីសិង្ហបុរីទៅក្រុងគុនមីង (Kunming) នៃខេត្តយូន់ណាន (Yunnan) ប្រទេសចិន។ ហេដ្ឋារចនាសម្ព័ន្ធផ្លូវគោក និងផ្លូវដែក នឹងជួយឲ្យកម្ពុជាអាចធ្វើសមាហរណកម្មកាន់តែប្រសើរទៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ក្នុងតំបន់ ដោយអាចបង្កើនតម្លៃបន្ថែម និងចូលទៅកាន់ទីផ្សារថ្មីៗ។

សមត្ថភាពផ្គត់ផ្គង់ភស្តុភារ (logistics) នាពេលបច្ចុប្បន្ន បានរាំងស្ទះដល់ការសម្រេចបាន នូវសក្ដានុពលនៃហេដ្ឋារចនាសម្ព័ន្ធដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស។ បញ្ហាផ្សេងៗ ដូចជា យានយន្តចាស់ហួសសម័យ និងនីតិវិធីគយ បានបង្កើនរយៈពេល និងបន្ទុកចំណាយ លើការនាំចេញរបស់កម្ពុជា។ នេះជាឧបសគ្គដ៏ធំមួយដល់ការអភិវឌ្ឍ SMEs ដែលត្រូវការច្រកចេញចូលទៅកាន់ទីផ្សារពិភពលោកមានសន្ទុះល្អ អាចទុកចិត្តបាន និងមានតម្លៃសមរម្យ។ ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទំនើប អាចដោះស្រាយតម្រូវការនេះបាន។ ការកែសម្រួលតម្រឹមនីតិវិធីគយ ការអនុវត្តច្បាប់ និងបទបញ្ញត្តិដែលច្បាស់លាស់ និងការកសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ត្រួតពិនិត្យទំនិញ មុនពេលទៅដល់ព្រំដែន (ឧ. កន្លែងត្រួតពិនិត្យទំនិញផ្លូវគោក) អាចបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា នៅក្នុងទីផ្សារពិភពលោក។ សមត្ថភាពមានកម្រិតនៃ វិស័យដឹកជញ្ជូនឆ្លងកាត់ព្រំដែនដែលចាស់ហួសសម័យ ក៏ធ្វើឲ្យកម្ពុជាថយចុះសមត្ថភាពប្រកួតប្រជែងក្នុងការនាំចេញដែរ។ ស្ដង់ដារយានយន្តកម្រិតទាប និងកង្វះវិនិយោគ បង្កបន្ទុកចំណាយខ្ពស់ក្នុងការដឹកជញ្ជូនទំនិញគិតក្នុង ១គីឡូក្រាម ភាពមិនប្រាកដប្រជាលើរយៈពេល និងសុវត្ថិភាពនៃការបញ្ជូនទំនិញ។ ដូច្នេះ ត្រូវមានបទបញ្ញត្តិជម្រុញការប្រកួតប្រជែងក្នុងផ្នែកដឹកជញ្ជូន ដើម្បីលើកទឹកចិត្តប្រតិបត្តិករឲ្យបង្កើនស្ដង់ដារគុណភាពនៃការដឹកជញ្ជូន។

ផលិតផលកម្មន្តសាល បានកើនឡើង ហើយលំនាំនៃចំណាយប្រើប្រាស់ បានប្រែប្រួលស្របតាមកំណើនសេដ្ឋកិច្ច ដែលនាំឲ្យតម្រូវការអគ្គិសនីកើនឡើងយ៉ាងខ្លាំង។ កំណើនដ៏ខ្ពស់ក្នុងការប្រើប្រាស់អគ្គិសនី (១៩% គិតនៅក្នុងកម្ពុជាទាំងមូល និង ២៥% នៅភ្នំពេញ) បង្ហាញពីតម្រូវការអភិវឌ្ឍសមត្ថភាពផ្គត់ផ្គង់អគ្គិសនីដើម្បីតាមឲ្យទាន់តម្រូវការនាពេលអនាគត។ ដើម្បីបំពេញតម្រូវការបច្ចុប្បន្ន និងទៅអនាគត រដ្ឋាភិបាលបានកំណត់ចំណុចសំខាន់៣ ដែលត្រូវយកចិត្តទុកដាក់ខាងគោលនយោបាយៈ ទី១ ដោយសារកម្ពុជាត្រូវនាំចូលថាមពលអគ្គិសនី ៤២% ពីបរទេស ដូច្នេះត្រូវបន្តអនុវត្តគោលនយោបាយ ក្របខ័ណ្ឌស្ថាប័ន និងបទបញ្ញត្តិ ព្រមទាំងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដើម្បីធានាឲ្យមានថាមពលនាំចូលតម្លៃថោក និងផ្គត់ផ្គង់ទៀងទាត់ក្នុងរយៈពេលខ្លី។

ទី២ ត្រូវមានធ្វើវិនិយោគយ៉ាងសកម្មក្នុងផ្នែកវារីអគ្គិសនី ដើម្បីប្រើប្រាស់សក្ដានុពលដ៏ធំធេងនៃផ្លូវទឹកនៅកម្ពុជា ក្នុងការផ្ដល់ថាមពលអគ្គិសនី។ ជាយុទ្ធសាស្ត្ររយៈពេលមធ្យម និងរយៈពេលវែង គឺត្រូវអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដើម្បីទាញយកផលពីសម្បត្តិធម្មជាតិដ៏ស្តុកស្តម្ភដែលតាមការប៉ាន់ស្មាន មានសក្ដានុពលអាចផ្ដល់ថាមពលវារីអគ្គិសនី ដល់ទៅ ១០.០០០ មេហ្គាវ៉ាត់ និងដែលបច្ចុប្បន្នផ្ដល់បានតែ ៣% នៃអគ្គិសនីប្រើប្រាស់ប៉ុណ្ណោះ។ សព្វថ្ងៃ កម្ពុជាមានផែនការដ៏ធំមួយ ដើម្បីបង្កើនសមត្ថភាពវារីអគ្គិសនី ហើយក្នុងរយៈពេលវែងសង្ឃឹមថានឹងអាចទទួលបានចំណូលពីការនាំចេញថាមពលទៅប្រទេសជិតខាងក្នុងមហាអនុតំបន់មេគង្គ (GSM)។

ទី៣ ការផ្គត់ផ្គង់អគ្គិសនី ត្រូវពង្រីកឲ្យហួសពីតំបន់មានប្រជាជនកុះករ ទៅដល់ជនបទកម្ពុជា។ សកម្មភាពនេះ នឹងជួយលើកកម្ពស់កម្រិតជីវភាព និងបង្កើនផលិតភាពកសិកម្ម។ រដ្ឋាភិបាល បានដាក់ចេញនូវគោលដៅប្រកបដោយមហិច្ឆតាមួយចំនួន ដើម្បីដោះស្រាយបញ្ហាភ្ជាប់បណ្ដាញអគ្គិសនីនៅជនបទ ពោលគឺត្រឹមឆ្នាំ២០៣០ គេសង្ឃឹមថា គ្រួសារនៅជនបទប្រមាណ ៧០% ទទួលបានការផ្គត់ផ្គង់អគ្គិសនីប្រកបដោយគុណភាព និងត្រឹមឆ្នាំ២០២០ គ្រប់ភូមិទាំងអស់ត្រូវទទួលបានសេវាកម្មអគ្គិសនី។ ដើម្បីសម្រេចគោលដៅនេះ រដ្ឋាភិបាលត្រូវបង្កើនប្រវែងខ្សែកាបបញ្ជូនចរន្តអគ្គិសនី ឲ្យបានវែងជាង ២១០០គីឡូម៉ែត្រត្រឹមឆ្នាំ២០២០ ដោយគ្រោងចំណាយថវិកាអស់ ៥០០លានដុល្លារក្នុង៥ឆ្នាំខាងមុខ។

នាបច្ចុប្បន្ន រដ្ឋាភិបាលក៏កំពុងដោះស្រាយបញ្ហាមួយចំនួនពាក់ព័ន្ធនឹងច្រើនវិស័យ ដែលជាផ្នែកមួយនៃក្របខ័ណ្ឌគោលនយោបាយថាមពលរួម។ បញ្ហាសំខាន់បំផុត គឺត្រូវចាត់វិធានការដើម្បីធានាឲ្យការផ្គត់ផ្គង់ និងប្រភពថាមពលនាពេលអនាគត មានចីរភាពខាងសេដ្ឋកិច្ចផង និងមានចីរភាពខាងសង្គម និងបរិស្ថានផង។ រដ្ឋាភិបាលត្រូវព្យាយាមលើកទឹកចិត្តឲ្យមានការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថានដោយសារការប្រើប្រាស់ថាមពល។ ម្យ៉ាងទៀត ត្រូវបង្កើនការស្រាវជ្រាវពីផលប៉ះពាល់ខាងសេដ្ឋកិច្ច-សង្គមកិច្ច និងបរិស្ថាន នៃការផ្គត់ផ្គង់ និងការប្រើប្រាស់ថាមពល និងប្រសិទ្ធភាពគោលនយោបាយពាក់ព័ន្ធ ហើយផ្ដល់ទៅជូនរដ្ឋាភិបាល ដើម្បីពិចារណាដាក់បញ្ចូលទៅក្នុងគោលនយោបាយនាពេលអនាគត។

*តទៅទំព័រ ១១*

# ការវិវត្តថ្មីៗក្នុងកិច្ចដំណើរការកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រុង ស្រុក ខណ្ឌ នៅកម្ពុជា[១]

ផែនការអនុវត្តរយៈពេល៣ឆ្នាំដំបូង (ផអ៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាល បានកំណត់ថា ថ្នាក់ក្រុង ស្រុក និងខណ្ឌ ជាថ្នាក់រដ្ឋបាលដ៏សំខាន់សម្រាប់ជួយលើកកម្ពស់ការផ្តល់សេវា ការសហការ និងការគាំទ្រដល់ថ្នាក់ឃុំ សង្កាត់។ សេចក្តីនេះ ជាការរំពឹងទុកមួយយ៉ាងធំចំពោះថ្នាក់រដ្ឋបាល ក្នុងខណៈដែលមុនការបោះឆ្នោតបង្កើតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នាឆ្នាំ២០០៩ គឺគ្រាន់តែដើរតួនាទីជា ការិយាល័យរដ្ឋបាលមួយរបស់ថ្នាក់រាជធានីខេត្ត ប៉ុណ្ណោះ។ ដើម្បីសម្រេចបានតាមការរំពឹងទុកនេះ ផអ៣ បានផ្តោតការយកចិត្តទុកដាក់ទៅលើការរៀបចំបង្កើត និងការអភិវឌ្ឍនូវរដ្ឋបាលប្រកបដោយប្រសិទ្ធភាពនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។ ដើម្បីជាជំនួយស្មារតីដល់ការស្វែងយល់ពីកំណែទម្រង់ដ៏សំខាន់នេះ ក្នុងអត្ថបទមានការពិភាក្សាត្រួសៗលើទិដ្ឋភាពគោលនយោបាយសំខាន់ៗដែលបានដាក់ចេញសម្រាប់ថ្នាក់ក្រុង ស្រុក ខណ្ឌ និងបង្ហាញពីសកម្មភាពដែលក្រុង ស្រុក ខណ្ឌ បានអនុវត្ត បន្ទាប់ពីការបោះឆ្នោតបង្កើតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ក្នុងឆ្នាំ២០០៩។

## ១. គោលនយោបាយសំខាន់ៗសម្រាប់ថ្នាក់ក្រុង ស្រុក ខណ្ឌ

ក្រោមក្របខ័ណ្ឌនៃ ផអ៣ ប្រព័ន្ធអភិបាលកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបែងចែកជា ២ប្រភេទគឺ ១) ប្រព័ន្ធអភិបាលកិច្ច និងរដ្ឋបាលខេត្ត ដែលមានតួនាទីសំខាន់តំណាងឱ្យរដ្ឋបាលថ្នាក់ជាតិ ក្នុងការសម្របសម្រួល ការគាំទ្រ និងការត្រួតពិនិត្យនីត្យានុកូលភាព និង ២) ប្រព័ន្ធអភិបាលកិច្ច និងរដ្ឋបាលមូលដ្ឋាន មានជាអាទិ៍ រាជធានី ក្រុង ស្រុក ខណ្ឌ ព្រមទាំងឃុំ/សង្កាត់ ដែលមានតួនាទីសំខាន់ក្នុងការបង្កើត ជម្រុញ និងធានាចីរភាពនៃការផ្តល់សេវា និងអភិវឌ្ឍន៍មូលដ្ឋាន។ រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សាមួយដែលជ្រើសតាំងឡើងតាមការបោះឆ្នោតអសាកល និងគណៈអភិបាលមួយដែលរាជរដ្ឋាភិបាលបានតែងតាំងឡើង[២]។ គណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលផង និងក្រុមប្រឹក្សាផង[៣]។ នៅទីជនបទ ក្រុមប្រឹក្សាស្រុកត្រូវមានគណនេយ្យភាពចំពោះថ្នាក់ឃុំ សង្កាត់ ហើយនៅទីប្រជុំជន ក្រុមប្រឹក្សាក្រុងត្រូវមានគណនេយ្យភាពចំពោះសង្កាត់ផង និងត្រូវត្រួតពិនិត្យ និងធ្វើប្រតិភូកម្មការងារនិងធនធានទៅឱ្យសង្កាត់ផង[៤]។

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ចាំបាច់ត្រូវរៀបចំបង្កើតឱ្យមានគណៈកម្មាធិការពិគ្រោះយោបល់ចំនួន ៣ គឺគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ និងគណៈកម្មាធិការលទ្ធកម្ម[៥]។ ជាទូទៅគណៈកម្មាធិការទាំងនេះ មានអភិបាលស្រុកជាប្រធាន និងមាននាយករដ្ឋបាល សមាជិកក្រុមប្រឹក្សា មន្ត្រីជំនាញ និងមេឃុំនិងចៅសង្កាត់មួយចំនួនជាសមាជិក។ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់យោបល់ដល់ក្រុមប្រឹក្សាអំពីផែនការអភិវឌ្ឍន៍ និងថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ការសម្របសម្រួលការងារបច្ចេកទេសជាមួយការិយាល័យជំនាញ (RGC 2009b; MoI 2010b) កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលជាមួយក្រុមប្រឹក្សាឃុំសង្កាត់និងអ្នកពាក់ព័ន្ធផ្សេងទៀត និងការចាត់វិធានការផ្សេងៗដើម្បីលើកកម្ពស់ការអនុវត្តមុខងារ និងធនធានរបស់ក្រុង ស្រុក ខណ្ឌ។

ក្នុងរយៈពេល១០ឆ្នាំខាងមុខ ថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយរួមសហការជាមួយថ្នាក់ឃុំ សង្កាត់ រំពឹងថានឹងក្លាយទៅជាថ្នាក់រដ្ឋបាលដ៏សកម្ម និងមានប្រសិទ្ធភាពខ្ពស់ ក្នុងការងារផ្តល់សេវាសាធារណៈចាំបាច់នានានៅមូលដ្ឋាន។ ដើម្បីសម្រេចបានគោលដៅនេះ ផអ៣ ក្នុងជំហានដំបូង បានផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាពរបស់ថ្នាក់ក្រុង ស្រុក ខណ្ឌដោយមាន គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ជួយដឹកនាំ និងដោយមានការចូលរួមពីក្រសួង ស្ថាប័នសំខាន់ៗ ដូចជា ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។ ការអភិវឌ្ឍសមត្ថភាពរបស់ក្រុង ស្រុក ខណ្ឌ ផ្តោតជាសំខាន់ទាំងលើការអភិវឌ្ឍធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាពស្ថាប័នពាក់ព័ន្ធទៅនឹងការរៀបចំ ការបង្កើត និងការពង្រឹងប្រព័ន្ធអភិបាលកិច្ចនិងគណនេយ្យភាព ប្រព័ន្ធផែនការប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រងកិច្ចការរដ្ឋបាល ប្រព័ន្ធតាមដានត្រួតពិនិត្យ វាយតម្លៃ និងរាយការណ៍ ដែលទាំងអស់

១ អត្ថបទនេះតាក់តែងឡើងដោយលោក ប៉ក់ គឹមជឿន លោកស្រី ធន់ វិមាលា និង លោក គ្រុយ វីរៈ ជាអ្នកស្រាវជ្រាវនៅ CDRI ។

២ មាត្រា ១៤ និង ១៤១ នៃច្បាប់អង្គការ

៣ មាត្រា ១៥៤ នៃច្បាប់អង្គការ

៤ មាត្រា ១០៦-១១៣ នៃច្បាប់អង្គការ

៥ មាត្រា ១៤៤ នៃច្បាប់អង្គការ

នេះ សុទ្ធតែជាសមាសធាតុសំខាន់ៗសម្រាប់ជម្រុញឱ្យថ្នាក់ក្រុង ស្រុក ខណ្ឌ មានសមត្ថភាពប្រសើរជាងមុន ក្នុងការងារអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន និងផ្ដល់ការគាំទ្រដល់ថ្នាក់ឃុំ/សង្កាត់ ប្រកបដោយប្រសិទ្ធភាព (NCDD 2010d; 2010e)។

ជាទិសដៅផ្នែកគោលនយោបាយ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស ហើយមុខងារទាំងនេះ ត្រូវមានក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួន។ ដើម្បីអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគទាំងនេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងត្រូវទទួលបាននូវថវិកាផ្ទេរពីថ្នាក់ជាតិ និងថវិកាប្រមូលបានពីមូលដ្ឋានផ្ទាល់របស់ខ្លួន (NCDD 2010e)។ ប៉ុន្តែ ដូចមានបង្ហាញលម្អិតនៅផ្នែកខាងក្រោយ ទាំងអស់នេះ កំពុងស្ថិតនៅជាផែនការ ដែលតម្រូវឱ្យមានការគិតគូរ និងខិតខំអនុវត្តជាដំណាក់កាលៗ ទើបអាចសម្រេចបាន។

ថ្នាក់ក្រោមជាតិ ក៏ត្រូវរៀបចំឱ្យមានផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ដើម្បីបង្ហាញពីចក្ខុវិស័យ និងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍរយៈពេលវែង រយៈពេលមធ្យម និងរយៈពេលខ្លី និងការកំណត់អាទិភាពសម្រាប់កិច្ចការអភិវឌ្ឍនៅតាមមូលដ្ឋានរបស់ខ្លួន។ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ក្រុង ស្រុក ខណ្ឌ គឺជាលក្ខខណ្ឌចាំបាច់ ដើម្បីទទួលបានធនធាន ពោលគឺ ត្រូវមានផែនការ ទើបមានថវិកា (RGC 2009c; NCDD 2010b)។ វិធានលម្អិតទាក់ទងនឹងការងារថវិកាមានចែងនៅក្នុងច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបទបញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត[៦]។

## ២. សកម្មភាពអភិវឌ្ឍន៍ និងការអភិវឌ្ឍសមត្ថភាពដែលក្រុង ស្រុក ខណ្ឌបានអនុវត្តកន្លងមក

យោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងយោងតាមស្ថានភាពទន់ខ្សោយរបស់ថ្នាក់ក្រុង ស្រុក ខណ្ឌ នៅមុនការបោះឆ្នោតបង្កើតក្រុមប្រឹក្សានាខែឧសភា ២០០៩ នោះ គេឃើញថាការអភិវឌ្ឍសមត្ថភាពរបស់ថ្នាក់នេះ ត្រូវការកិច្ចខិតខំប្រឹងប្រែង និងចំណាយធនធានជាច្រើន។ ទោះជាយ៉ាងនេះក្តី ក៏មិនគួរភ្លេចដែរថា ក្នុងពេលកន្លងមក ក្រុង ស្រុក ខណ្ឌមួយចំនួន ធ្លាប់បានទទួលការគាំទ្រ និងចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ និងគម្រោងកសាងសមត្ថភាពផ្សេងៗ សំដៅពង្រឹងតួនាទីក្រុង ស្រុក ខណ្ឌ ដើម្បីចូលរួមក្នុងការងារអភិវឌ្ឍន៍ និងឆ្លើយតបចំពោះតម្រូវការរបស់ឃុំ/សង្កាត់ និងប្រជាពលរដ្ឋមូលដ្ឋាន។ ខាងក្រោមនេះ គឺជាគម្រោង ៣សំខាន់ៗដែលធ្លាប់បានអនុវត្តលើទិដ្ឋភាពផ្សេងៗគ្នានៅថ្នាក់ក្រុង ស្រុក និងខណ្ឌមួយចំនួន ក្នុងពេលកន្លងមក[៧]។

### *កម្មវិធីសាកល្បងពង្រឹងតួនាទីថ្នាក់ស្រុក*

កម្មវិធីនេះ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៦ ដោយមានការគាំទ្រពី គម្រោងគាំទ្រការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (PSDD) និង គម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅ (NRMLP) គាំទ្រដោយរដ្ឋាភិបាលដាណឺម៉ាក ដែលសំដៅចូលរួមចំណែកពង្រឹងរចនាសម្ព័ន្ធ តួនាទី ការអភិវឌ្ឍសមត្ថភាពមន្ត្រីថ្នាក់ស្រុក និងជម្រុញឱ្យមានការផ្ទេរជាបណ្តើរៗទៅឱ្យថ្នាក់ស្រុកនូវ តួនាទី និងសិទ្ធិអំណាចក្នុងការប្រើប្រាស់ និងគ្រប់គ្រងថវិកា (NCDD 2007; NCDD 2009; Mekong Think Tank 2010)។ គិតត្រឹមឆ្នាំ២០១០ កម្មវិធីនេះមាន ១០៦ស្រុកចូលរួម ដោយស្រុកនីមួយៗទទួលបានថវិកាពី ២-៣ម៉ឺនដុល្លារអាមេរិកក្នុងមួយឆ្នាំ សម្រាប់ការរៀបចំ និងអនុវត្តគម្រោង ដែលមានលក្ខណៈអន្តរឃុំនៅក្នុងដែនដីរបស់ខ្លួន។ ចាប់តាំងពីពេលបង្កើតកម្មវិធីនេះមក ជាសរុបមាន ២៣៣៩គម្រោង មានតម្លៃ ១០,៣លានដុល្លារ ដែលត្រូវបានរៀបចំ និងអនុវត្តក្នុងវិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធជនបទ ធារាសាស្ត្រ ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ នៅតាមស្រុកគោលដៅទាំងនេះ គេបានរៀបចំឱ្យមានមន្ត្រីបង្គោលសម្រាប់ធ្វើការត្រួតពិនិត្យ តាមដាន វាយតម្លៃ និងប្រមូលទិន្នន័យ ទាក់ទងនឹងការរីកចម្រើន និងបញ្ហាប្រឈមនានាដែលកើតមានឡើង (MoI 2010a)។

តាមរយៈគណៈកម្មាធិការអភិវឌ្ឍន៍ស្រុក (គអស) កម្មវិធីនេះ បានបង្រៀនឱ្យថ្នាក់ស្រុកចេះសហការជាមួយឃុំ សង្កាត់ ក្នុងការជ្រើសរើស ធ្វើផែនការ និងអនុវត្តគម្រោងអន្តរឃុំ និងបានជម្រុញឱ្យមានការចូលរួមពីមន្ត្រីជំនាញ សំដៅពង្រឹងគណនេយ្យភាព និងការសហការតាមខ្សែទទឹងនៅថ្នាក់ស្រុក។ សរុបមក កម្មវិធីនេះជាបទពិសោធន៍ដ៏ល្អមួយសម្រាប់ឱ្យថ្នាក់ស្រុក ត្រៀមខ្លួនក្នុងការកសាងផែនការអភិវឌ្ឍន៍ និងគ្រប់គ្រងថវិកាផ្ទាល់ ដែលពួកគេរំពឹងថា នឹងទទួលបានក្នុងពេលឆាប់ៗខាងមុខ[៨]។

### *គម្រោងគែលម្អរដ្ឋបាលមូលដ្ឋាននៅកម្ពុជា (ហៅកាត់ថា PILAC)*

PILAC ជាគម្រោងមួយដែលក្រសួងមហាផ្ទៃបានបង្កើតឡើងនៅឆ្នាំ២០០៧ ដោយមានការគាំទ្រពីទីភ្នាក់ងារជំនួយរបស់ប្រទេសជប៉ុន ដើម្បីជួយទ្រទ្រង់ដល់ការកសាងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសថ្នាក់ស្រុក និងខេត្ត ខាងផ្នែកគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ គម្រោងនេះ មានគោលដៅរយៈពេលវែង បង្កើតជាប្រព័ន្ធគ្រប់គ្រងធនធានមនុស្សប្រកបដោយប្រសិទ្ធភាពមួយនៅថ្នាក់ក្រោមជាតិ ដោយយោងតាមស្មារតីនៃច្បាប់រៀបចំអង្គការ។ ដើម្បីសម្រេចនូវគោលដៅទាំងនេះ គម្រោងបានជួយបណ្តុះបណ្តាលគ្រូបង្គោល

---

៦ យោងតាមបទសម្ភាសន៍ថ្ងៃទី១៨ ឧសភា ២០១១ ជាមួយមន្ត្រីជាន់ខ្ពស់ នៃលេខាធិការដ្ឋានរបស់ គជអប។

៧ ក្រៅពីគម្រោងទាំង ៣ នេះ គម្រោងផ្សេងទៀតក៏បានចូលរួមចំណែកដល់ការកសាងសមត្ថភាពរបស់ថ្នាក់ស្រុកដែរ ដូចជា គម្រោង Inter-Communal Cooperation (ICC) និង គម្រោង Cambodian Criminal Justice Assistance Project (CCJAPIII) ជាដើម។

៨ យោងតាមបទសម្ភាសន៍នៅថ្ងៃទី១៨ ឧសភា ២០១១ ជាមួយមន្ត្រីជាន់ខ្ពស់នៃលេខាធិការដ្ឋានរបស់ គជអប។

ថ្នាក់ជាតិ ដែលបានធ្វើការបណ្តុះបណ្តាល និងចែករំលែកបន្តដល់មន្ត្រីថ្នាក់ក្រោមជាតិ តាមរយៈសិក្ខាសាលាមួយចំនួន។ គម្រោងក៏បានរៀបចំឱ្យមានការសិក្សាផ្សេងៗ សំដៅចងក្រងឯកសារ អំពីស្ថានភាព និងបញ្ហាប្រឈមដែលកើតមានឡើងជាក់ស្តែងទាក់ទងនឹង ការកសាងសមត្ថភាពនៅថ្នាក់ក្រោមជាតិ (MoI 2008a; MoI 2008b)។ ឯកសារ និងធនធានមនុស្សទាំងនេះ នឹងជួយជាទុនសម្រាប់រដ្ឋបាលថ្នាក់ស្រុក ក្នុងការកសាងផែនការអភិវឌ្ឍន៍មូលដ្ឋាន និងការគាំទ្រដល់រដ្ឋបាលឃុំ/សង្កាត់របស់ខ្លួន។

### *គម្រោងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ*

គម្រោងនេះ ចាប់ផ្តើមនៅឆ្នាំ២០០៥ នៅក្រុងគោលដៅចំនួន២ គឺក្រុងបាត់ដំបង និងក្រុងសៀមរាប ដោយមានការគាំទ្រពីមូលនិធិខុនរ៉ាតអាដេណូអ៊ែ និងសហគមន៍អឺរ៉ុប ដើម្បីសាកល្បងធ្វើឱ្យថ្នាក់ក្រុងមានតួនាទីសកម្មជាងមុន ក្នុងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាពដល់ប្រជាជន តាមរយៈការបង្កើតការិយាល័យច្រកចេញចូលតែមួយ។ ផ្អែកលើបទពិសោធន៍ និងលទ្ធផលវិជ្ជមាននៃការអនុវត្តគម្រោងសាកល្បងនេះ ធនាគារពិភពលោកបានផ្តល់ហិរញ្ញប្បទានដល់រាជរដ្ឋាភិបាល តាមរយៈគម្រោងពង្រឹងអភិបាលកិច្ចមូលដ្ឋាន (DFGG) ដើម្បីពង្រីកសកម្មភាពបង្កើតការិយាល័យច្រកចេញចូលតែមួយ នៅតាមក្រុង ស្រុកគោលដៅមួយចំនួនផ្សេងទៀត។ មកទល់បច្ចុប្បន្ន គម្រោងនេះបានពង្រីកដល់ក្រុងចំនួន ៦ គឺមាន ក្រុងតាខ្មៅ ក្រុងព្រះសីហនុ ក្រុងប៉ោយប៉ែត ក្រុងស្ទឹងសែន ក្រុងសួង ក្រុងក្រចេះ និងដល់ស្រុក ១ គឺ ស្រុកពាមរ (NCDD 2010a)។

តាមរយៈគម្រោងខាងលើ ក្រុង និងស្រុកគោលដៅ បានបង្កើតជាក្របខ័ណ្ឌអនុវត្តគោលនយោបាយមួយ ដែលក្នុងនោះមុខងារផ្តល់សេវាត្រូវបានផ្ទេរពីក្រសួងស្ថាប័នជំនាញចំនួន ៦ វិស័យទៅឱ្យក្រុង និងស្រុកគោលដៅ (RGC 2001)។ គម្រោងក៏បានជួយឲ្យមានការផ្លាស់ប្តូរឥរិយាបថរបស់មន្ត្រីមូលដ្ឋាន ពីអ្នកគ្រប់គ្រង មកជាអ្នកផ្តល់សេវាបម្រើប្រយោជន៍ប្រជាពលរដ្ឋវិញ។ ក្នុងពេលជាមួយគ្នា ប្រជាពលរដ្ឋក៏បានយល់ដឹង និងមានទំនុកចិត្តជាងមុនអំពីបែបបទក្នុងការស្វែងរក និងទទួលបានសេវាពីរដ្ឋអំណាចមូលដ្ឋាន។ លទ្ធផល និងបទពិសោធន៍បានពីគម្រោងអាចក្លាយជាមេរៀនដ៏ប្រសើរសម្រាប់ការរៀបចំគោលនយោបាយផ្ទេរមុខងារ និងវិសហមជ្ឈការតាមវិស័យ (NCDD 2010a; Thon *et al.* 2011)។

## ៣. របកគំហើញស្តីពីសកម្មភាពចាប់តាំងពីមានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

ផ្អែកលើលទ្ធផលនៃការចុះសាកសួរក្នុង ៤ស្រុក សកម្មភាពការងារដែលសម្រេចបាន ចាប់តាំងពីមានការបោះឆ្នោតជាអសាកលនៅខែឧសភា ២០០៩ ដើម្បីបង្កើតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានដូចតទៅ៖

### *សកម្មភាពកសាង និងដំណើរការស្ថាប័ន*

តាមការពិនិត្យជាទូទៅ ចាប់តាំងពីការបោះឆ្នោតឆ្នាំ២០០៩ មក ក្រុមប្រឹក្សាស្រុក មានសកម្មភាពតិចតួចណាស់ក្រៅពីការប្រជុំប្រចាំខែ និងការទទួលរបាយការណ៍ពីគណៈអភិបាល។ រឿងនេះ បង្កឡើងមួយផ្នែកដោយសាររដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅមិនទាន់មានផែនការអភិវឌ្ឍន៍ និងថវិកាសមស្របនៅឡើយ។ នៅពេលមានផែនការអភិវឌ្ឍន៍និងថវិកា ក្រុមប្រឹក្សានឹងមានសកម្មភាពជាច្រើនត្រូវបំពេញ។ ទោះជាយ៉ាងនេះក្តី ភាពសកម្មរបស់ក្រុមប្រឹក្សា ក៏អាស្រ័យទៅលើបុគ្គលិកលក្ខណៈរបស់ប្រធាន និងសមាជិកក្រុមប្រឹក្សាផងដែរ។ បច្ចុប្បន្ន ភាគច្រើននៃសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (លើសពី ៦៥% ក្នុងស្រុកទាំង៤ ដែលបានចុះសិក្សា) ស្ថិតក្នុងអាយុកាលចូលនិវត្តន៍។ ភាពចាស់ទុំរបស់ពួកគាត់ ជាគុណប្រយោជន៍ដ៏សំខាន់មួយ ព្រោះគាត់អាចនាំយកបទពិសោធន៍ការងារដ៏សម្បូរបែបរបស់ខ្លួន ទៅបម្រើការងាររបស់ក្រុមប្រឹក្សា ប៉ុន្តែក៏មានសមាជិកក្រុមប្រឹក្សាមួយចំនួនដែលអសកម្ម ឬមិនសូវស្វាហាប់ក្នុងការបំពេញការងារដែរ។

ចំណែកឥទ្ធិពលរបស់ប្រធានក្រុមប្រឹក្សាវិញ មួយផ្នែកអាស្រ័យលើមុខតំណែងពីអតីតកាល និងការជ្រើសតាំងបេក្ខភាពរបស់គាត់ក្នុងការបោះឆ្នោតឆ្នាំ២០០៩។ ក្នុងស្រុកបីដែលបានចុះសាកសួរ ប្រធានក្រុមប្រឹក្សាជាអតីតអភិបាលស្រុក ក្នុងស្រុកនោះផ្ទាល់ ឬមកពីស្រុកផ្សេង ហើយបេក្ខភាពរបស់គាត់ត្រូវបានផ្តួចផ្តើមឡើងដោយគណបក្សថ្នាក់ខេត្ត (សំដៅលើគណបក្សប្រជាជនកម្ពុជា)។ ក្នុងករណីនេះ ប្រធានក្រុមប្រឹក្សាហាក់មានឥទ្ធិពល និងទទួលបានការគោរពច្រើននៅក្នុងរដ្ឋបាលស្រុករបស់ខ្លួន។ នៅស្រុកមួយទៀត ប្រធានក្រុមប្រឹក្សាជាអតីតបុគ្គលិកចាស់ទុំក្នុងស្រុក រីឯបេក្ខភាពរបស់គាត់ត្រូវបានផ្តួចផ្តើមដោយសាខាបក្សស្រុក និងក្រោយមកមានការយល់ព្រមពីគណបក្សថ្នាក់ខេត្ត។ នៅក្នុងករណីនេះ ប្រធានក្រុមប្រឹក្សាហាក់មិនសូវមានឥទ្ធិពលទេ បើប្រៀបធៀបទៅនឹងអភិបាលស្រុក។

ចំពោះគណបក្សនយោបាយ (ជាពិសេសគណបក្សប្រជាជនកម្ពុជា) ភាពចាស់ទុំ និងភាពស្មោះត្រង់ គឺជាលក្ខខណ្ឌចម្បងក្នុងការតែងតាំងបេក្ខភាពសម្រាប់ធ្វើជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដោយសារហេតុផលពីរ៖ ទី១ ភាពចាស់ទុំ មានន័យថាមានបទពិសោធន៍ការងារច្រើន អាចជួយដល់ការងាររបស់ក្រុមប្រឹក្សា និង ទី២ ការគាំទ្រដល់បេក្ខជនដែលមានភាពចាស់ទុំ និងស្មោះត្រង់ចំពោះបក្ស គឺជាការផ្តល់រង្វាន់មួយ។ ចំពោះចំណុចនេះ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានការដឹងគុណយ៉ាងខ្លាំង។ គណបក្សផ្សេងៗទៀត ក៏មានការគិតគូរស្រដៀងគ្នាដែរ។ ក្នុងការសិក្សាបន្តទៀត គេគួរពិនិត្យលើកត្តាគណបក្សនយោបាយនេះក្នុងការកំណត់ពីបេក្ខភាព និងភាពសកម្មរបស់ក្រុមប្រឹក្សា ហើយនិងទំនាក់ទំនងរបស់ក្រុមប្រឹក្សា ជាមួយគណៈអភិបាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

ទោះបីមានក្រុមប្រឹក្សាក៏ដោយ ក៏ក្នុងអំឡុង ២ឆ្នាំកន្លងមកនេះ គណៈអភិបាល និងអភិបាលនៅតែមានសកម្មភាព និងឥទ្ធិពលច្រើនក្នុងការងារជាក់ស្តែង។ នាបច្ចុប្បន្ន គេឃើញមានមន្ត្រីវ័យក្មេងជាច្រើនត្រូវបានតែងតែងជាអភិបាល ឬជាអភិបាលរង។

ឧទាហរណ៍ ក្នុងខេត្តមួយនោះ អភិបាលស្រុកប្រមាណ ៨០% ត្រូវបានជំនួសដោយមន្ត្រីដែលមានអាយុតិចជាង ៤០ឆ្នាំ និងបានបញ្ចប់ការសិក្សាពីសាលាភូមិន្ទរដ្ឋបាល។ នៅអាណត្តិក្រោយនេះ គេរំពឹងថាអភិបាលស្រុកដែលបានបម្រើការ ១០-១៥ឆ្នាំមក ហើយនោះ នឹងដល់អាយុចូលនិវត្តន៍ ហើយត្រូវជំនួសដោយមន្ត្រីជំនាន់ក្រោយ[៩]។

ក្រុមប្រឹក្សាស្រុកបានបង្កើតគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារ (MoI 2009) និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស (RGC 2009b) រួចហើយ ប៉ុន្តែមិនទាន់បានបង្កើតគណៈកម្មាធិការលទ្ធកម្មទេ ដោយសារមិនទាន់ទទួលបានការណែនាំលម្អិតស្តីពីការរៀបចំបង្កើតគណៈកម្មាធិការនេះ។ ការប្រកាន់និន្នាការគណបក្សនយោបាយ មិនត្រូវបានពិនិត្យឃើញទេក្នុងការរៀបចំគណៈកម្មាធិការពិគ្រោះយោបល់នានា ប៉ុន្តែចំណុចនេះគួរធ្វើការសិក្សាបន្ថែមក្នុងក្រុង ស្រុក ផ្សេងៗទៀត។

ចំណែកខាងរដ្ឋបាលស្រុកវិញ គេក៏ឃើញមានការផ្លាស់ប្តូរមន្ត្រីពីមន្ទីរស្រុកទៅជានាយករដ្ឋបាលស្រុកចំនួនមួយរូប និងនាយករងចំនួនពីររូប។ ក្នុងនោះក៏មានការបង្កើតនូវការិយាល័យចំណុះចំនួន៣ គឺមាន ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ ការិយាល័យផែនការនិងគាំទ្រឃុំ/សង្កាត់ និងការិយាល័យអន្តរវិស័យ។ ក្រោមក្របខ័ណ្ឌនៃ ផអ៣ មានការជ្រើសរើស និងតែងតាំងទីប្រឹក្សាថ្នាក់ស្រុក ដើម្បីជួយគាំទ្រលើការអភិវឌ្ឍសមត្ថភាព និងសម្របសម្រួលសកម្មភាពអភិវឌ្ឍន៍នានា ហើយក៏ប្រហែលជាអាចមានការគិតគូររៀបចំឱ្យមាន មន្ត្រីជំនួយផ្នែកបច្ចេកទេសនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ផងដែរ[១០]។

បញ្ហាប្រឈមសម្រាប់រដ្ឋបាលស្រុកនាបច្ចុប្បន្ន គឺកង្វះសមត្ថភាពរបស់បុគ្គលិក និងកង្វះការសហការពីការិយាល័យជំនាញ។ ឧទាហរណ៍ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ក្រុង ស្រុក ខណ្ឌ ត្រូវពឹងលើជំនួយពីមន្ត្រីសម្របសម្រួលថ្នាក់ស្រុក រួមជាមួយនឹងសមាជិកក្រុមប្រឹក្សាមួយចំនួនដែលមានបទពិសោធន៍លើការងារនេះ ដើម្បីជួយបុគ្គលិករបស់ខ្លួន ដែលមិនសូវមានបទពិសោធន៍លើការងាររៀបចំផែនការ។ ចំណែកឯមន្ត្រីនៃការិយាល័យជំនាញមួយចំនួនឯណោះវិញ គឺនៅតែបំពេញការងារតាមការបង្គាប់នៃខ្សែបណ្តោយ។

ភាពអសកម្ម និងកង្វះការសហការរបស់ការិយាល័យជំនាញ បណ្តាលមកពីបៀវត្សរ៍តិចតួច និងបញ្ហាពុំទាន់មានការផ្ទេរមុខងារតាមវិស័យ និងធនធានតាមវិស័យឱ្យបានច្បាស់លាស់។ សំខាន់ជាងនេះទៀត ការចូលរួមរបស់ការិយាល័យខ្សែបណ្តោយមិនមែនទាមទារត្រឹមតែការផ្លាស់ប្តូររបៀបរបបធ្វើការនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានគោលនយោបាយថ្នាក់ជាតិមួយច្បាស់លាស់សម្រាប់ការផ្ទេរមុខងារ និងធនធាន។

## ការកសាងផែនការអភិវឌ្ឍន៍ និងរៀបចំថវិកា

ក្នុងរយៈពេល២ឆ្នាំកន្លងមក រដ្ឋាភិបាលបានរៀបចំលិខិតបទដ្ឋានគតិយុត្តិ និងសេចក្តីណែនាំបច្ចេកទេសនានាទាក់ទងនឹងដំណើរការកសាងផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ព្រមទាំងបានរៀបចំវគ្គបណ្តុះបណ្តាលមួយចំនួន ទាក់ទងនឹងការងារនេះ (NCDD 2011)។ គិតត្រឹមចុងខែឧសភា ២០១១ ស្រុកដែលយើងចុះទៅសាកសួរ ទើបតែបានបញ្ចប់ការងារកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ការអភិវឌ្ឍនៅតាមកន្លែងនីមួយៗ។ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគនេះ នឹងត្រូវដាក់ឲ្យអនុវត្តយ៉ាងពេញលេញនៅពេលដែលស្រុកទទួលបាននូវមូលនិធិក្រុង ស្រុក ដែលគេរំពឹងថានឹងមានបង្កើតឡើងនាពេលឆាប់ៗ[១១]។

ជាសង្ខេប ផែនការអភិវឌ្ឍន៍៥ឆ្នាំ ផ្តល់ជាទិសដៅសម្រាប់រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ ធ្វើការអភិវឌ្ឍក្នុងរយៈពេល៥ឆ្នាំ រីឯកម្មវិធីវិនិយោគ៣ឆ្នាំរំកិល បង្ហាញពីសកម្មភាព និងគម្រោងជាក់ស្តែងដែលត្រូវធ្វើជារៀងរាល់ឆ្នាំ (RGC 2009c)។ ក្នុងការកសាងផែនការទាំងនេះ ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតក្រុមការងារមួយដែលរួមមានអភិបាលស្រុក ក្រុង អភិបាលរង នាយករដ្ឋបាល និងប្រធានការិយាល័យផែនការនិងគាំទ្រឃុំ/សង្កាត់ ប្រធាន ឬតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ប្រធានការិយាល័យជំនាញពាក់ព័ន្ធ និងមន្ត្រីពាក់ព័ន្ធផ្សេងៗទៀត។ នៅពេលកសាងរួច ក្រុមការងារត្រូវដាក់សេចក្តីព្រាងផែនការអភិវឌ្ឍន៍ជូនទៅគណៈអភិបាល និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីពិនិត្យ និងផ្តល់យោបល់ មុននឹងដាក់ជូនក្រុមប្រឹក្សាធ្វើការពិភាក្សា និងអនុម័ត។ ផែនការអនុម័តដោយក្រុមប្រឹក្សា ត្រូវផ្ញើទៅជូនអភិបាលខេត្តដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។ ផែនការដែលអនុម័តរួចរាល់ហើយ គឺក្លាយជាឯកសារផ្លូវការ ហើយអាចដាក់ឱ្យសាធារណជនត្រួតពិនិត្យបាន (MoI 2010c)។

ផែនការអភិវឌ្ឍន៍ថ្នាក់ក្រុង ស្រុក ខណ្ឌ ពឹងលើទិន្នន័យបានមកពី ១) ឃុំ/សង្កាត់ ២) ការិយាល័យជំនាញ ៣) អង្គការមិនមែនរដ្ឋាភិបាល និង ៤) វិស័យឯកជន។ ក្រុង ស្រុក ខណ្ឌ ត្រូវសង្ខេប ធ្វើសំយោគ និងកំណត់អាទិភាពនៃសកម្មភាពដែលបានលើកឡើងទាំងនេះ (NCDD 2010c)។ មន្ត្រីស្រុកបានលើកឡើងថា ពួកគាត់មានការងាយស្រួលក្នុងការប្រមូល និងធ្វើសំយោគលើសំណើរបស់ឃុំ/សង្កាត់ ព្រោះមានបទពិសោធន៍ធ្វើការងារជាច្រើនជាមួយឃុំ/សង្កាត់ ក្នុងពេលកន្លងមក។ ប៉ុន្តែការិយាល័យជំនាញ កំពុងជួបបញ្ហាប្រឈមក្នុងដំណើរការនេះ ព្រោះពុំសូវមានបទពិសោធន៍ក្នុងការកសាងផែនការ ដែលត្រូវយកមកបូកសរុបនៅថ្នាក់ស្រុក ដោយធ្លាប់តែកសាងផែនការក្នុងវិស័យរបស់ខ្លួនផ្ទាល់។

៩ កិច្ចសម្ភាសន៍ជាមួយអភិបាលស្រុក (ថ្ងៃទី៣ ឧសភា ២០១១)

១០ ibid

១១ នេះជាការរំពឹងទុករបស់អភិបាលស្រុក និងសមាជិកក្រុមប្រឹក្សាដែលបានឆ្លើយសម្ភាសន៍។ បទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗនៅថ្នាក់ជាតិ (ថ្ងៃទី១៨ មិថុនា ២០១១) បានបង្ហាញពីភាពមិនច្បាស់លាស់នៃកាលវេលាដែលមូលនិធិស្រុក ក្រុង ត្រូវបង្កើតឡើង និងផ្ទេរ។

មន្ត្រីស្រុក ដែលក្រុមស្រាវជ្រាវធ្លាប់ជួបសំណេះសំណាល បានប្រាប់ថា បទពិសោធន៍ជាមួយនឹងកម្មវិធីសាកល្បងពង្រឹងតួនាទីថ្នាក់ស្រុក បានជួយឱ្យពួកគេងាយស្រួលកំណត់អាទិភាពរបស់ឃុំ/សង្កាត់ (ឧទាហរណ៍ គម្រោងអន្តរឃុំ) ហើយបំប្លែងតម្រូវការទាំងនោះ ឱ្យមកជាអាទិភាពរបស់ស្រុក។ ទិន្នន័យស្ដីពីស្ថានភាពអភិវឌ្ឍន៍មូលដ្ឋាន ដែលត្រូវបានចងក្រងឡើងសម្រាប់ការងាររបស់ឃុំ កន្លងមក មានប្រយោជន៍ខ្លាំងណាស់សម្រាប់ការវិភាគពីស្ថានភាពអភិវឌ្ឍន៍ក្នុងស្រុក។ ប៉ុន្តែពួកគេជួបការលំបាកក្នុងការទទួលបានទិន្នន័យពីអង្គការមិនមែនរដ្ឋាភិបាល និងសហគ្រាសឯកជន ដែលជាអ្នកផ្ដល់សេវាយ៉ាងសំខាន់នៅតាមមូលដ្ឋានស្រុកនីមួយៗ។ គេសង្ឃឹមថា ការកសាងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល នឹងមានការចូលរួមកាន់តែច្រើននៅឆ្នាំក្រោយពីសំណាក់តួអង្គមិនមែនរដ្ឋាភិបាលទាំងនេះ ។

## ៤. សេចក្ដីសន្និដ្ឋាន

តាមការពិនិត្យឃើញជាទូទៅ កំណែទម្រង់នៅថ្នាក់ក្រុង ស្រុក ខណ្ឌ នាបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលដំបូង និងមានសកម្មភាពតិចតួចនៅឡើយ បើប្រៀបធៀបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ដែលចង់ឱ្យថ្នាក់នេះមានសកម្មភាពខ្លាំងក្លាក្នុងការងារផ្ដល់សេវា និងអភិវឌ្ឍន៍មូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងចីរភាព។ ប៉ុន្តែយើងមិនគួរភ្លេចទេថា លទ្ធផលសម្រេចបាន គឺជាផ្លែផ្កាគួរឱ្យមានមោទនភាព បន្ទាប់ពីមានការខិតខំប្រឹងប្រែង ការពិភាក្សាពិគ្រោះយោបល់ និងការចរចាជាច្រើនឆ្នាំ ទាំងនៅកម្រិតបច្ចេកទេស និងកម្រិតនយោបាយ។ ជាការពិតណាស់ ការអភិវឌ្ឍសមត្ថភាពនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវការពេលវេលាច្រើន ប៉ុន្តែក៏ពុំមែនចាប់ផ្ដើមពីចំណុចសូន្យនោះដែរ ព្រោះកន្លងមកពួកគេធ្លាប់មានបទពិសោធន៍ និងធ្លាប់ទទួលបានការកសាងសមត្ថភាពពីគម្រោងសាកល្បងមួយចំនួនហើយ។ តាមរយៈគម្រោងទាំងនោះ ថ្នាក់ក្រុង ស្រុក ខណ្ឌ ធ្លាប់បានរៀនសូត្រ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ឃុំ សង្កាត់ និងបានរៀនអនុវត្ត និងគ្រប់គ្រងការងារអភិវឌ្ឍន៍ដែលមានការចូលរួម និងការអនុលោមតាមវិធានដ៏ច្បាស់លាស់។ ម៉្យាងទៀត ទោះបីជាការងារបច្ចេកទេស និងការងារគ្រប់គ្រង មានសារៈសំខាន់សម្រាប់ជម្រុញអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងការអភិវឌ្ឍនៅថ្នាក់មូលដ្ឋានយ៉ាងណាក៏ដោយ ក៏គេមិនត្រូវភ្លេចពីសារៈសំខាន់នៃកត្តានយោបាយ គណបក្សនយោបាយ និងការចូលរួមពីដៃគូមិនមែនរដ្ឋាភិបាល នៅក្នុងការងារនេះដែរ។

## ឯកសារយោង


Mekong Think Tank (2010), *Study of NCDD: Systems suitability for NRM in D&D implementation* (Phnom Penh: Mekong Think Tank)

Ministry of Interior (2009), *Prakas 4275 BRK on the Establishment and the Functioning of the Women's and Children's Consultative Committees at Capital, Provincial, Municipal, District and Khan Councils* (Phnom Penh: MoI)

Ministry of Interior (2010a), *National District Initiatives Project Report 2006-2010* (Phnom Penh: MoI)

Ministry of Interior (2010b), *Prakas no. 2417 on the preparation of the development plan and three year rolling plan of the capital, proivnces, municipalities, districts and khans* (Phnom Penh: MoI)

Ministry of Interior (2008a), *Situational Analysis 1 of Provincial/Municipal and Districts/Khans Administrations in Cambodia* (Phnom Penh: MoI)

Ministry of Interior (2008b), *Situational Analysis 2 of Provincial/Municipal and Districts/Khans Administrations in Cambodia* (Phnom Penh: MoI)

National Committee for Sub-national Democratic Development (2007), *Guideline for the Implementation of District Initiatives (DI)* (Phnom Penh: NCDD)

National Committee for Democratic Development (2010a), *Annual Progress Report for One Window Service Office and District Ombudsman (OWSO-DO)* (Phnom Penh: NCDD)

National Committee for Democratic Development (2010b), *National Capacity Development Framework for the 3-Year Implementation Plan (IP3)* (Phnom Penh: NCDD)

National Committee for Democratic Development (2010c), *Technical guideline on the preparation of the development plan and investment plan for municapalities, districts and khans* (Phnom Penh: NCDD)

National Committee for Democratic Development (2010d), *Outline of the First 3-Years Implementation Plan of the NP-SNDD* (Phnom Penh: NCDD)

National Committee for Democratic Development (2010e), *Implementation Plan First Three Years (2011-2013)* (Phnom Penh: NCDD)

National Committee for Democratic Development (2011), *A compilation of the key regulations and guidelines on the preparation of the development and investment program for the capital, provinces, municipalities, districts, and khan* (Phnom Penh: NCDD)

Royal Government of Cambodia (1994), *Law on General Status of Civil Servants of Cambodia* (Phnom Penh: RGC)

Royal Government of Cambodia (2001), *Council for Administrative Reform: Governance Action Plan* (Phnom Penh: RGC)

Royal Government of Cambodia (2008), *Law on Administrative Management of the Capital, Provinces, Municipalities, Districts and Khans* (Phnom Penh: RGC)

Royal Government of Cambodia (2009a), *Sub-decree 216 on Roles, Duties, and Working Relationship of the Provincial Council and Board of Governors, Municipal*

*Council and Board of Governors and District Council and Board of Governors* ( Phnom Penh: RGC )

Royal Government of Cambodia ( 2009b ), *Sub-decree no. 218 ank.bk on the Establishment, Organization and Functioning of the Technical Facilitation Committee of the Provincial, Municipal and District Council* ( Phnom Penh: RGC )

Royal Government of Cambodia ( 2009c ), *Sub-decree no. 219 ankr.bk on the development and 3 year rolling investment plan for the capital, provnices, municipalities, districts, and khans* ( Phnom Penh: RGC )

Thon, Vimealea, Heng Seiha, Kruy Virak & Ly Tem ( 2011 ), "Assessment of One Window Service Office and District Ombudsman Pilot Project", *Annual Development Review 2010-11* ( Phnom Penh: CDRI )

## *តពីទំព័រ ៥* ជម្រុញកំណើនសេដ្ឋកិច្ចខ្ពស់ ...

ក្រាហ្វិក ៣. ការប៉ាន់ស្មានពីការពង្រីកបណ្តាញចែកចាយថាមពល




ប្រភព៖ បទបង្ហាញក្នុងសន្និសីទចក្ខុវិស័យឆ្នាំ២០១១

### ការប្រមើលឃើញ និងអាទិភាព

សេដ្ឋកិច្ចកម្ពុជា បានងើបឡើងវិញល្អគួរឲ្យកត់សម្គាល់ពីការប៉ះទង្គិចដោយវិបត្តិសេដ្ឋកិច្ចសាកល។ កំណើនសេដ្ឋកិច្ច មានសន្ទុះខ្លាំង និងរំពឹងថានៅថេរក្នុងរយៈពេលពីរបីឆ្នាំខាងមុខ។ ប៉ុន្តែឥឡូវនេះ ត្រូវត្រៀមរៀបចំខ្លួនជាបន្ទាន់សម្រាប់រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីកសាងសេដ្ឋកិច្ចលើគ្រឹះដ៏រឹងមាំ ធ្វើពិពិធកម្មសេដ្ឋកិច្ច និងរៀបចំប្រទេសដើម្បីទទួលបានកំណើនខ្ពស់ ប្រកបដោយចីរភាព និងសមធម៌។ រាជរដ្ឋាភិបាលមានគោលគំនិតច្បាស់លាស់ពីបញ្ហាត្រូវប្រឈមមុខ និងមានឆន្ទៈចង់ដោះស្រាយ ចង់បំបាត់ឧបសគ្គ តាមការអនុវត្តគោលនយោបាយផ្តោតចំគោលដៅ និងមានការសម្របសម្រួល។ កង្វះសមត្ថភាពស្ថាប័ន បានរារាំងគោលនយោបាយមិនឲ្យសម្រេចបានតាមគោលដៅកំណត់ទុក ហើយវាជាឧបសគ្គដែលគេបានគូសបញ្ជាក់ជាច្រើនលើកក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១១។ ការយកចិត្តទុកដាក់របស់រដ្ឋាភិបាល ក្នុងការរៀបចំច្បាប់ បទបញ្ញត្តិ និងបង្កើតក្របខ័ណ្ឌគោលនយោបាយប្រកបដោយ គំនិតបែបថ្មី បានបើកចំហប្រទេសកម្ពុជា និងសម្រេចបានកំណើន និងវិបុលភាពកម្រិតខ្ពស់មិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រកម្ពុជា។ ប៉ុន្តែ ដើម្បីឲ្យកំណើននេះអាចបន្តទៅមុខ និងមានតម្លាភាព ស្ថាប័ននានាដែលបានកសាងឡើងលើគោលការណ៍អភិបាលកិច្ចល្អ ត្រូវអនុវត្តតាមគោលនយោបាយបានរៀបចំឡើង ដើម្បីជម្រុញកំណើនសេដ្ឋកិច្ចចម្រុះ ប្រកបដោយចីរភាព និងសមភាព។ ទោះបីតាមការបង្កើតបទបញ្ញត្តិគ្រប់គ្រងទីផ្សារឥណទាន ឬតាមការអនុវត្តកម្មវិធី TVET យ៉ាងសក្តិសិទ្ធិក្តី សមត្ថភាពស្ថាប័នសំខាន់ណាស់ក្នុងការធានាឲ្យមានការអនុវត្ត និងពង្រឹង គោលនយោបាយនានារបស់រដ្ឋាភិបាល និងការតាមដានលទ្ធផល។

ការពង្រឹងសមត្ថភាពស្ថាប័នរបស់កម្ពុជា ត្រូវមានការកសាងសមត្ថភាពក្នុងរយៈពេលវែង និងការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ក្នុងទិសដៅដែលបានដាក់ចេញ។ ប៉ុន្តែតាមធម្មតា ការងារនេះតែងជួបការលំបាកដោយសារភាពមិនស៊ីគ្នារវាងការរំពឹងទុករបស់ដៃគូអភិវឌ្ឍន៍ និងភាពជាក់ស្តែងនៃសមត្ថភាពស្ថាប័ន។ ជាទូទៅ ដៃគូអភិវឌ្ឍន៍តែងរំពឹងចង់បានលទ្ធផលឆាប់រហ័ស ប៉ុន្តែភាពទន់ខ្សោយជាប្រព័ន្ធជាក់ស្តែងក្នុងស្ថាប័នកម្ពុជា ត្រូវការពេលវេលាយូរ ដើម្បីដោះស្រាយ។ សមត្ថភាពស្ថាប័ន មិនមែនត្រឹមតែជាបញ្ហាសេដ្ឋកិច្ច-សង្គមកិច្ចនោះទេ ប៉ុន្តែ មានទាក់ទងនឹងទិដ្ឋភាពនយោបាយ ព្រមទាំងវប្បធម៌សំខាន់ៗទៀតផង ហើយបញ្ហាទាំងនេះមិនអាចដោះស្រាយបានភ្លាមៗនោះទេ។ ដើម្បីឲ្យមានប្រសិទ្ធភាពល្អ ការរំពឹងទុក និងភាពជាក់ស្តែង ត្រូវតែសម្របសម្រួលឲ្យស៊ីគ្នា តាមរយៈអន្តរាគមន៍ខាងគោលនយោបាយដ៏សមស្រប។ រដ្ឋាភិបាលយល់ឃើញដោយប្រាកដនិយមថា ការកសាងសមត្ថភាពស្ថាប័ន ត្រូវប្រើពេលពី ៥-១០ឆ្នាំ ដើម្បីឈានដល់ស្តង់ដារស្ថាប័នសាកល ហើយដៃគូអភិវឌ្ឍន៍នានា គួរតែអនុវត្តការងារ ព្រមទាំងរៀបចំ និងសម្របសម្រួលគោលនយោបាយឆ្លើយតបឲ្យស៊ីគ្នានឹងក្របខ័ណ្ឌពេលវេលានេះ។

### ឯកសារយោង

បទបង្ហាញនានាក្នុងសន្និសីទចក្ខុវិស័យ អាចរកបាននៅក្នុងគេហទំព័ររបស់វិទ្យាស្ថាន CDRI: www.cdri.org.kh។

# អង្កេតស្តីពីសមត្ថភាព និងការត្រៀមខ្លួនរបស់ឃុំក្នុងការគ្រប់គ្រងគម្រោងអភិវឌ្ឍន៍មូលដ្ឋាន៖ លទ្ធផលបឋម[1]

## ១. សេចក្តីផ្តើម

ទិដ្ឋភាពដ៏សំខាន់មួយនៃកំណែទម្រង់វិមជ្ឈការ គឺការផ្តល់ក្របខ័ណ្ឌមួយដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីគ្រប់គ្រងនិងសម្របសម្រួលគម្រោងអភិវឌ្ឍន៍ និងគំនិតផ្តួចផ្តើមនានានៅមូលដ្ឋាន។ ការវិភាគពីគម្រោងផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១២ បង្ហាញថា ៧៧% នៃការអនុវត្តគម្រោង ជាការទទួលខុសត្រូវរួមគ្នារបស់អាជ្ញាធរថ្នាក់ក្រោមជាតិ និងរដ្ឋាភិបាលថ្នាក់ជាតិ។ យុទ្ធសាស្ត្រជាដៃគូរបស់កម្ពុជាជាមួយ ADB ភាគច្រើនផ្តោតលើសហគមន៍ក្នុងអាងទន្លេសាប (ADB 2009; Tariq 2011)។

ក្រុមប្រឹក្សាឃុំ ដែលជាស្ថាប័នរដ្ឋាភិបាលថ្នាក់ក្រោមជាតិចំបងមួយ បាននិងកំពុងបន្តទទួលខុសត្រូវក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ ដើម្បីកែលម្អជីវភាពរស់នៅនៃសហគមន៍មូលដ្ឋានក្នុងព្រំដែនរដ្ឋបាលរបស់ខ្លួន។ ដូច្នេះ ការយល់ដឹងកាន់តែស៊ីជម្រៅពីសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ និងបទពិសោធន៍ក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ និងគំនិតផ្តួចផ្តើមផ្សេងៗ អាចជួយកែលម្អការកំណត់គោលដៅគម្រោងអភិវឌ្ឍន៍សម្រាប់ប្រជាជនធម្មតា។

អត្ថបទនេះ បង្ហាញពីវិធីសាស្ត្រជាក់ស្តែងសម្រាប់ការចាត់ថ្នាក់សមត្ថភាពឃុំ ក្នុងការគ្រប់គ្រង និងអនុវត្តគម្រោងអភិវឌ្ឍន៍នៅមូលដ្ឋាន។ ពាក្យ "សមត្ថភាពឃុំ" មិនត្រឹមតែសំដៅលើអត្ថិភាពនៃហេដ្ឋារចនាសម្ព័ន្ធ និងគ្រឿងសម្រួលការងាររបស់ឃុំប៉ុណ្ណោះទេ តែថែមទាំងសំដៅលើសមត្ថភាព និងការអនុវត្តរបស់សមាជិកក្រុមប្រឹក្សាឃុំផងដែរ។

## ២. កត្តានានាសម្រាប់ការចាត់ថ្នាក់សមត្ថភាពឃុំ

ការសិក្សាជាច្រើនស្តីពី វិមជ្ឈការ និងវិសហមជ្ឈការ ផ្តល់នូវចំណេះដឹងជារួម អំពីរដ្ឋាភិបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាល មុខងារ សមត្ថភាព និងការរួមចំណែករបស់ក្រុមប្រឹក្សាឃុំទាក់ទងនឹងការអភិវឌ្ឍ និងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ព្រមទាំងបានគូសបញ្ជាក់ពីបញ្ហាប្រឈមជាច្រើន និងដំណោះស្រាយជាយុទ្ធសាស្ត្រនានា។

ធនធានធម្មជាតិ មានជាអាទិ៍ ទឹក ត្រី និងព្រៃឈើ ជាប្រភពសំខាន់នៃជីវភាពរស់នៅ និងប្រាក់ចំណូលសម្រាប់ប្រជាជនក្នុងតំបន់ភូមិសាស្ត្រដូចជានៅអាងទន្លេសាបនេះ។ ប៉ុន្តែបទពិសោធន៍និងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ក្នុងការគ្រប់គ្រង និងថែរក្សាធនធានធម្មជាតិឲ្យមានសមធម៌ និងមានចីរភាព គឺនៅមានកម្រិត។ Rusten *et at.* (2004) អះអាងថា ក្រុមប្រឹក្សាឃុំនៅខ្វះចំណេះដឹង និងការយល់ច្បាស់អំពីរបៀបគ្រប់គ្រងធនធានធម្មជាតិ រីឯ Kim & Henke (2005) បានបញ្ជាក់ថា ក្រុមប្រឹក្សាឃុំកំពុងជួបប្រទះបញ្ហាប្រឈមយ៉ាងធំ ក្នុងការការពារធនធានធម្មជាតិ។ ការសិក្សាមួយនាពេលថ្មីៗធ្វើឡើងដោយ Thon *et al.* (2009) សន្និដ្ឋានថា សមត្ថភាពគ្រប់គ្រងធនធានធម្មជាតិរបស់ក្រុមប្រឹក្សាឃុំ ត្រូវតែពង្រឹងថែមទៀត ហើយការគ្រប់គ្រងធនធានធម្មជាតិនៅកម្រិតតំបន់ គួរមានទំនាក់ទំនងប្រសើរជាងមុនជាមួយរដ្ឋាភិបាលមជ្ឈិម។

ការរចនារៀបចំគម្រោងអភិវឌ្ឍន៍នៅមូលដ្ឋានដោយមានការចូលរួម ក្នុងនេះមានទាំងការធ្វើផែនការ និងគម្រោងថវិកាផង គឺសំដៅបំផុស និងជម្រុញឲ្យសហគមន៍ចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ ទោះយ៉ាងនេះក្តី គណៈកម្មាធិការរៀបចំផែនការ និងថវិកា នៅទន់ខ្សោយនៅឡើយ ហើយទំនងមានសមាជិកតែពីរបីនាក់ប៉ុណ្ណោះដែលសកម្មនឹងការងារ (Kim & Henke 2005)។ ហិរញ្ញប្បទានមានកម្រិត និងក្របខ័ណ្ឌពេលវេលាជាក់លាក់ អាចជម្រុញឲ្យក្រុមប្រឹក្សាឃុំធ្វើការកំណត់អាទិភាពមុនពេលបានពិគ្រោះជាមួយអ្នកភូមិ ឬដាក់ចេញនូវផែនការសកម្មភាពឲ្យស្របតាមបំណងរបស់អ្នកផ្តល់ជំនួយ ជាជាងតាមអាទិភាពរបស់អ្នកភូមិ។ ចំពោះគុណភាពនៃការពិគ្រោះយោបល់ វាអាស្រ័យលើសមត្ថភាពរបស់គណៈកម្មាធិការ ហើយក៏អាស្រ័យលើសមត្ថភាពរបស់សមាជិកគណៈកម្មាធិការម្នាក់ៗដែរ។

គម្រោងអភិវឌ្ឍន៍មូលដ្ឋាន ទទួលបានហិរញ្ញប្បទានពីមូលនិធិឃុំ/សង្កាត់ និងប្រភពពីខាងក្រៅផ្សេងទៀត ដូចជាបុគ្គល និងគណបក្សនយោបាយនានា (Thon *et al.* 2009)។ ដូច្នេះ ឃុំត្រូវតែឆ្លើយតបនឹងគោលដៅដែលបានព្រមព្រៀងជាមួយម្ចាស់ជំនួយ ហើយនេះជាបញ្ហាប្រឈមមួយ។

សរុបមក មានកត្តាជាច្រើន ដែលកំណត់ពីសមត្ថភាពនៃការអនុវត្តមុខងារ និងទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ ក៏ដូចជាគុណភាព និងបរិមាណនៃលទ្ធផលសម្រេចបាន។ សមត្ថភាពសំដៅដល់លទ្ធភាពក្នុងការអនុវត្តមុខងារឲ្យបានសក្តិសិទ្ធិ មានប្រសិទ្ធភាព និងមានចីរភាព ហើយសម្រេចបានតាមគោលដៅអភិវឌ្ឍន៍ក្នុងរយៈពេលកំណត់ណាមួយ (Blagescu & Young 2006; Em 2008)។ ដូច្នេះ សមត្ថភាពក្រុមប្រឹក្សាឃុំ ត្រូវជាប់ទាក់ទិនទាំងធនធាន និងប្រព័ន្ធរបស់ឃុំ ក្នុងនេះមានទាំងសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាឃុំផងដែរ។ ការសិក្សាបានរកឃើញកត្តា ១០ ដែលកំណត់លើសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ និងសមាជិកក្រុមប្រឹក្សា។

---

១ អត្ថបទនេះ រៀបចំដោយលោក អែម ស៊ូវ៉ានី និងលោក គឹម សួ ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។ អត្ថបទនេះ សង្ខេបរបាយការណ៍ស្តីពី អង្កេតសមត្ថភាព និងការត្រៀមខ្លួនរបស់ឃុំ (Em & Kim 2011)។ អ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះ មូលនិធិជប៉ុនសម្រាប់ការកាត់បន្ថយភាពក្រីក្រ ធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅកម្ពុជា ដែលបានផ្តល់ហិរញ្ញប្បទាន និងចំពោះលោក កុយ រ៉ា និងលោក អ៊ូច ឈួង ដែលបានជួយក្នុងការធ្វើអង្កេត។

ភាពក្រីក្រ៖ អត្រានៃភាពក្រីក្រ បង្ហាញពីបញ្ហាប្រឈមក្នុងការអភិវឌ្ឍ ជាពិសេសដើម្បីសម្រេចបានការកាត់បន្ថយភាពក្រីក្រ ១% ក្នុងមួយឆ្នាំ ដែលមានចែងក្នុងយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី២ (RGC 2008)។ តួលេខនៃភាពមិនក្រ ត្រូវកំណត់ឡើងដោយយក ១០០ ដកជាមួយនឹងអត្រានៃភាពក្រីក្រ។ អត្រាទាបនៃភាពមិនក្រ បង្ហាញថា ភាពក្រីក្រ និងភាពងាយរងគ្រោះខ្លាំង នៅមានកម្រិតខ្ពស់ ហើយធាតុផ្សំមួយចំនួន ដូចជា ប្រាក់ចំណូល ប្រភពដោះស្រាយជីវភាព និងសន្តិសុខស្បៀង ជាដើម ត្រូវតែពង្រឹងឡើង និងធ្វើពិពិធកម្ម។

ទីតាំងភូមិសាស្រ្ត៖ ទីតាំងឃុំនៅដាច់ឆ្ងាយពីផ្លូវធំ ធ្វើឲ្យការដឹកជញ្ជូនកសិផលទៅទីផ្សារ និងការសម្របសម្រួលសកម្មភាពគាំទ្រពីខាងក្រៅ ជួបការលំបាក និងត្រូវចំណាយអស់ច្រើន។

សាលាឃុំ៖ ជាគោលការណ៍ ក្រុមប្រឹក្សាឃុំ គឺជាមជ្ឈមណ្ឌលនៃសេវាសាធារណៈ គំនិតផ្តួចផ្តើម និងការពិភាក្សានៅមូលដ្ឋាន ហើយការគ្រប់គ្រងសកម្មភាពទាំងនេះ ត្រូវមានកន្លែងការិយាល័យសមរម្យ។

គ្រឿងសម្ភារការងារ៖ បរិក្ខារ និងគ្រឿងសង្ហារឹមមូលដ្ឋានសម្រាប់ប្រើក្នុងការិយាល័យ សំខាន់ខ្លាំងណាស់សម្រាប់បម្រើសកម្មភាព និងសេវាសម្របសម្រួលរបស់ឃុំ។ តួយ៉ាង ការមានទូគ្រប់គ្រាន់សម្រាប់រក្សាឯកសារ និងកំណត់ត្រាផ្សេងៗឲ្យបានត្រឹមត្រូវ អាចជួយសម្រួលឲ្យការផ្តល់សេវាអនុវត្តបានកាន់តែឆាប់រហ័ស។

កិច្ចប្រជុំ៖ សមាជិកក្រុមប្រឹក្សាឃុំ ធ្វើសេចក្តីសម្រេចដោយមានការចូលរួមនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា ដែលតាមធម្មតា ត្រូវធ្វើប្រចាំខែ។ កិច្ចប្រជុំប្រចាំខែ ការពិគ្រោះយោបល់ និងកិច្ចប្រជុំចំពោះកិច្ចផ្សេងៗ ជាទូទៅត្រូវធ្វើឡើងនៅសាលាឃុំ។ កំណត់ត្រាពីកិច្ចប្រជុំ ត្រូវផ្ញើជូនទៅការិយាល័យថ្នាក់លើទៀត។ ការពិគ្រោះយោបល់ជាញឹកញាប់ និងជាប្រព័ន្ធ ដោយមានការចូលរួមយ៉ាងសកម្ម និងមានកំណត់ត្រាត្រឹមត្រូវ ផ្តល់នូវអារម្មណ៍ថា ការសម្រេចចិត្តមានលក្ខណៈរាប់បញ្ចូលល្អ។

ប្រព័ន្ធហិរញ្ញវត្ថុ៖ សមាជិកក្រុមប្រឹក្សាឃុំ មានលទ្ធភាពទទួលបានប្រភពហិរញ្ញប្បទានច្រើន។ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ ឆ្លុះបញ្ចាំងពីគណនេយ្យភាពរបស់ឃុំចំពោះអ្នកផ្តល់មូលនិធិ។ យ៉ាងហោចណាស់មានយន្តការហិរញ្ញវត្ថុពីរ ដែលឃុំបានទទួលយកមកប្រើប្រាស់ គឺយន្តការរបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (DoLA) និងយន្តការរបស់ទីភ្នាក់ងារផ្តល់មូលនិធិ។ ប៉ុន្តែគួរកត់សម្គាល់ថា ទីភ្នាក់ងារផ្តល់មូលនិធិផ្សេងៗគ្នា មានប្រព័ន្ធហិរញ្ញវត្ថុខុសៗគ្នា។

ការរៀបចំគម្រោង និងផ្តល់មូលនិធិ៖ ការរចនារៀបចំគម្រោងដោយមានការចូលរួមសម្រាប់គំនិតផ្តួចផ្តើមអភិវឌ្ឍន៍នៅមូលដ្ឋានអនុវត្តឡើង តាមរយៈការពិគ្រោះយោបល់ជាមួយអ្នកភូមិ ដើម្បីឆ្លើយតបនឹងតម្រូវការនៅមូលដ្ឋាន។ ការកំណត់អាទិភាពនៃសកម្មភាពនានាក្នុងផែនការវិនិយោគរបស់ឃុំ គឺជាលទ្ធផលនៃការពិគ្រោះយោបល់ថ្នាក់មូលដ្ឋាន។

បរិស្ថាន និងសហគមន៍៖ ជាការសំខាន់ណាស់ដែលសមាជិកក្រុមប្រឹក្សាមានការយល់ដឹងពី ផលប៉ះពាល់បរិស្ថាន និងបម្រែបម្រួលអាកាសធាតុ។ ចំណេះដឹងនេះជួយសម្រួលពួកគេក្នុងការបង្កើតគំនិតផ្តួចផ្តើម និងកំណត់អាទិភាពដែលអំណោយផលដល់បរិស្ថាននៅមូលដ្ឋាន។ ផែនការវិនិយោគរបស់ឃុំ រំពឹងថាមានបូកបញ្ចូលនូវកត្តាសង្គមមួយចំនួន ជាអាទិ៍ ការដោះស្រាយទំនាស់ សមភាពយេនឌ័រ ការចូលរួមរបស់ក្រុមគ្មានសិទ្ធិអំណាច ដូចជា ជនជាតិដើមភាគតិច អ្នកផ្ទុកមេរោគអេដស៍ ។ល។

បុគ្គលិកជំនួយការ៖ ទោះជាគោលការណ៍ សមាជិកក្រុមប្រឹក្សាជាប់ឆ្នោត ត្រូវមានចំនួនគ្រប់គ្រាន់សម្រាប់ធ្វើជាតំណាងឲ្យប្រជាជនក្នុងឃុំទាំងមូលក្តី ក៏ការផ្តល់សេវាជាក់ស្តែង និងការពិគ្រោះយោបល់អំពីគម្រោងអភិវឌ្ឍន៍នានា វាប្រែប្រួលខុសគ្នាដែរ។ បុគ្គលិកមានសមត្ថភាព និងបទពិសោធន៍សម្រាប់បំពេញតួនាទីជំនួយការ អាចជ្រើសរើសបានតាមរយៈការជួល ការស្ម័គ្រចិត្ត និងការបញ្ជូនមកធ្វើការបណ្តោះអាសន្ន។

ធនធានមនុស្ស និងការបណ្តុះបណ្តាល៖ ការគ្រប់គ្រងការផ្តល់សេវាកម្ម រំពឹងថានឹងរីកចម្រើនឡើងតាមរយៈការពិគ្រោះយោបល់ និងការចូលរួមក្នុងព្រឹត្តិការណ៍ចែករំលែកចំណេះដឹង និងការបណ្តុះបណ្តាល ហើយតាមរយៈការធ្វើការរួមគ្នា សមាជិកក្រុមប្រឹក្សាកាន់តែមានទំនុកចិត្តលើខ្លួនឯង ក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។

## ៣. វិធីសាស្រ្តធ្វើចំណាត់ថ្នាក់

នីតិវិធីដាក់ពិន្ទុ៖ សំណួរមួយក្រុមតូច ត្រូវបានបង្កើតឡើងសម្រាប់កត្តានីមួយៗ ដែលត្រូវទទួលបានពិន្ទុ ពី 0 ដល់ ១០០។ កត្តាសំខាន់ ត្រូវទទួលបានពិន្ទុខ្ពស់។ ឧទាហរណ៍ សាលាឃុំសង់ពីឥដ្ឋ ទទួលបានពិន្ទុខ្ពស់ជាងសាលាឃុំសង់ពីឈើ។ វិធីសាស្រ្តដាក់ពិន្ទុនេះ អាចប្រើសម្រាប់ប្រៀបធៀបទិដ្ឋភាពជាក់លាក់នានានៃសមត្ថភាពឃុំ (ពោលគឺ កត្តាខ្លះៗ) ឬសន្ទស្សន៍សមត្ថភាពឃុំ (CCI) (ពោលគឺ កត្តាទាំង១០ ខាងលើ) ដើម្បីអាចមានទស្សនៈកាន់តែធំទូលាយ។

ការគណនាសន្ទស្សន៍៖ សន្ទស្សន៍សមត្ថភាពឃុំ (CCI) ត្រូវគណនាឡើង ដោយយកពិន្ទុសរុបរបស់កត្តាទាំង១០ ចែកនឹង ១000 ដែលជាពិន្ទុអតិបរមា (ពិន្ទុ១00 សម្រាប់កត្តានីមួយៗ)។ ដូច្នេះ CCI ស្ថិតនៅចន្លោះពី 0 ទៅ ១ ដែល 0 តំណាងឲ្យសមត្ថភាពទាបបំផុត និង ១ តំណាងឲ្យសមត្ថភាពខ្ពស់បំផុត។ CCI របស់ឃុំមួយ មានបង្ហាញជាឧទាហរណ៍នៅក្នុងតារាង ១។

ការជ្រើសរើសឃុំ៖ វិធីសាស្រ្តចាត់ថ្នាក់នេះ អាចប្រើប្រាស់ដើម្បីប្រៀបធៀបឃុំ ដោយផ្អែកលើកត្តាបានជ្រើសរើសទាំង១០ ខាងលើ ប៉ុន្តែក៏គួរសង្កេតពីអន្តរកម្មនៃកត្តាជាប់ទាក់ទិនផងដែរ។ ដូច្នេះ ឃុំជាគោលដៅនៃគម្រោង ៥ របស់ ADB ក្នុងខេត្តចំនួន ៧ ត្រូវបានជ្រើសរើសសម្រាប់អង្កេត។ គម្រោងទាំង៥ គឺមាន៖ គម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប (TSEMP) គម្រោងជីវភាពរស់នៅប្រកបដោយចីរភាពនៅបឹងទន្លេសាប (TSSLP) គម្រោង អភិវឌ្ឍន៍តំបន់ជនបទនៅវាលទំនាបបឹងទន្លេសាប (TSLRDP) គម្រោងផ្គត់ផ្គង់ទឹក និងអនាម័យនៅតំបន់ជនបទបឹងទន្លេសាប (TSRWSS) និងគម្រោងអភិវឌ្ឍន៍អ្នកកាន់កាប់ដីតូចៗនៅបឹងទន្លេសាប (TSSHDP)។ គម្រោង TSEMP និង

តារាង ១. ប្រព័ន្ធដាក់ពិន្ទុសម្រាប់កត្តាទាំង១០

| | កត្តា | ពិន្ទុជាក់ស្ដែង (ក្រោយអង្កេត) |
|---|---|---|
| A | អត្រាមិនក្រក្នុងឃុំ (១០០ - អត្រាភាពក្រីក្រ) | = 100 - 58.2 = 41.8 |
| B | ទីតាំងភូមិសាស្ត្រ | 75 |
| C | សាលាឃុំ | 95 |
| D | គ្រឿងសម្រួលការងាររបស់ឃុំ | 35 |
| E | ការជួបប្រជុំ | 95 |
| F | ប្រព័ន្ធហិរញ្ញវត្ថុ | 90 |
| G | ការរចនារៀបចំគម្រោង និងការផ្ដល់មូលនិធិ | 90 |
| H | បរិស្ថាន និងសហគមន៍ | 100 |
| I | បុគ្គលិកជំនួយការឃុំ | 47 |
| J | ធនធានមនុស្ស និងការបណ្ដុះបណ្ដាល | 44 |
| | CCI = 712.8/1000 | 0.7128 |

តារាង ២. ការជ្រើសរើសឃុំផ្អែកលើគម្រោងមុនៗ

| គម្រោង | ឃុំក្នុងគម្រោងសរុប | ចំនួនកូតាជ្រើសរើស | ឃុំក្នុងគម្រោងដែលបានជ្រើសរើស | ឃុំមានគម្រោងតែមួយ | ឃុំមានគម្រោងច្រើន |
|---|---|---|---|---|---|
| TSSLP (គម្រោងបានបញ្ចប់) | 37 | 6 | 10 | 1 | 9 |
| TSEMP (គម្រោងបានបញ្ចប់) | 92 | 14 | 19 | 1 | 18 |
| TSLRDP (ទើបចាប់ផ្ដើម) | 40 | 6 | 31 | 20 | 11 |
| TSSDHP (ជិតចាប់ផ្ដើម) | 193 | 30 | 36 | 19 | 17 |
| TSRWSS (ជិតចាប់ផ្ដើម) | 40 | 6 | 19 | 3 | 16 |
| ឃុំក្រៅគម្រោង ADB | 230 | 35 | 20 | 0 | 0 |
| សរុប | 632 | 97 | | | |
| ល្បឿងអតិបរមាក្នុងការជ្រើសគំរូតាង៖ ៩,៣៥ % | | | | | |

TSSLP បានបញ្ចប់រួចរាល់ រីឯគម្រោង TSLRDP ទើបចាប់ផ្ដើមនាពេលថ្មីៗ ហើយ គម្រោង TSSHDP និង TSRWSS គ្រោងចាប់ផ្ដើមនាពេលឆាប់ៗ។ ខេត្តស្ថិតក្នុងគម្រោង គឺមានបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ ពោធិ៍សាត់ និង សៀមរាប។ ឃុំក្នុងខេត្តជាមួយគ្នា តែមិនចំគោលដៅរបស់ ADB ក៏ត្រូវបានជ្រើសរើសដែរ សម្រាប់ធ្វើការប្រៀបធៀប។

ក្នុងចំណោម ៦៣២ឃុំ ក្នុង ៧ខេត្តជាប់បឹងទន្លេសាប និងទន្លេមេគង្គ មាន ៤០២ឃុំ ស្ថិតក្នុងគម្រោង ADB និង ២៣០ឃុំនៅក្រៅគម្រោង។ ពីក្នុងចំណោមប្រជាជនសរុប គេបានជ្រើសរើសដោយចៃដន្យ ១៥% ដែលផ្ដល់នូវរបាយគំរូតាងដ៏ល្អមួយ ដោយមានល្បឿង ១០% ក្នុងការជ្រើសគំរូតាង ដែលអាចបណ្ដាលមកពីការជ្រើសរើសឃុំជាគោលដៅនៃគម្រោង ADB ពីឆ្នាំ២០០៨ ដល់ ២០១០[២]។

ការប្រមូលទិន្នន័យ៖ ការសិក្សានេះទទួលបានព័ត៌មានពី ការពិភាក្សាតាមក្រុមស្នូល (FGDs) ជាមួយមន្ត្រីឃុំ ដោយប្រើបញ្ជីសំណួរមានជម្រើសច្រើន ផ្អែកលើកត្តាបានជ្រើសរើសទាំង១០។ ដើម្បីធានាគុណភាពព័ត៌មាន បានដោះស្រាយឲ្យឃុំនីមួយៗមានសមាជិកក្រុមប្រឹក្សាយ៉ាងហោចណាស់ ៥០% មកចូលរួមក្នុងការពិភាក្សាក្រុមស្នូល។ ក្រុមស្រាវជ្រាវបានកត់ត្រា និងដាក់ពិន្ទុព័ត៌មានទទួលបាន ទុកសម្រាប់ការវិភាគ។[៣]

## ៤. លទ្ធផលស្រាវជ្រាវសំខាន់ៗ

លទ្ធផលចំបងបានពីអង្កេតនេះ គឺសន្ទស្សន៍សមត្ថភាពឃុំ (CCI) ដែលជាសូចនាករគន្លឹះមួយសម្រាប់វាស់វែងសមត្ថភាពរបស់ឃុំជាទូទៅ។ លទ្ធផលសំខាន់មួយទៀត គឺការកំណត់កត្តាទាំង១០ សម្រាប់ស្វែងរកមើលទិដ្ឋភាពជាក់លាក់នៃសមត្ថភាពឃុំ។ តារាង ៣ បង្ហាញពីលទ្ធផលរបស់ ១០ឃុំ ដែលបានពិន្ទុ

២ រូបមន្តជ្រើសគំរូតាងដោយចៃដន្យនៃ n=N/(1+Ne2) (Zulueta & Costales 2006)

៣ សម្រាប់ព័ត៌មានបន្ថែមស្ដីពីវិធីសាស្ត្រចាត់ថ្នាក់ និងឧបករណ៍ប្រមូលទិន្នន័យ សូមទាក់ទងលោក អែម សូវ៉ាន់នី និងលោក គឹម សួ នៅវិទ្យាស្ថាន CDRI។

តារាង ៣. ឃុំ ១០ ដែលទទួលបានពិន្ទុលើសគេក្នុងពេលអង្កេត ផ្អែកលើកត្តាជ្រើសរើសទាំង១០

| ខេត្ត | ស្រុក | ឃុំ | កត្តា | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | A | B | C | D | E | F | G | H | I | J | CCI |
| បាត់ដំបង | សង្កែ | កំពង់ព្រះ | 69.2 | 90 | 95 | 69 | 90 | 95 | 95 | 85 | 61 | 56 | 0.81 |
| បន្ទាយមានជ័យ | ក្រុងសិរីសោភ័ណ | ព្រះពន្លា | 86.9 | 90 | 70 | 49 | 95 | 100 | 100 | 100 | 42 | 64 | 0.80 |
| ពោធិ៍សាត់ | បាកាន | ស្នាមព្រះ | 64.2 | 90 | 95 | 69 | 100 | 100 | 90 | 100 | 45 | 49 | 0.80 |
| បាត់ដំបង | ថ្មគោល | អូរតាគី | 74.4 | 90 | 95 | 65 | 100 | 100 | 95 | 95 | 19 | 61 | 0.79 |
| កំពង់ចាម | ស្ទឹងត្រង់ | ព្រែកបាក់ | 74.6 | 90 | 95 | 42 | 100 | 95 | 95 | 100 | 39 | 55 | 0.79 |
| ពោធិ៍សាត់ | បាកាន | ត្រពាំងជង | 68.2 | 90 | 85 | 61 | 95 | 100 | 95 | 80 | 59 | 56 | 0.79 |
| ពោធិ៍សាត់ | ក្រគរ | ឈើតុំ | 65.5 | 80 | 95 | 59 | 100 | 100 | 95 | 100 | 42 | 55 | 0.79 |
| កំពង់ចាម | បាធាយ | សំបូរ | 74.3 | 85 | 95 | 47 | 95 | 95 | 95 | 95 | 41 | 54 | 0.78 |
| បន្ទាយមានជ័យ | មង្គលបុរី | បន្ទាយនាង | 70.8 | 90 | 95 | 54 | 95 | 95 | 95 | 85 | 62 | 31 | 0.77 |
| កំពង់ធំ | ស្ទោង | ប្រឡាយ | 61.6 | 90 | 95 | 32 | 95 | 95 | 95 | 90 | 57 | 63 | 0.77 |

A: អត្រាមិនក្រ B: ទីតាំងភូមិសាស្ត្រ C: សាលាឃុំ D: គ្រឿងសម្រួលការងារ E: ការជួបប្រជុំ F: ប្រព័ន្ធហិរញ្ញវត្ថុ
G: ការរចនារៀបចំគម្រោង និងការផ្តល់មូលនិធិ H: បរិស្ថាន និងសហគមន៍ I: បុគ្គលិកជំនួយការឃុំ J: ធនធានមនុស្ស និងការបណ្តុះបណ្តាល

តារាង ៤. ការប្រៀបធៀបកត្តាកំណត់ក្នុងឃុំអង្កេតចំនួនពីរ

| | កត្តាបានអង្កេត | កំពង់ព្រះគគីរ* | កំពង់ព្រះ** |
|---|---|---|---|
| A | អត្រាមិនក្រ | 59.7 | 69.2 |
| B | ទីតាំងភូមិសាស្ត្រ | 75 | 90 |
| C | សាលាឃុំ | 70 | 95 |
| D | គ្រឿងសម្រួលការងាររបស់ឃុំ | 9 | 69 |
| E | ការជួបប្រជុំ | 90 | 90 |
| F | ប្រព័ន្ធហិរញ្ញវត្ថុ | 90 | 95 |
| G | ការរចនារៀបចំគម្រោង និងការផ្តល់មូលនិធិ | 75 | 95 |
| H | បរិស្ថាន និងសហគមន៍ | 65 | 85 |
| I | បុគ្គលិកជំនួយការឃុំ | 36 | 61 |
| J | ធនធានមនុស្ស និងការបណ្តុះបណ្តាល | 35 | 56 |
| | CCI | 0.6 | 0.81 |

* ឃុំកំពង់ព្រះគគីរ ស្ថិតក្នុងស្រុកបរិបូរ ខេត្តកំពង់ឆ្នាំង

** ឃុំកំពង់ព្រះ ស្ថិតក្នុងស្រុកសង្កែ ខេត្តបាត់ដំបង

លើសគេ។ CCI ពេញលេញ អាចរកបាននៅក្នុង Em & Kim (2011)។

ដើម្បីបង្ហាញពីការប្រើប្រាស់ CCI មានការប្រៀបធៀបពិន្ទុរវាងឃុំពីរ នៅក្នុងតារាង៤។ ឃុំកំពង់ព្រះគគីរ មានCCI ស្មើនឹង ០,៦ ហើយឃុំកំពង់ព្រះ មាន ០,៨១។ ឃុំកំពង់ព្រះ មានពិន្ទុសរុបលើកត្តាទាំង១០ ខ្ពស់ជាងឃុំកំពង់ព្រះគគីរ គឺមានន័យថា ឃុំកំពង់ព្រះ មានសមត្ថភាពខ្ពស់ជាង ក្នុងការគ្រប់គ្រងគម្រោងអភិវឌ្ឍន៍។

ការចុះពិន្ទុកត្តាទាំង១០ នៅលើគំនូសស្ថិតិរ៉ាដា (ក្រាហ្វិក ១) ធ្វើឲ្យការពិនិត្យមើល និងការប្រៀបធៀប សមត្ថភាពឃុំទាំងពីរកាន់តែងាយស្រួល។

CCI នៃឃុំអង្កេតទាំង ៩៧ គេបានបែងចែកជា ៣ កម្រិត ផ្អែកលើការវិភាគប្រេកង់៖ ខ្ពស់ (CCI ធំជាង ០,៧៤) មធ្យម (CCI នៅចន្លោះពី ០,៧០ ទៅ ០,៧៤) និង ទាប (CCI តូចជាង ០,៧០) ។ ឃុំអង្កេត ជិតដល់ ២៩% មាន CCI ខ្ពស់ ហើយ

ប្រហែល ៤៥% មាន CCI មធ្យម និង ជិតដល់ ២៦% មាន CCI ទាប។

ក្រាហ្វិក ១. ការប្រៀបធៀបសមត្ថភាពរវាង ២ឃុំអង្កេត ដោយប្រើកត្តាជ្រើសរើសទាំង១០




A: អត្រាមិនក្រ B: ទីតាំងភូមិសាស្ត្រ C: សាលាឃុំ D: គ្រឿងសម្រួលការងារ E: ការជួបប្រជុំ F: ប្រព័ន្ធហិរញ្ញវត្ថុ G: ការរៀបចំគម្រោង និងការផ្តល់មូលនិធិ H: បរិស្ថាន និងសហគមន៍ I: បុគ្គលិកជំនួយការឃុំ J: ធនធានមនុស្ស និងការបណ្តុះបណ្តាល

បន្ទាប់ពីគូសផែនទីឃុំដោយប្រើចំណាត់ថ្នាក់ដូចខាងលើ គេអាចឃើញថា ឃុំដែលមានទីតាំងជិតផ្លូវធំ (ផ្លូវជាតិលេខ៥ ឬលេខ៦) ស្ថិតក្នុងក្រុមមានសមត្ថភាពខ្ពស់ និងមធ្យម ហើយឃុំនៅឆ្ងាយពីផ្លូវធំ ស្ថិតក្នុងក្រុមមានសមត្ថភាពទាប។

ក្នុងករណីនេះ គេអាចសន្និដ្ឋានបានថា ឃុំនៅឆ្ងាយៗ និងពិបាកចូលដល់ តែងចាញ់ប្រៀបគេក្នុងការទទួលបានគម្រោង ហើយតែងត្រូវបានមើលរំលងក្នុងការផ្តល់មូលនិធិ ឬជំនួយទ្រទ្រង់ពីរដ្ឋាភិបាល ឬទីភ្នាក់ងារអភិវឌ្ឍន៍នានា។ ជាលទ្ធផល សមាជិកក្រុមប្រឹក្សាឃុំ/សកម្មជន ក្នុងឃុំដាច់ស្រយាល អាចពុំបានទទួលបទពិសោធន៍ តាមរយៈការអនុវត្តគម្រោងនៅមូលដ្ឋាន។ នេះជាឧបសគ្គរាំងមិនឲ្យពួកគេមានឱកាសធ្វើការពង្រឹងសមត្ថភាព និងកសាងធនធាននៅមូលដ្ឋាន។ ប្រសិនបើសមត្ថភាព និងធនធានរបស់ឃុំពិបាកចូលដល់ នៅតែទន់ខ្សោយ ពួកគេ កាន់តែមិនអាចទាក់ទាញគម្រោងអភិវឌ្ឍន៍សម្រាប់ប្រជាជនមូលដ្ឋាន កុំថាឡើយតែគម្រោងអភិវឌ្ឍន៍ប្រើមូលនិធិពីបរទេសនោះ ជាពិសេសនៅពេលដែលឃុំងាយស្រួលចូលដល់នានា គេកាន់តែមានសមត្ថភាព និងធនធានច្រើនឡើង។ ដូច្នេះ ឃុំទាំងនេះ នឹងកាន់តែផុងជ្រៅទៅក្នុងស្ថានភាពគ្មានសិទ្ធិអំណាច។ គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេដែល (លើកលែងតែឃុំមួយចំនួនតូចចេញ) ទីតាំងភូមិសាស្ត្រ ហាក់មានទំនាក់ទំនងជាមួយ

ក្រាហ្វិក ២. ផែនទីបង្ហាញឃុំនានាតាមចំណាត់ថ្នាក់ CCI



ភាពក្រីក្រ ពោលគឺ ឃុំពិបាកចូលដល់ តែងមានអត្រាភាពក្រីក្រខ្ពស់។

ជាទូទៅ ឃុំអង្កេត មានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់អនុវត្ត។ មូលនិធិសរុបរបស់ឃុំ ពីឆ្នាំ២០០៨ ដល់ ២០១០ តែងមានទំនាក់ទំនងជាមួយនឹងកម្រិតនៃភាពក្រីក្រ។ ឃុំខ្លះទទួលបានហិរញ្ញប្បទានច្រើនជាងឃុំដទៃទៀត នៅអំឡុងឆ្នាំ២០០៨-១០ ប៉ុន្តែនៅមានអត្រាភាពក្រីក្រខ្ពស់ដដែល។ ឃុំដែលទទួលបានជំនួយពី ADB ហាក់មានសមត្ថភាពប្រសើរជាងឃុំមិនបានទទួលជំនួយសោះ ព្រោះជំនួយនោះបានជួយកែលម្អដល់កត្តាទាំង១០ ដែលបានជ្រើសរើសមកសិក្សា។

មូលនិធិឃុំ/សង្កាត់ មានប្រមាណជា ៥០% នៃមូលនិធិសរុបដែលឃុំអង្កេតទទួលបាន ពីឆ្នាំ២០០៨ ដល់២០១០ ហើយប្រភពមូលនិធិធំបំផុតលំដាប់ទី២ គឺ ADB ដែលបានផ្តល់ហិរញ្ញប្បទានជិត ៣៩% និងបន្ទាប់មកទៀត គឺទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក (DANIDA) ដែលរួមចំណែកជាង ៧%។ ម្ចាស់ជំនួយជាច្រើនទៀត ក៏បានផ្តល់មូលនិធិដល់គម្រោងតូចៗក្នុងឃុំអង្កេតដែរ។

ប្រមាណ៦០%នៃមូលនិធិសរុបរបស់ឃុំអង្កេតបានចំណាយលើគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន ដូចជា ការសាងសង់ និងស្តារ ផ្លូវថ្នល់ ស្ពាន ប្រឡាយ គម្រោងធារាសាស្ត្រ។ល។ ចំណែកធំជាងគេទី២ នៃមូលនិធិរបស់ឃុំ (ប្រមាណ ៣៦%) បានយកទៅប្រើសម្រាប់សកម្មភាពលើកស្ទួយជីវភាពរស់នៅ និងការកែលម្អការគ្រប់គ្រងធនធានធម្មជាតិ ហើយមូលនិធិនៅសល់គឺសម្រាប់សកម្មភាពសង្គម ដូចជា ការអប់រំពីការថែទាំសុខភាពមូលដ្ឋាន (ឧ. ការថែទាំអ្នកជម្ងឺអេដស៍) និងការការពារសិទ្ធិកុមារជាដើម។ លទ្ធផលនេះ បង្ហាញថា មានតែគម្រោងធំជាងគេពីរប៉ុណ្ណោះ (ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងជីវភាពរស់នៅ) ដែលអនុវត្តដោយសមាជិកក្រុមប្រឹក្សាឃុំ។ ដូច្នេះបទពិសោធន៍របស់សមាជិកក្រុមប្រឹក្សាឃុំ ភាគច្រើនទទួលបានតាមរយៈការចូលរួមក្នុងការសម្របសម្រួល និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលប្រើមូលនិធិឃុំ/សង្កាត់ និងការសម្របសម្រួលគំនិតផ្តួចផ្តើមទាក់ទិននឹងជីវភាពរស់នៅ ដែលអនុវត្តដោយភ្នាក់ងារផ្សេងៗទៀត។

ការរចនារៀបចំគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានមន្ត្រីលទ្ធកម្ម និងមន្ត្រីរដ្ឋបាលមូលដ្ឋានថ្នាក់ខ្ពស់ជាង ជួយសម្របសម្រួល ដោយមានគោលការណ៍ណែនាំ នីតិវិធី និងជំនួយបច្ចេកទេសផ្សេងៗ។ ប៉ុន្តែ សមាជិកក្រុមប្រឹក្សាឃុំ ក៏បានផ្តល់ធាតុចូលជាច្រើននៅតាមដំណាក់កាលមួយចំនួនដែរ ដូចជា គំនិត ចំណេះដឹង និងអង្កេតរបស់ពួកគាត់ទាក់ទិននឹងចរាចរណ៍ លំហូរទឹក ត្រី និងសត្វព្រៃជាដើម គឺមានលក្ខណៈសំខាន់ សម្រាប់ការរចនារៀបចំហេដ្ឋារចនាសម្ព័ន្ធ។ សមាជិកក្រុមប្រឹក្សាឃុំ ក៏មានបទពិសោធន៍ក្នុងមូលដ្ឋានយ៉ាងច្រើន ដូចជា ការប្រមូលព័ត៌មានពីអ្នកភូមិ និងការដោះស្រាយទំនាស់ទ្រព្យសម្បត្តិសម្រាប់គ្រួសាររងការប៉ះពាល់ពីគម្រោង ដែលជាធាតុចូលដ៏សំខាន់សម្រាប់ការរចនារៀបចំគម្រោង។ ពាក់ព័ន្ធនឹងគម្រោងលើកស្ទួយជីវភាពរស់នៅ និងសកម្មភាពសង្គមផ្សេងទៀត សមាជិកក្រុមប្រឹក្សាឃុំជួយសម្រេចអំពីគោលដៅនៃគម្រោង រីឯផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ គឺមានជំនួយការ ឬអ្នកសម្របសម្រួលគម្រោង ជួយគ្រប់គ្រង។

ជាទូទៅ ការយល់ដឹងពីបម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់ដល់បរិស្ថាន នៅមានកម្រិតនៅឡើយក្នុងចំណោមឃុំអង្កេតនានា។ ការអនុវត្តវិធានការបង្ការគ្រោះធម្មជាតិ ការគ្រប់គ្រងធនធានធម្មជាតិ និងការការពារបរិស្ថាននាបច្ចុប្បន្ន គេឃើញថា មានការជឿនលឿនខុសៗគ្នា អាស្រ័យលើទីតាំងភូមិសាស្ត្រ កម្រិតនៃការផ្តល់មូលនិធិ និងយុទ្ធសាស្ត្រដោះស្រាយផ្សេងៗគ្នា។

ការងារពាក់ព័ន្ធបញ្ហាសង្គម ជាពិសេសការជម្រុញឲ្យនារី ជនជាតិដើមភាគតិច និងជនប៉ះពាល់ដោយជម្ងឺអេដស៍ បានចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍ និងសកម្មភាពសង្គមនានានោះ មានការជឿនលឿនមិនស្មើគ្នាទេ។ សកម្មភាពទាំងនោះ បានរៀបចំឡើងនៅក្រោមមូលនិធិឃុំ/សង្កាត់ ហើយតែងមានការជម្រុញនៅក្នុងឃុំដោយមូលនិធិទទួលបានបន្ថែមពី អង្គការមិនមែនរដ្ឋាភិបាល។ ទំនាស់អំពីសកម្មភាពចិញ្ចឹមជីវិត និងអំពើហិង្សាក្នុងគ្រួសារ កន្លងមក មានការដោះស្រាយបានល្អ ទោះបីវានៅមានកើតឡើងជារឿយៗក្តី។

## ៥.សេចក្តីសន្និដ្ឋាន

CCI ជាវិធីសាស្ត្រសាមញ្ញ ងាយស្រួល ផ្អែកលើការប្រមូលទិន្នន័យពីការពិភាក្សាក្រុមស្នូល និងសម្រាប់ធ្វើការវាយតម្លៃពីសមត្ថភាពរបស់ អាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍នៅមូលដ្ឋាន និងពីហេដ្ឋារចនាសម្ព័ន្ធ និងគ្រឿងសម្រួលការងារដែលពួកគេមាន។

លទ្ធផលអង្កេតបង្ហាញថា៖

- ឃុំដែលទទួលជំនួយពី ADB ហាក់មានសមត្ថភាព និងអនុវត្តការងារបានប្រសើរជាងឃុំដែលមិនបានទទួល ប៉ុន្តែឃុំដែលទទួលមូលនិធិបានច្រើន មិនប្រាកដថាមានអត្រាភាពក្រីក្រកម្រិតទាបនោះទេ។
- ឃុំពិបាកចូលទៅដល់ ហាក់មានអត្រាភាពក្រីក្រខ្ពស់ ហើយសមត្ថភាព គួបផ្សំគ្នានៃប្រព័ន្ធគ្រប់គ្រងឃុំ និងធនធានមនុស្ស អាចមិនទាន់មានគ្រប់គ្រាន់ សម្រាប់អនុវត្តគម្រោងឲ្យបានសក្តិសិទ្ធិ។
- សមាជិកក្រុមប្រឹក្សាឃុំ បានចូលរួមយ៉ាងច្រើនក្នុងការកសាង និងស្តារហេដ្ឋារចនាសម្ព័ន្ធក៏ពិតមែន ប៉ុន្តែពួកគាត់មិនបានចូលរួមស្មើគ្នាល្អទេ ក្នុងការរចនារៀបចំសកម្មភាពកែលម្អជីវភាព និងអភិវឌ្ឍន៍សង្គម។ ដូច្នេះ ពួកគាត់ទទួលបានសមត្ថភាព ក្នុងការគ្រប់គ្រងគម្រោងហេដ្ឋារចនាសម្ព័ន្ធច្រើនជាង សមត្ថភាពក្នុងការកែលម្អជីវភាពនៅមូលដ្ឋាន ហើយនេះជាបញ្ហាប្រឈមដ៏ធំ សម្រាប់ការធ្វើពិពិធកម្មប្រាក់ចំណូលនៅជនបទ។
- សមាជិកក្រុមប្រឹក្សាជាទូទៅ នៅខ្វះខាតចំណេះដឹង និងការយល់ច្បាស់អំពី បម្រែបម្រួលអាកាសធាតុ ការបង្ការគ្រោះ

*តទៅទំព័រ ២៧*

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[១]

ផ្នែកនេះ បង្ហាញពីនិន្នាការសេដ្ឋកិច្ចពិភពលោក និងសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍ នៅត្រីមាសទី៤ ឆ្នាំ២០១០។

## កំណើនសេដ្ឋកិច្ចពិភពលោក

សេដ្ឋកិច្ចសាកល ចាប់ផ្តើមកើនឡើងក្នុងត្រីមាសទី២ ឆ្នាំ២០០៩ និងកើនឡើងជាបន្តបន្ទាប់ ក្រោយពីការធ្លាក់ចុះជាប្រវត្តិសាស្ត្រ នៅក្នុងត្រីមាសទី១។ ដោយប្រើវិធានការគោលនយោបាយសារពើពន្ធជាបន្ទាន់ បណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ និងអាស៊ីបូព៌ា បានឆ្លងកាត់វិបត្តិសាកលបានយ៉ាងល្អ ដោយសម្រេចបានកំណើនសេដ្ឋកិច្ចជាមធ្យមប្រមាណ ០,៧% នៅឆ្នាំ ២០០៩ និង ៨,៨% នៅឆ្នាំ២០១០។ នៅត្រីមាសទី៤ ឆ្នាំ២០១០ កំណើន ផសស ពិតពីមួយឆ្នាំទៅមួយឆ្នាំនៅប្រទេសឥណ្ឌូនេស៊ីមាន ៦,៩% ដែលជាអត្រាខ្ពស់បំផុតចាប់តាំងពីឆ្នាំ ២០០៦ មក។ កំណើន ផសស នៅម៉ាឡេស៊ី បានធ្លាក់ចុះមកត្រឹម ៤,៨% ចំណែកឯកំណើន ផសស នៅសិង្ហបុរី កើនឡើងវិញដល់ ១២%។ ក្នុងត្រីមាសដដែល កំណើន ផសស នៅថៃ រួមចុះមកត្រឹម ៣,៨% ដោយហេតុចំបងមកពីចលាចលផ្នែកនយោបាយ និងអស្ថិរភាពខាងសន្តិសុខ។ ផសស ពិតពីមួយឆ្នាំទៅមួយឆ្នាំ នៅវៀតណាម កើនដល់ ៧,៣% ធៀបនឹង ៥,៨% នៅត្រីមាសទី១ ឆ្នាំ២០១០ ដោយសារវិធានការគោលនយោបាយបន្ទាន់ និងកិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីពង្រីក ការនាំចេញសម្លៀកបំពាក់ សេវាកម្ម កសិកម្ម និង ថាមពល និងដើម្បីទាក់ទាញវិនិយោគផ្ទាល់ពីបរទេសឲ្យបានកាន់តែច្រើន។

នៅឆ្នាំ២០១០ ផសស នៅចិន មានកំណើនពីមួយឆ្នាំទៅមួយឆ្នាំជាមធ្យម ១០% ធៀបនឹង ៨,៤% ក្នុងឆ្នាំ២០០៩។ នៅត្រីមាសទី៤ ឆ្នាំ២០១០ កំណើន ផសស ពិត កើនបន្តិច ធៀបនឹងត្រីមាសមុន ដល់ ៩,៨%។ ក្នុងពេលដដែលនេះ កំណើន ផសស នៅហុងកុង ធ្លាក់ចុះមកត្រឹម ៦,២% ហើយនៅតៃវ៉ាន់ ធ្លាក់ចុះមកត្រឹម ៦,៩% ខណៈដែល ផសស កូរ៉េខាងត្បូង បានកើនឡើងតិចតួចដល់ ៤,៨%។

នៅឆ្នាំ២០១០ ផសស នៅប្រទេសសេដ្ឋកិច្ចជឿនលឿន បានងើបឡើងវិញ ជាមួយនឹងកំណើន ២,៨% ធៀបនឹងការរួមចុះជាមធ្យម ២,៧% នៅឆ្នាំ២០០៩។ ក្នុងត្រីមាសទី៤ ឆ្នាំ២០១០ ផសស មានកំណើន ២,២% នៅជប៉ុន និង ២,៨% នៅសហរដ្ឋអាមេរិក ធៀបនឹងត្រីមាសទី៣។ អត្រាកំណើន ផសស នៅតំបន់អឺរ៉ូ-១២ គឺ ២,២% ឬ ធ្លាក់ចុះ ៣,៣ឯកតាភាគរយ ធៀបនឹងត្រីមាសទី១។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

អតិផរណានៅអាស៊ីអាគ្នេយ៍ និងអាស៊ីបូព៌ា បានថយចុះមកត្រឹម ១,៤% ក្នុងឆ្នាំ២០០៩ ដោយសារការធ្លាក់ចុះសកម្មភាពសេដ្ឋកិច្ច និងការចុះថ្លៃទំនិញអន្តរជាតិ។ ក្នុងពេលដដែលនេះ អត្រាអតិផរណាក្នុងសេដ្ឋកិច្ចមួយចំនួន បានថយចុះដោយសារបរិត្តផរណានៅតែបន្តកើតមាន។ ទោះយ៉ាងនេះក្តី នៅឆ្នាំ២០១០ អតិផរណា បានកើនឡើងជាមធ្យម ៣,៥% ដោយសារជាចំបងមកពីការអនុវត្តគោលនយោបាយពង្រីកការផ្គត់ផ្គង់រូបិយវត្ថុ។ នៅត្រីមាសទី៤ ឆ្នាំ២០១០ អត្រាអតិផរណានៅកម្ពុជា កើនដល់ ៣,៣% ធៀបនឹង ១,៨% នៅត្រីមាសមុន។ អតិផរណានៅប្រទេសម៉ាឡេស៊ី សិង្ហបុរី និងថៃ កើនឡើងជាមធ្យម ២,៧% ស្របពេលដែលអតិផរណានៅឥណ្ឌូនេស៊ី កើនឡើង ៦,៣% និងនៅវៀតណាម កើនឡើង ១១%។ នៅប្រទេសចិន ហុងកុង កូរ៉េខាងត្បូង និងតៃវ៉ាន់ អតិផរណាកើនឡើងជាមធ្យម ៣,០%។ ក្នុងពេលដដែលនេះ អតិផរណាសហរដ្ឋអាមេរិក មាន ១,៣% និងនៅតំបន់អឺរ៉ូ-១២ មាន ២% ស្របពេលដែលជប៉ុន បានងើបផុតពីបរិត្តផរណា ជាមួយនឹងអត្រាអតិផរណា ០,១%។

អត្រាប្តូរប្រាក់ក្នុងប្រទេសអាស៊ាន កើនឡើងជាមធ្យម ៤,០% ពីមួយឆ្នាំទៅមួយឆ្នាំ ទល់នឹងដុល្លារអាមេរិក ខណៈដែលអត្រាប្តូរប្រាក់នៅបណ្តាប្រទេសអាស៊ីបូព៌ា កើន ៣,៦% ទល់នឹងដុល្លារអាមេរិក។ កំណើននេះ ទំនងជាបណ្តាលមកពីគោលនយោបាយពង្រីកការផ្គត់ផ្គង់រូបិយវត្ថុរបស់សហរដ្ឋអាមេរិក ដើម្បីជម្រុញសេដ្ឋកិច្ច ការមិនសូវទុកចិត្តពីកំណើនសេដ្ឋកិច្ចទៅអនាគត ទីផ្សារហ៊ុនបានចុះខ្សោយ និងឱនភាពគណនីចរន្ត។ ក្នុងត្រីមាសទី៤ ឆ្នាំ២០១០ មានការឡើងថ្លៃ ប្រាក់រៀល ២,៧% ប្រាក់រូពីយ៉ា ០,៣% ប្រាក់រីហ្គីត ១,៣% ដុល្លារសិង្ហបុរី ៤,៤% និងប្រាក់បាត ៥,២% ធៀបនឹងត្រីមាសមុន ប៉ុន្តែមានការចុះថ្លៃប្រាក់ដុងវៀតណាម ០,១%។

ក្នុងពេលដដែល ប្រាក់យន់ចិន និងដុល្លារហុងកុង ឡើងថ្លៃជាមធ្យម ០,៨% ហើយប្រាក់វ៉ុនកូរ៉េខាងត្បូង និងដុល្លារតៃវ៉ាន់ ឡើងថ្លៃ ៤,៥%។ ប្រាក់អឺរ៉ូ និងប្រាក់យេនជប៉ុន ក៏ឡើងថ្លៃជាមធ្យម ៣,៨% ដែរ។

## ថ្លៃទំនិញក្នុងទីផ្សារពិភពលោក

ក្នុងឆ្នាំ២០១០ ពោតឡើងថ្លៃជាមធ្យម ៩,៩% ពីមួយឆ្នាំទៅមួយឆ្នាំ ដល់ ១៨៣,៨ដុល្លារ/តោន ធៀបនឹង ១៦៧,៣ដុល្លារ/តោន ក្នុងឆ្នាំ២០០៩។ នៅត្រីមាសទី៤ ឆ្នាំ២០១០ ពោតឡើងថ្លៃ ៣៥,៦% ដល់ ២៣៨,៨ដុល្លារ/តោន ធៀបនឹងត្រីមាសទី៣។ កៅស៊ូ SMR 5 ឡើងថ្លៃ ៣៤,០% ដល់ ៤២៥៧,៣ដុល្លារ/តោន សណ្តែកសៀងឡើងថ្លៃ ១៣,៤% ដល់ ៤៨០,២ដុល្លារ/តោន ហើយអង្ករឡើងថ្លៃ ១៣,៤% ដល់ ៥៣១ដុល្លារ/តោន។ ដំណាលគ្នានេះដែរ ប្រេងដៅឡើងថ្លៃ ១២,៤% ដល់ ៨៤,២ ដុល្លារ/ធុង ប្រេងសាំងឡើងថ្លៃ ១១,០% ដល់ ០,៥៧២៣ដុល្លារ/លីត្រ ហើយម៉ាស៊ូតឡើងថ្លៃ ១៥% ដល់ ០,៦១៦៨ដុល្លារ/លីត្រ។

---

១ អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១០ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2006 | 2007 | 2008 | 2009 | | | | 2010 | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា | 10.6 | 10.2 | 6.8 | - | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.4 | 6.3 | 6.1 | 4.4 | 3.9 | 4.2 | 5.4 | 5.7 | 6.2 | 5.8 | 6.9 |
| ម៉ាឡេស៊ី | 5.9 | 6.3 | 4.6 | -6.2 | -3.9 | -1.2 | 4.5 | 16.9 | 8.9 | 5.3 | 4.8 |
| សិង្ហបុរី | 7.7 | 7.7 | 1.1 | -10.1 | -3.5 | 0.8 | 4.0 | 17.4 | 18.7 | 10.5 | 12.0 |
| ថៃ | 4.8 | 4.9 | 2.6 | -7.1 | -4.9 | -2.8 | 5.8 | 12.0 | 9.2 | 6.7 | 3.8 |
| វៀតណាម | 8.1 | 8.5 | 6.2 | 3.1 | 4.5 | 5.8 | 6.9 | 5.8 | 6.4 | 7.2 | 7.3 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន | 10.5 | 11.9 | 9.0 | 6.1 | 7.9 | 9.1 | 10.7 | 11.9 | 10.3 | 9.7 | 9.8 |
| ហុងកុង | 6.6 | 6.4 | 2.4 | -7.8 | -3.8 | -2.2 | 2.6 | 8.0 | 6.5 | 6.8 | 6.2 |
| កូរ៉េខាងត្បូង | 5.0 | 4.9 | 2.2 | -4.4 | -2.2 | 0.4 | 6.1 | 8.1 | 7.1 | 4.5 | 4.8 |
| តៃវ៉ាន់ | 4.6 | 5.2 | 0.1 | -10.2 | -7.5 | -1.3 | 8.4 | 14.6 | 12.9 | 9.8 | 6.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.7 | 2.9 | 0.9 | -2.5 | -4.8 | -4.7 | 0.1 | 0.6 | 1.7 | 1.9 | 2.0 |
| ជប៉ុន | 2.1 | 2.0 | -0.7 | -9.1 | 0.6 | -4.7 | -1.4 | 5.5 | 3.5 | 5.0 | 2.2 |
| សហរដ្ឋអាមេរិក | 3.3 | 2.2 | 1.1 | -2.6 | -3.9 | -2.5 | 2.6 | 2.8 | 2.9 | 2.3 | 2.8 |

*Sources: International Monetary Fund, Economist and countries' statistic offices. * Updated data*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១០ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | | | | 2010 | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា | 4.7 | 10.5 | 19.7 | 4.3 | -4.8 | -3.0 | 1.7 | 7.0 | 4.1 | 1.8 | 3.3 |
| ឥណ្ឌូនេស៊ី | 13.4 | 6.4 | 10.1 | 8.5 | 5.6 | 2.78 | 2.6 | 3.6 | 4.4 | 6.2 | 6.3 |
| ម៉ាឡេស៊ី | 3.7 | 2.0 | 5.3 | 3.7 | 1.3 | -2.23 | -0.2 | 1.3 | 1.6 | 1.9 | 2.1 |
| សិង្ហបុរី | 1.0 | 2.1 | 6.5 | 2.1 | -0.5 | -0.4 | -0.3 | 0.9 | 3.1 | 3.4 | 4.0 |
| ថៃ | 4.7 | 2.2 | 5.5 | -0.2 | -2.8 | -2.1 | 1.9 | 3.7 | 3.3 | 3.3 | 2.0 |
| វៀតណាម | 7.7 | 8.3 | 23.3 | 15.1 | 6.2 | 2.6 | 4.6 | 7.5 | 9.0 | 8.4 | 10.9 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន | 1.5 | 4.8 | 5.9 | -0.6 | 1.5 | -1.26 | 0.7 | 2.1 | 2.7 | 3.3 | 4.7 |
| ហុងកុង | 2.2 | 2.0 | 4.3 | 1.7 | -0.1 | -0.9 | 1.3 | 1.9 | 2.6 | 2.3 | 2.9 |
| កូរ៉េខាងត្បូង | 2.4 | 2.5 | 4.6 | 3.9 | 2.8 | 2.0 | 2.4 | 2.7 | 2.6 | 2.9 | 3.6 |
| តៃវ៉ាន់ | 0.6 | 1.8 | 3.2 | 0.0 | -0.8 | -1.3 | -1.3 | 1.3 | 1.1 | 0.4 | 1.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 2.1 | 3.3 | 1.0 | 0.9 | -0.34 | 0.4 | 1.1 | 1.5 | 1.7 | 2.0 |
| ជប៉ុន | 0.5 | 0.1 | 1.4 | -0.1 | -1.0 | -2.2 | -2.0 | -1.2 | -0.9 | -0.9 | 0.1 |
| សហរដ្ឋអាមេរិក | 3.2 | 2.9 | 3.8 | -0.2 | -0.9 | -1.6 | 1.4 | 2.3 | 1.8 | 1.2 | 1.3 |

*Sources: International Monetary Fund, Economist and National Institute of Statistics. * Updated data*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១០ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | | | | 2010 | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា (រៀល) | 4103.20 | 4062.70 | 4054.20 | 4108.00 | 4128.60 | 4164.40 | 4163.10 | 4180.11 | 4209.02 | 4236.69 | 4122.58 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9134.00 | 9419.00 | 9699.00 | 11,630.80 | 10,225.00 | 9887.00 | 9472.44 | 9266.93 | 9132.00 | 8995.11 | 8965.70 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.70 | 3.30 | 3.30 | 3.60 | 3.50 | 3.50 | 3.40 | 3.37 | 3.24 | 3.15 | 3.11 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.59 | 1.51 | 4.58 | 1.51 | 1.45 | 1.44 | 1.39 | 1.40 | 1.36 | 1.36 | 1.30 |
| ថៃ (បាត) | 37.90 | 32.22 | 33.36 | 35.29 | 33.98 | 33.96 | 33.30 | 32.90 | 32.33 | 31.63 | 29.99 |
| វៀតណាម (ដុង) | 15,994.00 | 16,030.00 | 16,382.00 | 16,954.00 | 17,801.00 | 17,841.00 | 18,472.00 | 18,825.67 | 18,993.00 | 19,485.00 | 19,499.48 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន (យ៉ន់) | 7.97 | 8.03 | 6.94 | 6.84 | 6.83 | 6.83 | 6.83 | 6.83 | 6.77 | 6.77 | 6.66 |
| ហុងកុង (ដុល្លារហុងកុង) | 7.77 | 7.80 | 7.78 | 7.75 | 7.75 | 7.75 | 7.75 | 7.76 | 7.78 | 7.77 | 7.76 |
| កូរ៉េខាងត្បូង (វ៉ុន) | 955.00 | 929.04 | 1137.23 | 1412.50 | 1273.90 | 1239.04 | 1167.77 | 1143.97 | 1166.04 | 1182.41 | 1132.85 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.50 | 32.85 | 31.54 | 34.00 | 33.10 | 32.77 | 32.29 | 31.93 | 31.90 | 31.90 | 30.36 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.70 | 0.84 | 0.76 | 0.71 | 0.70 | 0.68 | 0.72 | 0.79 | 0.77 | 0.74 |
| ជប៉ុន (យ៉េន) | 116.40 | 117.80 | 102.46 | 93.72 | 95.95 | 93.58 | 89.78 | 90.73 | 92.20 | 85.74 | 82.53 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៦-២០១០ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | | | | 2010 | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ពោត (US No. 2) - USA (USD/តោន) | 111.04 | 149.08 | 218.15 | 183.12 | 171.16 | 146.85 | 168.13 | 162.88 | 157.41 | 176.13 | 238.81 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 433.85 | 707.68 | 912.23 | 636.53 | 719.35 | 659.16 | 732.33 | N/A | N/A | N/A | N/A |
| កៅស៊ូ SMR 5 | 1996.30 | 2202.30 | 2586.30 | 1439.77 | 1638.77 | 1924.80 | 2536.03 | 3105.90 | 3083.73 | 3175.97 | 4257.27 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 282.00 | 305.36 | 615.32 | 522.13 | 499.45 | 307.31 | 569.00 | 565.67 | 461.33 | 468.33 | 531.00 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 213.88 | 294.59 | 460.41 | 434.40 | 420.10 | 411.18 | 390.43 | 372.68 | 370.95 | 406.88 | 480.24 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 61.58 | 69.25 | 95.44 | 42.34 | 57.46 | 68.32 | 73.86 | 75.73 | 77.00 | 74.91 | 84.17 |
| សាំង - US Gulf Coast (សេន/លីត្រ) | 47.70 | 53.58 | 62.22 | 31.97 | 43.11 | 46.92 | 49.64 | 53.87 | 54.43 | 51.54 | 57.23 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 51.35 | 55.51 | 76.20 | 34.17 | 40.51 | 46.46 | 51.03 | 53.87 | 55.13 | 53.64 | 61.68 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស[១]

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

អនុមតិគម្រោងវិនិយោគឯកជន បានធ្លាក់ចុះ ៦០% ពី ៥,៦ ពាន់លានដុល្លារក្នុងឆ្នាំ២០០៩ មកត្រឹម ២,៣ពាន់លានដុល្លារ ក្នុងឆ្នាំ២០១០។ ក្នុងត្រីមាសទី៤ ឆ្នាំ២០១០ អនុមតិគម្រោងទាក់ទងនឹងវិស័យកសិកម្មធ្លាក់ចុះ ៨៧% មកត្រឹម ៣៦,៧លានដុល្លារ ធៀបនឹងត្រីមាសមុន ស្របពេលដែលអនុមតិសម្រាប់វិស័យឧស្សាហកម្មកើនឡើង ៩៨% ដល់ ៨៧,៧លានដុល្លារ។ អនុមតិសម្រាប់វិស័យសេវាកម្ម កើនឡើងពីកម្រិតសូន្យ ដល់ ១០៩៦,២លានដុល្លារ ដោយមានសណ្ឋាគារ និងទេសចរណ៍ជាកត្តាជម្រុញដ៏សំខាន់។

ក្នុងរយៈពេលដដែល តម្លៃនៃគម្រោងសាងសង់ផ្ទះ និងភូមិគ្រឹះ ធ្លាក់ចុះ ៣២,៤% មកត្រឹម ៩,៥លានដុល្លារ តម្លៃនៃគម្រោងសាងសង់ផ្ទះល្វែង ធ្លាក់ចុះ ២០% មកត្រឹម ២០,៣លានដុល្លារ និងតម្លៃនៃគម្រោងសាងសង់ផ្សេងទៀតធ្លាក់ចុះ ៩៦% មកត្រឹម ៧៦,២លានដុល្លារ។

នៅត្រីមាសទី៤ ឆ្នាំ២០១០ ភ្ញៀវមកដល់កម្ពុជា កើន ២១% ដល់ ៧០៥.១០០នាក់ ធៀបនឹង ៥៨២.០០០នាក់ នៅត្រីមាសទី៣។ ភ្ញៀវមកដល់តាមផ្លូវអាកាស កើន ៣៣% ដល់ ៣៨៤.០០០នាក់ ហើយតាមផ្លូវគោក និង ផ្លូវទឹក កើន ៩,៤% ដល់ ៣២១.០០០នាក់។ នៅឆ្នាំ២០១០ ចំនួនទេសចរមកដល់សរុប កើន ១៦% ពី ២,២លាននាក់ ដល់ ២,៥លាននាក់។

ការនាំចេញសរុបសម្រាប់ឆ្នាំ២០១០ កើន ៥០% ពី ២,៤ពាន់លានដុល្លារ ដល់ ៣,៦ពាន់លានដុល្លារ។ ការនាំចេញសំលៀកបំពាក់ កើន ៥៦% ដល់ ៣,២ពាន់លានដុល្លារ ស្របពេលដែលការនាំចេញផលិតផលកសិកម្ម កើន ៦,៦% ដល់ ៣៤៦,៧ លានដុល្លារ។ នៅត្រីមាសទី៤ ឆ្នាំ២០១០ ការនាំចេញសំលៀកបំពាក់ កើន ០,៥% ធៀបនឹងត្រីមាសមុន ដល់ ៩៤២,៧លានដុល្លារ ដោយសារការបញ្ជាទិញពីសហរដ្ឋអាមេរិកធ្លាក់ចុះ ១,៣% ខណៈដែលការបញ្ជាទិញពីសហភាពអឺរ៉ុប អាស៊ាន ជប៉ុន និងប្រទេសដទៃទៀត កើនជាមធ្យម ៣,២%។ ក្នុងរយៈពេលដដែល ការនាំចេញផលិតផលកសិកម្ម កើន ១៩% ដល់ ១១៦,០លានដុល្លារ ការនាំចេញកៅស៊ូ កើន ៥០% ដល់ ៣៨,១លានដុល្លារ ការនាំចេញឈើ កើន ១១៣% ដល់ ១៨,៧លានដុល្លារ និងការនាំចេញត្រី កើន ៦៤% ដល់ ០,៨លានដុល្លារ។

ការនាំចូលសរុបក្នុងឆ្នាំ២០១០ កើន ១២% ដល់ ៦៧៧,១ លានដុល្លារ។ នៅត្រីមាសទី៤ ការនាំចូលប្រេងសាំង កើន ១០% ដល់ ៣០,៥លានដុល្លារ ហើយការនាំចូលប្រេងម៉ាសូតកើន ៥,១% ដល់ ៥០,៥លានដុល្លារ ប៉ុន្តែការនាំចូលសម្ភារៈសំណង់ ធ្លាក់ចុះ ១៧% មកត្រឹម ១៣,៨លានដុល្លារ ហើយការនាំចូលផលិតផលផ្សេងទៀត ធ្លាក់ចុះ ៨,៩% មកត្រឹម ៥៨២,៣លានដុល្លារ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៤ ឆ្នាំ២០១០ ចំណូលសរុប កើន ១៧% ធៀបនឹងត្រីមាសមុន ដល់ ១៦៧៥,០ពាន់លានរៀល ក្នុងនេះ ចំណូលចរន្ត កើន ៩,៧% ចំណូលពន្ធ កើន ០,៣% ចំណូលមិនមែនពន្ធ កើន ៦៦% ហើយចំណូលមូលធន កើន ២០៧៧%។ ក្នុងរយៈពេលដដែល ចំណាយសរុបធ្លាក់ចុះ ១៩% មកត្រឹម ១៩៤៥,០ ពាន់លានរៀល ចំណាយមូលធនធ្លាក់ចុះ ២៤% មកត្រឹម ៦៧៦,០ ពាន់លានរៀល និងចំណាយចរន្ត ធ្លាក់ចុះ ១៦% មកត្រឹម ១២៧០,០ពាន់លានរៀល។ ចំណាយលើបៀវត្សរ៍ កើនឡើង ០,៩% ខណៈដែលប្រាក់បំពេញខាតពីរដ្ឋាភិបាល និងប្រាក់ឧបត្ថម្ភខាងសង្គមកិច្ច ធ្លាក់ចុះ ៤២,៤% ហើយចំណាយចរន្តផ្សេងទៀត ធ្លាក់ចុះ ១៣% ។ ឱនភាពថវិកា មានចំនួន ២០៨,៦ ពាន់លានរៀល។

## អតិផរណា និងអត្រាប្តូរប្រាក់បរទេស

នៅត្រីមាសទី៤ ឆ្នាំ២០១០ អតិផរណានៅទីក្រុងភ្នំពេញ មានកម្រិត ៣,៣% ធៀបនឹង ១,៨% នៅត្រីមាសមុន ដោយសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៃអាហារ និងភេសជ្ជៈគ្មានជាតិស្រា មានកម្រិត ៤,១% ហើយសន្ទស្សន៍ថ្លៃដឹកជញ្ជូន មានកម្រិត ៣,១%។ ក្នុងរយៈពេលដដែល ប្រាក់រៀលឡើងថ្លៃ ២,៧% ទល់នឹងប្រាក់ដុល្លារអាមេរិក ០,៧% ទល់នឹងប្រាក់បាតថៃ និង ១,៤% ទល់នឹងប្រាក់ដុងវៀតណាម។ ប្រេងសាំង ឡើងថ្លៃ ២,៧% ដល់ ៤៥៣៥រៀល/លីត្រ ហើយប្រេងម៉ាស៊ូត ឡើងថ្លៃ ៣,៣% ដល់ ៤០៦៦រៀល/លីត្រ។

## ការវិវត្តរូបិយវត្ថុ

ក្នុងឆ្នាំ២០១០ រូបិយវត្ថុទូទៅ (M2) កើនជាមធ្យម ១៨% ពី ១៤.៣៧២,០ពាន់លានរៀល មកដល់ ១៨.៤៦៦,០ពាន់លានរៀល។ នៅត្រីមាសទី៤ ទ្រព្យសកម្មបរទេសសុទ្ធ ធ្លាក់ចុះ ១,២% មកត្រឹម ១៦.៦៩៨,០ពាន់លានរៀល ខណៈដែលទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ៤០% ដល់ ២៧៧៩,០ពាន់លានរៀល។ ក្នុងរយៈពេលដដែល ប្រាក់រៀលចរាចរ កើន ៥,២% ដល់ ៣២២១,០ពាន់លានរៀល ហើយរូបិយវត្ថុផ្សេងៗ កើន ២,៧% ដល់ ១៦.២៥៦,០ពាន់លានរៀល។

## ស្ថានភាពក្រីក្រ

យោងតាមអង្កេតពលករងាយរងគ្រោះរបស់ CDRI ក្នុងខែកុម្ភៈ ២០១១ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ ៩ក្រុម ក្នុងចំណោម ១០ក្រុម កើនឡើងគួរឲ្យកត់សម្គាល់ ធៀបនឹងខែដដែលនៅឆ្នាំមុន ខណៈពេលដែលប្រាក់ចំណូលប្រចាំថ្ងៃរបស់ពលករស៊ីឈ្នួលធ្វើស្រែបានធ្លាក់ចុះ។

១ អត្ថបទនេះ រៀបរៀងដោយលោក ថៃ វឌ្ឍនា កញ្ញា អ៊ួន វិមល និងលោកស្រី ប៉ុន ដូរីណា អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញ កើនឡើង ៤៧% ធៀបនឹងខែដដែលក្នុងឆ្នាំ២០១០ ដល់ ១១.៣៣៩រៀល ហើយចំណាយសរុបប្រចាំថ្ងៃពិតរបស់ពួកគេ ធ្លាក់ចុះ ៨,៧% មកដល់ ៤០៨១រៀល។ មាន ៩៥% នៃកម្មករសំណង់គ្មានជំនាញ បានឆ្លើយសម្ភាសន៍ប្រាប់ថា ខ្លួនមិនអាចសន្សំប្រាក់ទុកសម្រាប់ថ្ងៃអនាគតបានទេ ថ្វីបើប្រាក់ចំណូលកើនឡើង ហើយប្រាក់ចំណាយបានកាត់បន្ថយមួយចំនួន ហើយមានពលករ ៩០% និយាយថា ប្រាក់ចំណូលរបស់ខ្លួន គឺគ្រប់គ្រាន់សម្រាប់តែផ្គត់ផ្គង់ជីវភាពគ្រួសារដែលមានសមាជិកបួននាក់ជាមធ្យម។ ស្របគ្នានេះដែរ ប្រាក់ចំណូលរបស់កម្មករសំណង់មានជំនាញ បានកើនឡើងតិចតួច គឺ ៥,២% ដល់ ១២.៥៤០រៀល។ កម្មករសំណង់មានជំនាញភាគច្រើន បានធ្វើការងារនេះប្រមាណ ៥ ទៅ ៦ឆ្នាំមកហើយ។

ប្រាក់ចំណូលរបស់អ្នកបម្រើតុតាមភោជនីយដ្ឋាន កើន ២០% ដល់ ៦១៨០រៀល/ថ្ងៃ។ ប្រាក់នេះ គឺគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគេ។ ជាទូទៅ អ្នកបម្រើតុ មិនមានចំណាយប្រាក់អ្វីច្រើនទេ ព្រោះម្ចាស់ហាងដោះស្រាយផ្តល់អាហារ និងទីកន្លែងស្នាក់នៅឲ្យពួកគេ ប៉ុន្តែទោះយ៉ាងនេះក្តី ក៏បានកើនចំណាយប្រចាំថ្ងៃ ១២% ផងដែរ បើធៀបនឹងចំណាយកាលពីមុនត្រឹម ១៣៩៤រៀល/ថ្ងៃ។

ប្រាក់ចំណូលអ្នកលក់បន្លែតូចតាច កើនឡើង ១៧% ដល់ ៩១៨៨រៀល/ថ្ងៃ។ ដើមទុនជាមធ្យមសម្រាប់អាជីវកម្មរបស់ពួកគេ គឺ ៥៧.២៥០រៀល ប៉ុន្តែ ៥៣% នៃអ្នកលក់បន្លែបានឆ្លើយសម្ភាសន៍ ប្រាប់ថា ចំនួននេះមិនគ្រប់គ្រាន់ទេ។ ក្នុងចំណោមអ្នកលក់បន្លែតូចតាចដែលបានសម្ភាសន៍មាន ៨៣% ធ្វើចំណាកស្រុកមកពីខេត្ត ជាពិសេសខេត្តកណ្តាល ព្រៃវែង ស្វាយរៀង និងតាកែវ។ អ្នកលក់បន្លែតូចតាចភាគច្រើនជានារី ក្នុងនោះ ៨៣% បានរៀបការរួច ១៥% នៅលីវ និង ២% ជាស្ត្រីមេម៉ាយ។

ប្រាក់ចំណូលពិតរបស់អ្នកធាក់ស៊ីក្លូ កើនឡើង ១៣% ដល់ ១០.៦៧៨រៀល/ថ្ងៃ។ ម្យ៉ាងទៀត ចំណាយប្រចាំថ្ងៃរបស់ពួកគាត់ធ្លាក់ចុះ ៥,២% មកត្រឹម ៤៥៨៦រៀល/ថ្ងៃ។ អ្នកធាក់ស៊ីក្លូទាំង ៤០នាក់ដែលត្រូវបានអង្កេតសាកសួរ សុទ្ធតែជាមេគ្រួសារ។ មានតែ ២៨% នៃអ្នកធាក់ស៊ីក្លូបានឆ្លើយសម្ភាសន៍ប៉ុណ្ណោះ ដែលជាម្ចាស់ស៊ីក្លូខ្លួនឯង ហើយក្រៅពីនោះ សុទ្ធតែត្រូវជួលស៊ីក្លូពីគេ។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នករើសអេតចាយ កើនឡើង ១២% ដល់ ៦៩៦០រៀល ដោយសាររបស់អេតចាយ បានឡើងថ្លៃ។ ទោះយ៉ាងនេះក្តី អ្នករើសអេតចាយ ៦៥% និយាយថា ប្រភពរបស់អេតចាយបានធ្លាក់ចុះ។ ម្យ៉ាងទៀត មាន ៤២% បានឆ្លើយសម្ភាសន៍ប្រាប់ថា ស្ថានភាពគ្រួសាររបស់ពួកគេបានប្រែប្រួលអាក្រក់ជាងមុន តាំងពីពេលមកធ្វើការងារនេះ និងមាន ២៨% ប្រាប់ថាមានស្ថានភាពដូចមុន ហើយមាន ៣០% ប្រាប់ថាបានធូរធារជាងមុន។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មករកាត់ដេរ កើនជាមធ្យម ១១% ដល់ ៨៣៤៧រៀល។ ក្នុងចំណោមកម្មករកាត់ដេរ ១២០នាក់ ដែលបានឆ្លើយសម្ភាសន៍ មាន ៤១% និយាយថា ពួកគេមិនមានជំនាញអ្វីទេមុនពេលចូលធ្វើការងារនេះ ហើយមាន ៦០% ប្រាប់ថា ចង់ប្តូរការងារថ្មី ព្រោះសព្វថ្ងៃមិនអាចសន្សំប្រាក់សម្រាប់ពេលអនាគតបាន។

ប្រាក់ចំណូលរបស់ពលករស៊ីឈ្នួលធ្វើស្រែ ដែលតែងជាអ្នកទទួលបានប្រាក់ចំណូលទាបបំផុតក្នុងចំណោមក្រុមទាំង១០នោះ បានធ្លាក់ចុះ ៩,៩% មកត្រឹម ៤៨២៦រៀល/ថ្ងៃ។ ក្នុងចំណោមពលករស៊ីឈ្នួលធ្វើស្រែបានឆ្លើយសម្ភាសន៍ទាំងអស់ មាន ៥៥% គ្មានដីធ្វើស្រែទេ ហើយ ៤០% មានដីកសិកម្មទំហំតិចជាងមួយហិកតា។ ពួកគេភាគច្រើន បានចូលរៀនបឋមសិក្សា ប៉ុន្តែគ្មាននរណាម្នាក់បានទទួលសញ្ញាប័ត្រមធ្យមសិក្សាទេ។




## ឯកសារចេញផ្សាយថ្មីៗពីវិទ្យាស្ថាន CDRI

### លើកកម្ពស់អភិបាលកិច្ចធនធានទឹកនៅកម្ពុជា៖ ការវិភាគអ្នកពាក់ព័ន្ធ

*ស្វែងយល់អំពីតួនាទី ទស្សនវិស័យ និងបញ្ហាប្រឈមរបស់អ្នកពាក់ព័ន្ធ ដើម្បីគ្រប់គ្រងនិងអភិវឌ្ឍធារាសាស្ត្រ និងផ្ទៃរងទឹកភ្លៀងប្រកបដោយប្រសិទ្ធភាព*

ឯកសារនេះបានវិភាគទៅលើ តួនាទី ទំនាក់ទំនង និងទស្សនវិស័យរបស់អ្នកពាក់ព័ន្ធនានាក្នុងការងារគ្រប់គ្រង ធនធានទឹកនៅកម្ពុជា ដោយផ្តោតសំខាន់លើការគ្រប់គ្រងធារាសាស្ត្រ និងអាងផ្ទៃរងទឹកភ្លៀង។ ការវិភាគក៏បានផ្តោតទៅលើកម្រិតនៃភាពស្របគ្នា ឬគម្លាតគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធ ព្រមទាំងភាពស្របគ្នា ឬគម្លាតគ្នានៃតួនាទីផ្លូវការរបស់ពួកគេក្នុងការអនុវត្តជាក់ស្តែងដែរ។ ទិន្នន័យទទួលបានពីការធ្វើសម្ភាសន៍អ្នកពាក់ព័ន្ធសំខាន់ៗ អង្កេតស្ថានភាពជាក់ស្តែង ការពិភាក្សាតាមក្រុមគោលដៅ និងសិក្ខាសាលាផ្សព្វផ្សាយព័ត៌មាន ត្រូវបានយកមកវិភាគដើម្បីសម្រាំងយកបញ្ហាចម្បងទាក់ទងនឹងតួអង្គពាក់ព័ន្ធក្នុងការងារអភិបាលកិច្ចធនធានទឹកនៅកម្ពុជា និងសម្រាប់យកមកបំពេញចន្លោះប្រហោងក្នុងការយល់ដឹង។ ឯកសារនេះបានបន្តពិនិត្យស៊ីជម្រៅទៅលើភ្នាក់ងារ និងស្ថាប័នមួយចំនួនដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធនធាន ទឹក ដើម្បីស្វែងយល់ពីសក្តានុពល និងកម្រិតសមត្ថភាពនាពេលបច្ចុប្បន្ន។ គំហើញនៃការស្រាវជ្រាវ ត្រូវបានបង្ហាញឡើង តាមវិធីសាស្ត្រមួយដែលជួយឲ្យអ្នកធ្វើសេចក្តីសម្រេចចិត្តលើគោលនយោបាយសាធារណៈ អាចយកទៅធ្វើការប្រៀបធៀប និងវាយតម្លៃនូវជម្រើសគោលនយោបាយដ៏ចាំបាច់នានា។

តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៥-១០

| | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 26.8 | 498.0 | 135.6 | 92 | 175.3 | 0.0 | 176.1 | 94.4 | 165.7 | 41.4 | 278.0 | 36.7 |
| ឧស្សាហកម្ម | 914.6 | 365.3 | 709.1 | 724.9 | 257.7 | 39.4 | 60.6 | 685.5 | 247.7 | 54.5 | 44.3 | 87.7 |
| *កាត់ដេរ* | *174.4* | *89.4* | *170.7* | *142.8* | *16.4* | *35.0* | *21.9* | *14.2* | *13.1* | *21.3* | *29.3* | *50.0* |
| សេវាកម្ម | 155.5 | 2939.1 | 1742.5 | 10003.2 | 495.6 | 0.0 | 150.2 | 3475.8 | 89.5 | 121.6 | 0.0 | 1096.2 |
| *សណ្ឋាគារ និងទេសចរណ៍* | *102.6* | *345.0* | *1048.3* | *8758.1* | *254.1* | *0.0* | *150.2* | *0.0* | *3.78* | *14.0* | *0.0* | *1087.4* |
| សរុប | 1096.9 | 3802.4 | 2587.2 | 10570.9 | 928.6 | 39.4 | 386.3 | 4255.7 | 502.9 | 217.5 | 322.3 | 1220.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | -41.2 | -95.7 | 882.0 | 1001.7 | -91.2 | -56.8 | 48.2 | 278.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 275.6 | 246.6 | -32.0 | 308.6 | 266.5 | -99.0 | -91.5 | 169.3 | -59.8 | 452.0 | -16.6 | -71.3 |

*Including expansion project approvals. Source: Cambodian Investment Board*

តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៥-១០

| | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 45.5 | 33.1 | 79.1 | 154.7 | 32.1 | 6.7 | 15.6 | 9.8 | 5.1 | 7.5 | 14.1 | 9.5 |
| ផ្ទះល្វែង | 204.2 | 213.3 | 297.2 | 221.6 | 95.2 | 18.9 | 7.4 | 28.0 | 11.1 | 127.2 | 25.3 | 20.3 |
| ផ្សេងៗ | 109.1 | 76.8 | 259.6 | 740.9 | 53.7 | 36.7 | 68.4 | 29.0 | 35.2 | 67.4 | 38.9 | 76.2 |
| សរុប | 358.8 | 323.3 | 635.8 | 1117.0 | 181.1 | 62.3 | 91.4 | 66.8 | 51.4 | 202.1 | 78.4 | 106.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | -48.5 | -65.6 | 46.6 | -26.9 | -23.1 | 293.2 | -61.2 | 35.3 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 36.2 | -9.9 | 96.7 | 75.7 | 31.9 | -55.8 | -81.2 | -81.0 | -71.6 | 224.4 | 278.5 | 58.7 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

តារាង៣. ចំនួនអ្នកដំណើរមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៥-១០

| | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 856.5 | 1029.0 | 1296.5 | 1239.4 | 335.2 | 221.2 | 247.2 | 308.1 | 371.5 | 260.9 | 288.3 | 383.7 |
| តាមផ្លូវគោក និងទឹក | 565.1 | 672.9 | 718.6 | 881.9 | 287.1 | 243.0 | 240.2 | 279.5 | 312.2 | 276.6 | 293.8 | 321.4 |
| សរុប | 1421.6 | 1701.9 | 2015.1 | 2121.3 | 622.3 | 464.2 | 487.4 | 587.6 | 683.7 | 537.5 | 582.0 | 705.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | 7.7 | -25.4 | 5.0 | 20.6 | 16.4 | -21.4 | 8.3 | 21.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 34.7 | 19.7 | 28.4 | 5.3 | -3.4 | 2.2 | 9.4 | 1.7 | 9.9 | 15.8 | 19.4 | 20.0 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៥-១០

| | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 2452.5 | 2920.4 | 3160.1 | 3206.9 | 568.94 | 558.11 | 618.84 | 648.87 | 688.24 | 786.29 | 1036.17 | 1058.79 |
| ក្នុងនេះ៖ សម្លៀកបំពាក់* | 2352.8 | 2810.8 | 3050.2 | 3097.8 | 462.2 | 492.4 | 535.5 | 579.3 | 625.48 | 716.85 | 938.28 | 942.74 |
| *- សហរដ្ឋអាមេរិក* | *1555.6* | *1851.7* | *1959.9* | *1913.0* | *88.0* | *88.1* | *89.3* | *80.1* | *380.54* | *416.71* | *531.85* | *524.75* |
| *- សហភាពអឺរ៉ុប* | *506.9* | *603.0* | *660.9* | *693.4* | *108.6* | *128.3* | *125.7* | *113.8* | *137.22* | *184.83* | *239.40* | *248.03* |
| *- អាស៊ាន* | *70.7* | *80.4* | *90.3* | *99.6* | *51.0* | *55.1* | *62.1* | *152.1* | *2.20* | *1.87* | *2.85* | *2.99* |
| *- ជប៉ុន* | *25.0* | *40.6* | *30.1* | *26.5* | *110.9* | *112.8* | *149.3* | *128.3* | *19.82* | *14.86* | *25.53* | *26.25* |
| *- ប្រទេសផ្សេងៗ* | *194.6* | *235.1* | *309.0* | *365.3* | *103.7* | *108.1* | *109.1* | *105.0* | *85.70* | *98.58* | *138.64* | *140.72* |
| កសិកម្ម | 99.7 | 109.6 | 109.9 | 109.1 | 106.74 | 65.71 | 83.34 | 69.57 | 62.76 | 70.00 | 97.9 | 116.05 |
| *- កៅស៊ូ* | 36.7 | *41.5* | *41.0* | 35.8 | *11.79* | *8.27* | *15.08* | *16.49* | *11.94* | *13.81* | *25.4* | *38.07* |
| *- ឈើ* | 10.3 | *8.6* | *8.7* | 3.4 | *0.55* | *0.5* | *0.64* | *1.83* | *2.75* | *4.48* | *8.8* | *18.70* |
| *- ត្រី* | 10.1 | *5.9* | 3.2 | 2.3 | *0.83* | *0.85* | *1.11* | *1.2* | *0.81* | *0.66* | *0.5* | *0.82* |
| *- ផ្សេងៗ* | 42.6 | *53.6* | *57.0* | 67.6 | *93.57* | *56.09* | *66.51* | *50.05* | *47.26* | *51.15* | *63.2* | *58.46* |
| ការនាំចូលសរុប | 2513 | 512.2 | 554.8 | 1010.9 | 585.3 | 608.1 | 484.4 | 532.8 | 505.6 | 563.2 | 731.3 | 677.1 |
| ក្នុងនេះ៖ សាំង | 40.2 | 38.8 | 58.7 | 70.1 | 16.8 | 15.6 | 19.3 | 19.4 | 28.81 | 22.37 | 27.63 | 30.50 |
| ម៉ាស៊ូត | 93.1 | 113.0 | 122.8 | 113.5 | 34.2 | 40.0 | 46.0 | 43.1 | 49.81 | 55.44 | 48.04 | 50.48 |
| សម្ភារៈសំណង់ | 134.7 | 56.5 | 69.0 | 77.8 | 13.8 | 14.8 | 15.7 | 13.3 | 13.7 | 13.2 | 16.7 | 13.8 |
| ផ្សេងៗ | 2245 | 303.9 | 304.3 | 749.5 | 520.5 | 537.7 | 403.4 | 457.0 | 413.3 | 472.2 | 638.9 | 582.3 |
| ជញ្ជីងពាណិជ្ជកម្ម | -60.5 | 2408.2 | 2605.3 | 2196 | -16.36 | -49.99 | 134.44 | 116.07 | 182.64 | 223.09 | 304.87 | 381.69 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | -21.9 | -1.9 | 10.9 | 4.9 | 6.1 | 14.2 | 31.8 | 2.2 |
| ការនាំចេញសរុប | - | - | - | - | -36.1 | 3.9 | -20.3 | 10.0 | -5.1 | 11.4 | 29.8 | -7.4 |
| ការនាំចូលសរុប | - | - | - | - | -91.3 | 205.6 | -368.9 | -13.7 | 57.4 | 22.1 | 36.7 | 25.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 11.6 | 19.5 | 8.5 | 1.6 | -29.2 | 3.4 | -33.4 | -10.9 | 21.0 | 40.9 | 67.4 | 63.2 |
| ការនាំចេញសរុប | 12.0 | 19.1 | 8.2 | 1.5 | -40.5 | -48.4 | -52.8 | -41.9 | -13.6 | -7.4 | 51.0 | 27.1 |
| ការនាំចូលសរុប | 16.9 | -79.6 | 8.3 | 82.2 | -90.9 | -92.2 | -236.6 | -161.8 | -1216.4 | -546.3 | 126.8 | 228.8 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF (web site). *Updated data*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៥-១០ (ពាន់លានរៀល)

| | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 2625.0 | 3259.2 | 1146.1 | 5290.0 | 1101.7 | 1252.7 | 1184.7 | 1346.1 | 1536.8 | 1341.1 | 1436.0 | 1675.0 |
| ចំណូលចរន្ត | 2474.0 | 2881.8 | 1141.6 | 5210.7 | 1097.7 | 1245.7 | 1174.9 | 1337.7 | 1526.4 | 1330.9 | 1431.2 | 1570.5 |
| ចំណូលពន្ធ | 1911.0 | 2270.9 | 965.2 | 4409.9 | 947.4 | 1096.5 | 999.5 | 1224.1 | 1094.1 | 1143.8 | 1225.5 | 1229.6 |
| ពន្ធក្នុងស្រុក | - | - | 661.8 | 3248.4 | 712.0 | 838.7 | 731.8 | 808.5 | 820.3 | 890.9 | 916.9 | 905.5 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | 303.5 | 1161.5 | 235.4 | 257.8 | 268.0 | 303.4 | 273.7 | 253.0 | 308.6 | 324.1 |
| ចំណូលមិនមែនពន្ធ | 563.0 | 610.9 | 176.4 | 800.8 | 150.3 | 149.2 | 176.1 | 225.7 | 432.4 | 187.1 | 205.7 | 340.9 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | 13.6 | 78.0 | 13.1 | 9.7 | 27.5 | 14.3 | 237.0 | 20.2 | 19.5 | 14.5 |
| លក់ទំនិញ និងសេវា | - | - | 124.3 | 424.7 | 93.5 | 100.9 | 91.7 | 121.9 | 108.4 | 102.9 | 127.0 | 121.7 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | 38.5 | 298.2 | 43.7 | 38.6 | 56.5 | 89.5 | 84.0 | 61.0 | 59.2 | 204.8 |
| ចំណូលជាមូលធន | 152.0 | 377.4 | 4.5 | 79.3 | 4.0 | 7.0 | 9.8 | 8.4 | 10.4 | 10.2 | 4.8 | 104.5 |
| ចំណាយសរុប | 3295.0 | 4174.7 | 1689.7 | 6297.8 | 1650.6 | 1766.1 | 2089.5 | 1877.1 | 2129.4 | 2154.8 | 2390.3 | 1945.4 |
| ចំណាយជាមូលធន | 1328.0 | 1638.1 | 807.4 | 2574.4 | 693.6 | 607.1 | 759.2 | 634.9 | - | 913.0 | 887.0 | 675.6 |
| ចំណាយចរន្ត | 1967.0 | 2536.8 | 882.3 | 3809.0 | 752.4 | 1064.7 | 1290.4 | 1332.3 | 831.8 | 1168.1 | 1503.3 | 1269.8 |
| បៀវត្សរ៍ | 711.0 | 822.0 | 362.6 | 1397.0 | 327.4 | 515.5 | 526.6 | 642.5 | - | 545.6 | 562.4 | 567.4 |
| ឧបត្ថមធន និងជំនួយសង្គមកិច្ច | - | - | 194.2 | 927.1 | 217.3 | 185.9 | 272.6 | 195.6 | 213.3 | 253.2 | 401.5 | 231.4 |
| ចំណាយចរន្តផ្សេងទៀត | - | - | 325.5 | 1384.9 | 207.7 | 363.2 | 491.2 | 494.3 | 449.6 | 369.3 | 539.4 | 471.0 |
| សមតុល្យជាទូទៅ | -706.0 | -915.6 | -543.6 | -1007.8 | -548.9 | -513.4 | -904.8 | 90.2 | -592.6 | -813.7 | -954.2 | -207.3 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1127.0 | 1360.7 | 741.5 | 2055.1 | 507.8 | 326.7 | 484.5 | -531.0 | 270.8 | 746.0 | 409.1 | 419.3 |
| ហិរញ្ញប្បទានក្នុងស្រុក | -396.0 | -445.1 | -185.8 | -127 | -310.3 | 236.5 | 316.4 | 406.4 | 422.8 | 194.1 | 343.3 | -21.6 |

*Source: MEF web site.*

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៥-១០

| | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| (ខែតុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 5.8 | 4.7 | 5.8 | 19.7 | 4.3 | -4.8 | -3.0 | 1.7 | 7.0 | 4.1 | 1.8 | 3.3 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 8.6 | 6.4 | 9.9 | 33.1 | 6.1 | -5.2 | -2.7 | 1.8 | 7.8 | 3.6 | 1.9 | 4.1 |
| - ដឹកជញ្ជូន | 11.4 | 9.1 | 5.8 | 19.4 | -13.0 | -16.5 | -13.8 | 2.4 | 12.9 | 8.7 | 3.2 | 3.1 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4119.7 | 4119.0 | 4062.7 | 4058.2 | 4111.6 | 4128.6 | 4164.4 | 4157.3 | 4180.1 | 4209.0 | 4236.7 | 4122.6 |
| រៀលក្នុង ១ បាតថៃ | 102.6 | 108.7 | 122.8 | 123.5 | 116.6 | 119.2 | 122.9 | 126.0 | 127.0 | 129.9 | 138.3 | 137.3 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.8 | 25.1 | 25.0 | 24.8 | 23.6 | 23.3 | 23.5 | 23.0 | 22.3 | 22.1 | 21.4 | 21.1 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 54.0 | 70.6 | 83.2 | 105.9 | 105.6 | 110.7 | 123.2 | 133.8 | 133.9 | 142.9 | 143.5 | 165.7 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 2633.0 | 3140.0 | 3262.3 | 4555.2 | 2873.7 | 3056.9 | 3867.0 | 3381.9 | 3599.5 | 3835.1 | 3936.6 | 4066.1 |
| ថ្លៃសាំង (រៀល/លីត្រ) | 3442.0 | 4004.0 | 4005.0 | 4750.8 | 3112.6 | 3452.4 | 3371.1 | 3940.2 | 4163.0 | 4358.7 | 4415.5 | 4535.2 |

*Sources: NIS, NBC and CDRI*

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៥-១០ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 5475.0 | 7224.0 | 10735.0 | 10345.0 | 11222.0 | 12611.0 | 13869.0 | 14655.0 | 15514.6 | 12610.9 | 16903.0 | 16697.9 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -450.0 | -282.0 | 576.0 | 1513.3 | 1266.0 | 1249.0 | 1042.0 | 1573.0 | 1720.0 | 1785.3 | 1984.8 | 2778.9 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -421.0 | -953.0 | -1816.0 | -2987.0 | -3048.0 | -2889.0 | -2463.0 | -2252.0 | -2484.8 | -2362.7 | -2120.4 | -2126.6 |
| ឥណទានដល់ផ្នែកឯកជន | 2394.0 | 3630.0 | 6386.0 | 9894.0 | 9814.0 | 10129.0 | 10127.0 | 10532.0 | 11146.7 | 11859.1 | 12479.8 | 13331.2 |
| រូបិយវត្ថុទូទៅ M2 | 5025.0 | 6942.0 | 11311.0 | 11858.0 | 12488.0 | 13859.0 | 14912.0 | 16228.0 | 17234.5 | 18267.1 | 18887.8 | 19476.8 |
| រូបិយវត្ថុ M1 | 1323.0 | 1658.0 | 2052.0 | 2399.0 | 2545.0 | 2695.0 | 2773.0 | 3120.0 | 3148.5 | 3115.1 | 3061.7 | 3220.9 |
| រូបិយវត្ថុផ្សេងៗ | 3702.0 | 5285.0 | 9259.0 | 9459.0 | 9942.0 | 11164.0 | 12139.0 | 13108.0 | 14086.0 | 15152.0 | 15826.1 | 16255.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 16.1 | 38.1 | 62.9 | 4.8 | 3.7 | 9.1 | 18.7 | 36.9 | 38.0 | 31.8 | 26.7 | 20.0 |
| រូបិយវត្ថុ M1 | 14.7 | 25.3 | 23.8 | 16.9 | 6.5 | 9.2 | 18.7 | 30.1 | 23.7 | 15.6 | 10.4 | 3.2 |
| រូបិយវត្ថុផ្សេងៗ | 16.6 | 42.8 | 75.2 | 2.2 | 2.9 | 9.1 | 18.7 | 38.6 | 41.7 | 35.7 | 30.4 | 24.0 |

*Source: National Bank of Cambodia*

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | 2010 | | 2011 |
| | | | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | សីហា | វិច្ឆិកា | កុម្ភៈ |
| អ្នកធាក់ស៊ីក្លូ | 7469 | 8081 | 12628 | 8091 | 9413 | 9570 | 8404 | 8759 | 10678 | 8.6 | 21.7 | 13.4 |
| អ្នកលីសែង | 6545 | 8588 | 9005 | 9549 | 9953 | 9340 | 10525 | 9965 | 11232 | 29.0 | 7.8 | 12.9 |
| អ្នកលក់បន្លែតូចតាច | 6390 | 8220 | 9926 | 8273 | 7826 | 8062 | 8291 | 8821 | 9188 | -0.4 | 19.4 | 17.4 |
| អ្នករើសអេតចាយ | 4416 | 5426 | 4652 | 5857 | 6238 | 7407 | 6461 | 6628 | 6960 | -8.8 | 46.1 | 11.6 |
| អ្នកបំរើតុភោជនីយដ្ឋាន* | 4412 | 4482 | 4327 | 4646 | 5131 | 5380 | 6427 | 5448 | 6180 | 40.5 | 1.3 | 20.4 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5306 | 5516 | 8697 | 6197 | 5358 | 6260 | 6186 | 4912 | 4826 | 6.9 | 1.6 | -9.9 |
| កម្មកររោងចក្រកាត់ដេរ | 7649 | 7568 | 6554 | 7085 | 7557 | 7491 | 8470 | 7944 | 8347 | 14.3 | 6.2 | 10.5 |
| អ្នករត់ម៉ូតូឌុប | 8201 | 10634 | 15691 | 10685 | 11302 | 10274 | 10558 | 10278 | 11493 | 10.3 | 9.7 | 1.7 |
| កម្មករសំណង់គ្មានជំនាញ | 5918 | 6155 | 8779 | 8343 | 7699 | 9013 | 8744 | 9636 | 11339 | -7.4 | 22.6 | 47.3 |
| កម្មករសំណង់មានជំនាញ | 10316 | 11154 | 12710 | 12487 | 11924 | 11928 | 11738 | 12122 | 12540 | -1.5 | -3.6 | 5.2 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

*តពីទំព័រ ២៨* **ព័ត៌មានថ្មីៗ...**

Economic Research)។ ក្នុងកិច្ចប្រជុំនោះ លោកបានធ្វើបទបង្ហាញលើឯកសារមួយ ស្តីពី "សេដ្ឋកិច្ចនយោបាយនៃដំណើរឆ្ពោះទៅកាន់សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ និងការពង្រីកសមាហរណកម្មអាស៊ាន"ដោយផ្តោតសំខាន់លើបញ្ហានានាសម្រាប់បណ្តាប្រទេសលូតលាស់តិចជាងគេ (LDCs) នៃតំបន់អាស៊ាន ហើយនៅថ្ងៃបន្ទាប់ លោកនាយកប្រតិបត្តិ បានផ្តល់បទឧទ្ទេសនាមជាសាធារណៈមួយ ស្តីពី "ប្រទេសកម្ពុជា ការអភិវឌ្ឍ និងសមាហរណកម្មក្នុងតំបន់នៅមហាអនុតំបន់មេគង្គ និងអាស៊ាន៖ ការងារកំពុងដំណើរការ"។

នៅខែឧសភា CDRI បានដំណើរការសិក្ខាសាលាមួយស្តីពី "ការពិនិត្យពីកត្តាជម្រុញជោគជ័យសេដ្ឋកិច្ចនៅអាស៊ីបូព៌ា៖ មេរៀនសម្រាប់កម្ពុជា" ដែលជាផ្នែកមួយនៃគម្រោងស្រាវជ្រាវអំពីសមត្ថភាពរដ្ឋ ។ ភ្ញៀវកិត្តិយសពិសេស បណ្ឌិត Mahani Zainal Abidin នាយកប្រតិបត្តិនៃ ISIS ម៉ាឡេស៊ីបានចូលរួមធ្វើបទបង្ហាញមួយ ស្តីពី "តើប្រទេសម៉ាឡេស៊ីទទួលបានជោគជ័យក្នុងការអភិវឌ្ឍយ៉ាងដូចម្តេច៖ ការត្រួតពិនិត្យពីតួនាទីរបស់រដ្ឋ និងភាពជាអ្នកដឹកនាំនៃអតីតនាយករដ្ឋមន្ត្រី Mahathir Mohammad"។ នៅខែ មិថុនា CDRI បានផ្តល់នូវបទសង្ខេបមួយ ស្តីពី សេដ្ឋកិច្ចកម្ពុជា បញ្ហាប្រឈម និងយុទ្ធសាស្ត្រដោះស្រាយ ជូនដល់គណៈប្រតិភូនៃក្រសួងបង្រួបបង្រួមជាតិនៃសាធារណរដ្ឋកូរ៉េដែលដឹកនាំដោយសាស្ត្រាចារ្យ Yang Jae-Sung នៃមជ្ឈមណ្ឌលអប់រំសម្រាប់ការបង្រួបបង្រួមជាតិឡើងវិញ។

## ផ្នែកស្រាវជ្រាវ

*កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ (ETRC)*

"អង្កេតពលករងាយរងគ្រោះ អង្កេតថ្លៃទំនិញតាមខេត្ត និងគម្រោងធ្វើរោគវិនិច្ឆ័យលើកំណើន" កំពុងបន្តទៅមុខ និងមានដំណើរការយ៉ាងល្អ។ ឯកសារគោលគំនិតស្តីពី "ជោគជ័យនៃការកាត់បន្ថយភាពក្រីក្រនៅសាធារណៈរដ្ឋប្រជាមានិតចិន៖ ផលប៉ះពាល់ចំពោះប្រទេសកម្ពុជា និងជំនួយអភិវឌ្ឍន៍ផ្លូវការរបស់សាធារណៈរដ្ឋប្រជាមានិតចិន" ដែលជាសមាសធាតុទី៣ នៃគម្រោងបណ្តាញភាពក្រីក្រ បានសរសេរចប់ និងប្រគល់ជូន ADB នៅចុងខែឧសភា ដើម្បីសុំមតិយោបល់។ របាយការណ៍ចុងក្រោយនៃគម្រោង"ចរន្តពលករខុសៗគ្នាតម្រូវការនិងផលប៉ះពាល់ខុសៗគ្នា៖ ការគ្រប់គ្រងទេសន្តរប្រវេសន៍ពលកម្មអន្តរជាតិនៅអាស៊ាន" ដែលសិក្សាពីបញ្ហារៀបចំឲ្យស្របច្បាប់ឡើងវិញនូវពលករអន្តោប្រវេសន៍មិនទៀងទាត់នៅកម្ពុជា បានប្រគល់ជូនអ្នកសម្របសម្រួលគម្រោង គឺវិទ្យាស្ថានហ្វីលីពីនសម្រាប់ការសិក្សាពីការអភិវឌ្ឍ (PIDS)។ សិក្ខាសាលាផ្សព្វផ្សាយថ្នាក់ជាតិ និងថ្នាក់តំបន់នៃគម្រោងនេះ គ្រោងធ្វើឡើងនៅចុងខែមិថុនា។ របាយការណ៍ព្រៀងទី២ នៃគម្រោង "ការវិភាគពីវិនិយោគអន្តរជាតិក្នុងវិស័យកសិកម្មនៅកម្ពុជា" បានប្រគល់ជូន FAO ហើយ។ អត្ថបទស្តីពី "ការវាយតម្លៃផលប៉ះពាល់នៃប្រទេសចិន ទៅលើការកាត់បន្ថយភាពក្រីក្រក្នុងមហាអនុតំបន់មេគង្គ៖ ករណីប្រទេសកម្ពុជា" កំពុងរៀបចំសម្រាប់បោះពុម្ពផ្សាយជាលក្ខណៈអន្តរជាតិ ដោយ វិទ្យាស្ថានសិក្សាពីអាស៊ីអាគ្នេយ៍ (ISEAS) និងកំពុងស្ថិតក្នុងដំណើរការបកប្រែជាភាសាខ្មែរ សម្រាប់ការបោះពុម្ពផ្សាយជាឯកសារពិភាក្សារបស់ CDRI។

នៅខែមិថុនា ប្រទេសជាសមាជិកនៃបណ្តាញវិភាគអភិវឌ្ឍន៍ធ្វើការជួបប្រជុំនៅប្រទេសឡាវ ដើម្បីពិភាក្សាពីសកម្មភាពស្រាវជ្រាវបន្ត។ លទ្ធផលដំបូងៗនៃគម្រោង "ការវិភាគពីភាពក្រីក្រពុំរ៉ៃនៅជនបទកម្ពុជា៖ ព័ត៌មានពីទិន្នន័យអង្កេតជាបន្តបន្ទាប់ (Panel Data)"បានលើកយកមកបង្ហាញនៅក្នុងវេទិកាបណ្តាញស្រាវជ្រាវអភិវឌ្ឍន៍អាស៊ីបូព៌ាប្រចាំឆ្នាំ២០១០-១១ នៅថ្ងៃទី២៤-២៥ ឧសភា នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។ វេទិកាស្រាវជ្រាវអភិវឌ្ឍន៍ប្រចាំឆ្នាំលើកទី៤ ក្រោមប្រធានបទ "ការសម្រេចបានកំណើនមានលក្ខណៈរាប់បញ្ចូល សមធម៌សង្គម និងការអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់កម្ពុជា" ដែលគ្រោងធ្វើនៅថ្ងៃទី ៨-៩ កញ្ញា ២០១១ បច្ចុប្បន្នកំពុងផ្សព្វផ្សាយស្វែងរកអ្នកមានចំណាប់អារម្មណ៍ដែលចង់ធ្វើបទបង្ហាញគម្រោងពាក់ព័ន្ធផ្សេងៗ។ សម្រាប់គម្រោង "វិបត្តិហិរញ្ញវត្ថុសាកល និងភាពងាយរងគ្រោះនៅកម្ពុជា" អង្កេតគ្រួសារ និងដំណើរការរៀបចំទិន្នន័យ បានបញ្ចប់ដោយជោគជ័យ។ ក្រុមស្រាវជ្រាវបានចាប់ផ្តើមប្រើប្រាស់ទាំងទិន្នន័យអង្កេតគ្រួសារពាក់ព័ន្ធច្រើនវិស័យឆ្នាំ២០១១ និងទិន្នន័យអង្កេតជាបន្តបន្ទាប់លើ ៧៩៣គ្រួសារជ្រើសរើសឲ្យមានតុល្យភាព ដើម្បីពិនិត្យអំពីប្រធានបទស្រាវជ្រាវ ដូចជា ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកលទៅលើភាពក្រីក្រ/ទីផ្សារពលកម្មជនបទ តួនាទីនៃឥណទាន(មីក្រូឥណទាន)និងពិពិធកម្មប្រាក់ចំណូលនៅពេលមានវិបត្តិ ព្រមទាំងយុទ្ធសាស្ត្រដោះស្រាយហានិភ័យរបស់គ្រួសារនៅមុន និងក្រោយពេលមានវិបត្តិ។

*កម្មវិធីអភិបាលកិច្ចបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ (DGPSR)*

កម្មវិធីនេះ កំពុងអនុវត្តគម្រោងចំនួន ៦។ គម្រោង "ការប្រែប្រួលក្នុងសេដ្ឋកិច្ចកម្ពុជា៖ ការពិនិត្យវិភាគពីសមត្ថភាពរដ្ឋ" ព្យាយាមវែកញែក កំណត់ និងវាយតម្លៃពីសមត្ថភាព និងស្ថានភាពរបស់រដ្ឋនាបច្ចុប្បន្ន ស្វែងរកកត្តាដែលជះឥទ្ធិពលលើសមត្ថភាពរដ្ឋ និងផ្តល់គំនិតពីមធ្យោបាយកែលម្អសមត្ថភាពរដ្ឋ។ របាយការណ៍ព្រាងដំបូងបានបញ្ចប់ នៅពាក់កណ្តាលខែឧសភា ហើយក្រុមស្រាវជ្រាវ ក៏បានជួបប្រជុំពិគ្រោះយោបល់មួយលើកដែរ។ គម្រោង "ការវិភាគពីវិមជ្ឈការ និងវិសហមជ្ឈការ" ព្យាយាមកំណត់ពីនិន្នាការ និងអនាគតនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ (D&D) ក្នុងបរិបទកម្ពុជាដែលមានប្រព័ន្ធទាំងពីរនៅលាយឡំគ្នា និងស្វែងរកចម្លើយថា តើ D&D ជួយពង្រឹងរបបប្រជាធិបតេយ្យនៅកម្ពុជាដែរឬទេ។ ក្រុមស្រាវជ្រាវបានពិភាក្សាជាមួយក្រុមស្រាវជ្រាវមានការងារស្រដៀងគ្នា នៅដើមខែឧសភា និងកំពុងបង្ហើយអត្ថបទព្រាងដំបូងនៃឯកសារពិភាក្សា។

គម្រោង "អង្កេតមូលដ្ឋានអំពីរដ្ឋបាលថ្នាក់ក្រោមជាតិ" មានបំណងស្រាវជ្រាវពីគំនិត និងការយល់ឃើញរបស់សមាជិកក្រុមប្រឹក្សាឃុំចំពោះរដ្ឋបាលថ្នាក់ស្រុក និងខេត្ត (ក្រុមប្រឹក្សា និងគណៈអភិបាលស្រុក និងខេត្ត)។ ក្រុមស្រាវជ្រាវកំពុងសរសេររបាយការណ៍អង្កេត ហើយរំពឹងថា អាចចប់សព្វគ្រប់នៅចុងខែមិថុនា។ គម្រោង "អភិបាលកិច្ចដែនរងទឹកភ្លៀង និងបញ្ហាចោទក្នុងកិច្ចសហប្រតិបត្តិការ" សំដៅពិនិត្យពីកិច្ចសហប្រត្តិបត្តិការរវាងភាគីពាក់ព័ន្ធនានាក្នុងបរិបទនៃកំណែទម្រង់ D&D។ ក្រុមស្រាវជ្រាវគម្រោងនេះ បានបញ្ចប់របាយការណ៍ព្រាងដំបូងរួចរាល់ហើយ។ ការស្រាវជ្រាវពី "ការអនុវត្តអភិបាលកិច្ចធារាសាស្ត្រនៅកម្ពុជា" ធ្វើអង្កេតលើកម្រិតស៊ីគ្នារវាងរបៀបរៀបចំអភិបាលកិច្ច និងតម្រូវការចាំបាច់ ដែលផុសចេញពីរបៀបរៀបចំរូបវ័ន្តនៃប្រព័ន្ធធារាសាស្ត្រទាំងនោះ។ របាយការណ៍ព្រាងពេញលេញដំបូង បានបញ្ចប់ និងប្រគល់ជូនទីប្រឹក្សាដើម្បីសុំមតិយោបល់។ ការពិនិត្យឡើងវិញនូវកម្មវិធីវិនិយោគបីឆ្នាំ (IP3) និងការកសាងទំនាក់ទំនងជាមួយ NCDD គឺជាផ្នែកមួយនៃគម្រោង ដើម្បីធ្វើបច្ចុប្បន្នភាពនូវការអនុវត្ត IP3 និង D&D ហើយដំណើរការនេះកំពុងវិវត្តទៅមុខយ៉ាងល្អ។ អត្ថបទសង្ខេបនៃការសិក្សានេះ បានរៀបចំឡើង កាលពីដើមខែមិថុនា សម្រាប់ការបោះពុម្ពផ្សាយ។ ការសិក្សាមួយចំនួន រួមមានផលប៉ះពាល់នៃ D&D ទៅលើការកាត់បន្ថយភាពក្រីក្រ ការប្រែប្រួលនៃភាពជាប្រជាពលរដ្ឋក្រោមកំណែទម្រង់ D&D សមត្ថភាពរដ្ឋបាលលើផ្នែកពន្ធដារ ការសិក្សាតាមដានបែបគុណភាពលើ D&D ការសិក្សាលើសមត្ថភាពថ្នាក់ស្រុក និងការសិក្សាតាមដានលើសមត្ថភាពរដ្ឋ/គ្រឹះស្ថាន កំពុងស្ថិតក្នុងការពិចារណា។

### កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ (PARD)

កម្មវិធីនេះ បានបញ្ចប់គម្រោងចំនួន ២ និងកំពុងអនុវត្តគម្រោងចំនួន ៤។ របាយការណ៍សម្រាប់គម្រោង "ភាពរលូនគ្នាខាងគោលនយោបាយសម្រាប់ការអភិវឌ្ឍជនបទ និងកសិកម្ម" បានបញ្ចប់ដោយជោគជ័យក្នុងខែមេសា និងកំពុងចាប់ផ្តើមរៀបចំបោះពុម្ពផ្សាយជាឯកសារពិភាក្សារបស់ CDRI។ គម្រោង "ការសិក្សាពីឌីណាមិកនៃភាពក្រីក្រ (PDS)" ដែលជាគម្រោងរួមគ្នារវាង PARD និង ETRC បានចប់សព្វគ្រប់ នៅខែមេសា។ សម្រាប់គម្រោង "ការវាយតម្លៃពីផលប៉ះពាល់នៃអង្គការកសិករលើសន្តិសុខស្បៀងសម្រាប់ជនក្រីក្រនៅជនបទ" ក្រុមស្រាវជ្រាវបានបញ្ចប់ដំណាក់កាលត្រៀម និងការប្រមូលទិន្នន័យបឋមនៅកន្លែង (ទាំងទិន្នន័យបែបគុណភាព និងបែបបរិមាណ) ហើយការសំអាតទិន្នន័យ ការដាក់លេខកូដ និងការវិភាគ កំពុងដំណើការ។

គំរូស្រាវជ្រាវសម្រាប់គម្រោង "ការកសាងវិធីសាស្ត្រវាយតម្លៃផលប៉ះពាល់សម្រាប់សកម្មភាពដោះមីននៅកម្ពុជា" បានចប់សព្វគ្រប់។ របាយការណ៍បច្ចេកទេស ខាង UNDP និងអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន (CMAA) ត្រូវបានទទួលយកហើយ និងបានបន្ថរយៈពេលគម្រោងចំនួន ៣ខែទៀត ដើម្បីធ្វើតេស្តដល់កន្លែង នូវឧបករណ៍វាយតម្លៃផលប៉ះពាល់ដែលបានដាក់ស្នើ។ គម្រោងរយៈពេល៣ឆ្នាំស្តីពី "គោលនយោបាយកសិកម្មសម្រាប់ប្រព័ន្ធកសិកម្មផ្អែកលើដំណាំស្រូវនៅកម្ពុជា និងឡាវ" ដែលទទួលមូលនិធិពី មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) គ្រោងចាប់អនុវត្តនៅខែមិថុនា។ សិក្ខាសាលាដំបូងដើម្បីកំណត់ផែនការ និងសកម្មភាពស្រាវជ្រាវគ្រោងធ្វើនៅប្រទេសឡាវ នៅខែសីហា ២០១១។ គម្រោង "ការលើកកម្ពស់សមភាពយេនឌ័រនៅទីផ្សារពលកម្ម ដើម្បីឲ្យកំណើនមានលក្ខណៈរាប់បញ្ចូលកាន់តែខ្លាំង" ដែលទទួលមូលនិធិពី ADB បានចាប់ផ្តើមនៅខែឧសភា។ គម្រោងរយៈពេល ១៥ខែនេះ ចែកជាអនុគម្រោង ២៖ សមភាពយេនឌ័រ និងសេដ្ឋកិច្ចពលកម្ម។

### កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន (NRE)

គម្រោង "ការកសាងសមត្ថភាពសហគមន៍សម្រាប់ការផ្តួចផ្តើមគំនិតកាត់បន្ថយភាពក្រីក្រនៅតំបន់អាងទន្លេសាប" បានចប់សព្វគ្រប់។ មជ្ឈមណ្ឌលធនធានទន្លេសាប (LRC) ដែលជាលទ្ធផលយ៉ាងសំខាន់មួយនៃគម្រោងនេះ និងមានទីតាំងនៅក្នុងបណ្ណាល័យ CDRI កំពុងដំណើរការទៅមុខយ៉ាងរលូន។ កម្មវិធីនេះកំពុងអនុវត្តគម្រោងចំនួន ៤។ ក្រុមស្រាវជ្រាវនៃគម្រោង "កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក (WRMRCDP)" បានរៀបចំទស្សនកិច្ចដល់កន្លែងឲ្យកសិករ និងអ្នកតំណាងអាជ្ញាធរមូលដ្ឋាន មកពីខេត្តកំពង់ធំ កំពង់ឆ្នាំង និងពោធិ៍សាត់ ចុះទៅពិនិត្យពីរបៀបរបបគ្រប់គ្រងធារាសាស្ត្រមួយនៅខេត្តតាកែវ ដើម្បីចែករំលែក និងរៀនសូត្រនូវសកម្មភាពល្អៗពីគ្នាទៅវិញទៅមក។ ឯកសារសង្ខេបគោលនយោបាយចំនួន ២ បានបោះពុម្ពផ្សាយ និងឯកសារពិភាក្សាមួយច្បាប់បានធ្វើចេញសម្រាប់ការបោះពុម្ពផ្សាយ ហើយឯកសារពិភាក្សាចំនួន ២ ទៀតកំពុងបញ្ចប់។ នាបច្ចុប្បន្ន ក្រុមស្រាវជ្រាវកំពុងរៀបចំសិក្ខាសាលាពិគ្រោះយោបល់ក្នុងខេត្តគោលដៅចំនួន ៣ និងសិក្ខាសាលាថ្នាក់ជាតិមួយ ដើម្បីផ្សព្វផ្សាយពីលទ្ធផលនៃការស្រាវជ្រាវក្នុងទម្រង់ជាឯកសារពិភាក្សា អត្ថបទសង្ខេបសម្រាប់គោលនយោបាយ និងវគ្គសិក្សាមាន ៥កម្រិត ដែល WRMRCDP បានបង្កើតឡើងសម្រាប់បញ្ចូលជាផ្នែកមួយ នៃកម្មវិធីសិក្សារបស់ដេប៉ាតឺម៉ង់វិទ្យាសាស្ត្របរិស្ថាននៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP)។ ឯកសារពិភាក្សាសម្រាប់គម្រោង "ព្រៃតំបន់ត្រូពិចសម្រាប់ការកាត់បន្ថយភាពក្រីក្រ-ការវិភាគទិន្នន័យតាំងពីកម្រិតគ្រួសារដល់កម្រិតសាកល" ដែលមានទិសដៅពង្រីកចំណេះដឹងស្តីពីតួនាទីព្រៃតំបន់ត្រូពិចក្នុងការកាត់បន្ថយភាពក្រីក្រ បានបញ្ចប់រួចរាល់ ហើយលទ្ធផល នឹងមានបង្ហាញក្នុងសិក្ខាសាលាមួយនៅប្រទេសកម្ពុជា និងសិក្ខាសាលាបច្ចេកទេស ព្រមទាំងសន្និសីទគោលនយោបាយនៅចក្រភពអង់គ្លេស ដែលគ្រោងធ្វើនៅខែមិថុនា។

សម្រាប់គម្រោង "ការពិនិត្យតាមដានផលប៉ះពាល់សង្គម និងអង្កេតមូលដ្ឋានវាយតម្លៃភាពងាយរងគ្រោះ" ដែលស្វែងយល់ពីស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច និងកម្រិតពឹងផ្អែករបស់ប្រជាជននៅតាមដងទន្លេមេគង្គទៅលើធនធានទឹក គឺបានបញ្ចប់ការប្រមូល និងបញ្ចូលទិន្នន័យ ហើយបច្ចុប្បន្ន ក្រុមស្រាវជ្រាវកំពុងវិភាគពីលទ្ធផលស្រាវជ្រាវដំបូង និងរៀបចំសរសេររបាយការណ៍។ ក្រុមស្រាវជ្រាវ បានអនុវត្តការពិភាក្សាតាមក្រុមស្នូលនៅតំបន់

អេកូឡូស៊ីសំខាន់ៗចំនួន៤ សម្រាប់គម្រោង "កសិកម្ម និងការប្រែប្រួលអាកាសធាតុ" ដែលជាគម្រោងរួមគ្នាជាមួយ PARD និងទទួលមូលនិធិពីវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ (IFPRI)។ ការសិក្សានេះ ធ្វើវិភាគអំពីកសិកម្ម និងសន្តិសុខស្បៀង ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុក្នុងន័យធំទូលាយ ដោយកំណត់ពីឧបសគ្គក្នុងការលើកកម្ពស់ទិន្នផល និងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ដែលកសិករកំពុងជួបប្រទះនាពេលបច្ចុប្បន្ន។

កម្មវិធីអភិវឌ្ឍន៍សង្គម (SD)

ក្រុមស្រាវជ្រាវកំពុងអនុវត្តគម្រោងចំនួន ៣។ អត្ថបទកែសម្រួល និងក្របមុខសៀវភៅ "ការលើកកម្ពស់លទ្ធផលក្នុងវិស័យសុខាភិបាល៖ ស្ថាប័ន សន្ទុះចិត្ត និងការលើកទឹកចិត្ត" ខាង ISEAS បានបញ្ជូនមកវិញហើយសម្រាប់ការពិនិត្យជាចុងក្រោយ។ ដោយបានមូលនិធិពីសាកលវិទ្យាល័យស្រាវជ្រាវ (URC) សៀវភៅនេះគឺសម្រាប់ចងក្រង និងផ្សព្វផ្សាយនូវឯកសារស្រាវជ្រាវដែលបានបង្ហាញក្នុងសន្និសីទអន្តរជាតិលើវិស័យសុខាភិបាលរបស់ CDRI កាលពីខែមេសា ២០១០។ សម្រាប់គម្រោងគំនិតផ្តួចផ្តើម EQUITAP[១] ក្រុមស្រាវជ្រាវបានបញ្ជូនលទ្ធផលវិភាគ (លើកលែងការវិភាគអត្ថប្រយោជន៍ ដែលមិនអាចធ្វើបានដោយសារមានទិន្នន័យមិនគ្រប់គ្រាន់) ទៅឲ្យអ្នកសម្របសម្រួល គឺវិទ្យាស្ថានសម្រាប់គោលនយោបាយសុខាភិបាលនៃប្រទេសស្រីលង្កា។ ក្រោមជំនួយហិរញ្ញវត្ថុពីទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ (AusAID) គម្រោង EQUITAP បានចប់សព្វគ្រប់នៅចុងខែឧសភា ដោយបានផ្តល់ការវិភាគលើទិន្នន័យអង្កេតគ្រួសារមានស្រាប់ ដើម្បីប៉ាន់ស្មានពីផលប៉ះពាល់ផ្សេងៗដែលធ្វើឲ្យចុះក្រនិងមហន្តរាយ ការវិវត្តទៅមុខ ភាពខុសគ្នាក្នុងការប្រើប្រាស់សេវាថែទាំសុខភាព និងអត្ថប្រយោជន៍ទទួលបានពីចំណាយរដ្ឋាភិបាល។ ក្រុមស្រាវជ្រាវបាននិងកំពុងអនុវត្តគម្រោងស្រាវជ្រាវរយៈពេល ៦ឆ្នាំ ស្តីពី "ការកសាងប្រព័ន្ធសុខាភិបាលសម្រាប់ជនក្រីក្រក្នុងពេលកសាងប្រទេសឡើងវិញ ក្រោយការបញ្ចប់ទំនាស់" ឬហៅកាត់ថា "REBUILD (ការកសាងជាថ្មី)" ដែលទទួលបានមូលនិធិពី ក្រសួងអភិវឌ្ឍន៍អន្តរជាតិអង់គ្លេស (DFID-UK) និងមាន Liverpool School of Tropical Medicine នៃចក្រភពអង់គ្លេស ជួយដឹកនាំ ដើម្បីស្វែងរកភស្តុតាងល្អៗ ជួយរួមចំណែកលើកកម្ពស់សុខភាពប្រជាជនក្រីក្រខ្លាំងក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ នៅឆ្នាំដំបូងនេះ ក្រុមស្រាវជ្រាវនឹងធ្វើការរៀបចំផែនការស្រាវជ្រាវចំនួន ៣៖ ១) ការវិភាគចំណាយរបស់គ្រួសារក្រីក្រលើការថែទាំសុខភាព ២) គ្រឿងលើកទឹកចិត្តសម្រាប់បុគ្គលិកក្នុងវិស័យសុខាភិបាល និង ៣) ការគ្រប់គ្រង និងការអនុវត្តកិច្ចសន្យា។ សិក្ខាសាលាផ្សព្វផ្សាយមួយសម្រាប់អ្នកពាក់ព័ន្ធសំខាន់ៗ គ្រោងធ្វើឡើងនៅចុងខែមិថុនា។

សកម្មភាពនៃកម្មវិធីបណ្តុះបណ្តាលជំនាញកសាងសមត្ថភាព បានចប់សព្វគ្រប់ ហើយរបាយការណ៍ប្រចាំឆ្នាំ បានប្រគល់ជូនម្ចាស់ជំនួយ Oxfam Novib។ ក្រុមបណ្តុះបណ្តាលបានប្តូរទៅខាងផ្នែកគ្រប់គ្រងចំណេះដឹងអភិវឌ្ឍន៍វិញ។

១ EQUITAP ឬ Equity in Asia-Pacific Health System (សមធម៌ក្នុងប្រព័ន្ធសុខាភិបាលនៅអាស៊ីប៉ាស៊ីហ្វិក) ជាកិច្ចប្រឹងប្រែងរួមគ្នារបស់អ្នកស្រាវជ្រាវជាង ១៥ក្រុម នៅអាស៊ី និង អឺរ៉ុប ដើម្បីពិនិត្យពីសមធម៌ក្នុងប្រព័ន្ធសុខាភិបាលជាតិនានានៅអាស៊ីប៉ាស៊ីហ្វិក។ កិច្ចសហការនេះ រួមមាន ការកសាងឧបករណ៍សម្រាប់ស្រាវជ្រាវ និង ការវាយតម្លៃជាក់ស្តែងលើការអនុវត្តប្រព័ន្ធសុខាភិបាលជាតិនានា។

*តពីទំព័រ ១៧* **អង្កេតស្តីពីសមត្ថភាព ......**

ធម្មជាតិ និងការគ្រប់គ្រងធនធានធម្មជាតិ។ ការយល់ដឹង និងយុទ្ធសាស្ត្រទប់ទល់របស់ពួកគាត់គួរតែពង្រឹងឡើងតាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលអំពី ការសម្របខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុ។

## ឯកសារយោង


ADB (2009), "Fact Sheet 2009" (Phnom Penh: ADB)

Blagescu, Minca & John Young (2006), *Capacity Development for Policy Advocacy: Current thinking and approaches among agencies supporting Civil Society Organisations*, Working Paper 260 (London: ODI)

Em Sorany (2008), "Attributes of Knowledge Sharing among Rice Farmers in Ou Saray, Takeo, Cambodia", Master's thesis (Los Banos: University of the Philippines)

Em Sorany & Kim Sour (2011), "The Commune Capacity and Readiness Survey" (Phnom Penh: CDRI)

Kim, N. & R. Henke (2005), "Commune Councils in Cambodia: A National Survey on Their Functions and Performance with Special Focus on Conflict Resolution" (Phnom Penh: Asia Foundation)

Royal Government of Cambodia (2008), "Rectangular Strategy Phase 2" (Phnom Penh: RGC)

Rusten, Caroline, Kim Sedara, Eng Netra & Pak Kimchoeun (2004) "The Challenges of Decentralisation Design in Cambodia", Monograph (Phnom Penh: CDRI)

Tariq H. Niazi (2011), "Sector Study Report on Deconcentration and Decentralisation Reforms in Cambodia: Recommendations for an Institutional Framework" (Metro Manila: ADB)

Thon Vimealea, Ou Sivhuoch, Eng Netra and Ly Tem (2009), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces*, CDRI Working Paper No. 42 (Phnom Penh: CDRI)

Zulueta, F.M. & Costales, N.E.B. (2006), "Methods of Research Thesis-writing and Applied Statistics", (Metro Manila: Navotas Press)

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ផ្នែកគ្រប់គ្រង

ក្នុងរយៈពេល២០ឆ្នាំកន្លងទៅនេះ CDRI បានធ្វើកិច្ចសហការប្រកបដោយជោគជ័យជាមួយដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគីជាច្រើន។ ដៃគូសហការដ៏ខ្លាំងក្លាបំផុតរបស់ CDRI ពិសេសនៅទសវត្សរ៍ចុងក្រោយនេះ គឺទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) ដែលបានផ្ដល់ការគាំទ្រដ៏មានតម្លៃក្នុងរយៈពេលវែងសម្រាប់កម្មវិធីស្រាវជ្រាវរបស់ CDRI ជាពិសេសកម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់សាធារណៈ ព្រមទាំងសម្រាប់ប្រតិបត្តិការនានា ដូចជា បណ្ណាល័យ ការបោះពុម្ពជាភាសាខ្មែរ និងអង់គ្លេស បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ITC) និងសំខាន់បំផុតគឺ ការកសាងសមត្ថភាពអ្នកស្រាវជ្រាវ។ Sida ក៏បានប្ដេជ្ញាចិត្តផ្ដល់ជំនួយគាំទ្របន្ថែមក្នុងអំឡុងពេលអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-១៥ របស់វិទ្យាស្ថាន CDRI ផងដែរ។

នៅថ្ងៃទី២១ មិថុនា ២០១១ CDRI និង Sida បានរួមគ្នាបង្កើតការជួបជុំពិគ្រោះយោបល់មួយ ជាមួយដៃគូអភិវឌ្ឍន៍សំខាន់ៗនៅកម្ពុជា ស្ដីពីដំណើរឆ្ពោះទៅរកជំនួយគាំទ្រកាន់តែប្រសើរពីដៃគូអភិវឌ្ឍន៍សម្រាប់វិទ្យាស្ថាន CDRI ដែលដឹកនាំដោយបណ្ឌិត សុខ ស៊ីផាន់ណា ជាប្រធានក្រុមប្រឹក្សាភិបាលរបស់ CDRI។ ផ្អែកលើការប្ដេជ្ញាចិត្តនៃដៃគូអភិវឌ្ឍន៍របស់កម្ពុជាចំពោះសុខដុមនីយកម្ម និងការតម្រឹមតាមគោលនយោបាយក្នុងប្រទេស CDRI និង Sida យល់ឃើញថា នេះជាពេលសមគួរ ដើម្បីស្វែងរកជំនួយគាំទ្រ ដែលមានលក្ខណៈកាន់តែប្រសើរសម្រាប់ការស្រាវជ្រាវ និងប្រតិបត្តិការរបស់ CDRI ស្របតាមយុទ្ធសាស្ត្រស្រាវជ្រាវប្រទេសកម្ពុជាឆ្នាំ២០២០ និងផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំរបស់ CDRI។ ហើយចាប់ពីពេលនេះ រហូតដល់ចុងឆ្នាំ២០១១ ត្រូវបន្តស្វែងរកឱកាសល្អ ដើម្បីរៀបចំឲ្យមានជំនួយគាំទ្រជាដៃគូកាន់តែច្រើន និងមានការសម្របសម្រួលកាន់តែប្រសើរ។

កាលពីថ្ងៃទី៥ ឧសភា ២០១១ លោកនាយកប្រតិបត្តិនៃ CDRI បានអញ្ជើញទៅប្រទេសសិង្ហបុរី ដើម្បីចូលរួមធ្វើជាប្រធានវគ្គមួយក្នុងកិច្ចប្រជុំដែលផ្ដួចផ្ដើមឡើងដោយ វិទ្យាស្ថានសិក្សាពីតំបន់អាស៊ីអាគ្នេយ៍នៃប្រទេសសិង្ហបុរី ក្រោមប្រធានបទ កិច្ចប្រជុំតុមូលអាស៊ានឆ្នាំ២០១១៖ ការពង្រឹងទំនាក់ទំនងអាស៊ាន។ កាលពីថ្ងៃទី៩-១០ ឧសភា នេះដែរ ក្នុងសិក្ខាសាលាមួយនៅឯការិយាល័យធនាគារ ADB នៅក្រុងបាងកក លោកនាយកប្រតិបត្តិបានធ្វើបទបង្ហាញពីឯកសារព្រៀងរបស់ CDRI ស្ដីពីសាវតារប្រទេសកម្ពុជា សម្រាប់ផ្ដល់ព័ត៌មានដល់ការសិក្សារបស់វិទ្យាស្ថាន ADB នៃធនាគារ ADB ក្រោមចំណងជើងថា អាស៊ាន ឆ្នាំ២០៣០៖ ការរីកលូតលាស់ទាំងអស់គ្នាដើម្បីវិបុលភាពរួម ។ នៅថ្ងៃទី២៤ ឧសភា លោកនាយកប្រតិបត្តិ បានទៅចូលរួមកិច្ចប្រជុំអន្តរជាតិមួយនៅទីក្រុង Taipei ដែលរៀបចំឡើងដោយ វិទ្យាស្ថានជុងហ៊្វា សម្រាប់ការស្រាវជ្រាវសេដ្ឋកិច្ច (Chung-Hua Institution for

*(តទៅទំព័រ ២៥)*

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ទស្សនាវដ្ដី
អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៥ លេខ២ ខែមេសា~មិថុនា ឆ្នាំ២០១១

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្ដល់ជូននូវមូលវិចារឯករាជ្យស្ដីពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន ។ អ្នកនិពន្ធ ត្រូវទាក់ទង វបសអ មុននឹងផ្ដល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☞ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@cdri.org.kh
website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសំរួល: យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា និង ម៉េន ច័ន្ទធីតា
ជំនួយការកែសំរួល: ខេង សេង និង អ៊ឹង សុជាតិ
រោងពុម្ពអង្គរអុហ្វសិត ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០១១ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

គំនិត ការលើកពីហេតុការណ៍ និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្ដល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ: http://www.cdri.org.kh